ក្រសួងអប់រំ យុវជន និងកីឡា
**Ministry of Education Youth and Sports**

វិទ្យាស្ថានជាតិអប់រំ
**National Institute of Education**

ញ៉ែម ធា
**NHEM THEA**

# ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា
# ករណីសិក្សា៖ ខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង

Situation of Resource Building Usage in Cambodia
Case Study: Tbong Khmum Kampong Cham and Prey Veng Provinces

និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ
ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ភ្នំពេញ ២០១៩

## ក្រសួងអប់រំ យុវជន និងកីឡា
**Ministry of Education Youth and Sports**

## វិទ្យាស្ថានជាតិអប់រំ
**National Institute of Education**

**ញ៉ែម ធា**

NHEM THEA

# ស្ថានភាពនៃការប្រើប្រាស់អាគារធនធាននៅកម្ពុជា
# ករណីសិក្សា៖ ខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង
Situation of Resource Building Usage in Cambodia

Case Study: Tbong Khmum Kampong Cham and Prey Veng Provinces

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ**

**ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត ឈាង សទ្ធាត**

**ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩**

**ក្រសួងអប់រំ យុវជន និងកីឡា**
**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**
**National Institute of Education**

**ញ៉ែម ធា**
**NHEM THEA**

# ស្ថានភាពនៃការប្រើប្រាស់អាគារធនធាននៅកម្ពុជា
# ករណីសិក្សា៖ ខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង

Situation of Resource Building Usage in Cambodia
Case Study: Tbong Khmum Kampong Cham and Prey Veng Provinces

គណៈកម្មការវាយតម្លៃនៃការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ថ្ងៃទី ខែ ឆ្នាំ២០១៩

**និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖**

សាស្ត្រាចារ្យដឹកនាំ ៖ ______________________

**បណ្ឌិត ឈាង សទ្ធាត**

តំណាងវិទ្យាស្ថានជាតិអប់រំ ៖ ______________________

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

តំណាងគណៈកម្មការវាយតម្លៃ ៖ ______________________

**ឯកឧត្តមបណ្ឌិត ជ័យ សារិន**

## សេចក្ដីប្រកាសរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ ញ៉ែម ធា សូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើង **«ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា»** ករណីសិក្សានៅ ខេត្ត កំពង់ចាម ខេត្ត ត្បូងឃ្មុំ និង ខេត្តព្រៃវែង សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។

ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាត ឬចុះបញ្ជីឯកសារយោងឡើយ ។ និក្ខេបបទស្រាវជ្រាវ និងចងក្រងខាងលើនេះពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

ហត្ថលេខា

**ញ៉ែម ធា**

## ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យណែនាំ នៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ សូមបញ្ជាក់ថាបេក្ខជន ឈ្មោះ **ញ៉ែម ធា** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើ ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឈាង សទ្ធាត**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នាដែលបានចូលរួមចំណែកជួយជ្រោមជ្រែង និងលះបង់ពេលវេលាដ៏មានតម្លៃក្នុងការចងក្រងនិក្ខេបបទនេះឡើង។

ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកឪពុក**ឱត្យ យ៉ុន** និងអ្នកម្តាយ**អ៊ឹម តូក** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើតចិញ្ចឹមបីបាច់ផ្តល់នូវដំបូន្មានល្អៗនិងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់ និងលំបាកព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹងដល់សព្វថ្ងៃនេះ។

លោកស្រី **សោម ច័ន្ទរ័ត្នមុនី** ជាភរិយានិងក្រុមគ្រួសារខ្ញុំ ដែលបានជួយជ្រោមជ្រែងផ្នែកថវិកា ស្មារតីនិងលើកទឹកចិត្តឱ្យខ្ញុំបាទបានបន្តការសិក្សាឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

សូមថ្លែងអំណរគុណឯកឧត្តម **បណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលវគ្គនាយកសាលា ឱ្យក្លាយជាអ្នកគ្រប់គ្រងអប់រំនៅក្នុងសាលារៀន។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់លោក **បណ្ឌិត ឈាង សទ្ធាត** ជាសាស្ត្រាចារ្យណែនាំគោល បានផ្តល់នូវមតិយោបល់ល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសសំណាកដើម្បីធ្វើការសម្ភាសន៍ ជាពិសេស ជំរុញឱ្យយើងខ្ញុំខិតខំប្រឹងប្រែងជម្នះឧបសគ្គ ដើម្បីសម្រេចបាននូវការសរសេរនិក្ខេបបទរហូតទទួលបានជោគជ័យប្រកបដោយមោទនភាព។

សូមថ្លែងអំណរគុណចំពោះឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលនាយកសាលានេះឡើង។

សូមថ្លែងអំណរគុណផងដែរដល់លោកនាយក នាយករង លោកគ្រូ អ្នកគ្រូទាំងអស់នៃវិទ្យាល័យសម្តេចតេជោហ៊ុនសែន.សួង ខេត្ត ត្បូងឃ្មុំ វិទ្យាល័យព្រះអង្គឌួង និងវិទ្យាល័យហ៊ុនសែន កំពង់ពពិល ខេត្ត ព្រៃវែង និងវិទ្យាល័យព្រះសីហនុ ខេត្ត កំពង់ចាម ដែលបានអនុញ្ញាតនិងសហការក្នុងការចូលរួមបំពេញកម្រងសំណួរធ្វើឱ្យការប្រមូលទិន្នន័យសម្រាប់ការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

-មិត្តភក្តិរួមជំនាន់ទី២ទាំងអស់នៃវគ្គនាយកសាលា ដែលបានជួយផ្តល់យោបល់និងមតិក្នុងការកែលម្អ ហើយជួយរកឯកសារពាក់ព័ន្ធនៃនិក្ខេបបទនេះ។

-គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំ  បានជួយជ្រោមជ្រែងកិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់ សូមប្រសិទ្ធពរជ័យដល់ ឯកឧត្តម លោកជំទាវ លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់សូមមានសុខភាពល្អបរិបូណ៌ កម្លាំងមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបានពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។។

ថ្ងៃ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩
និស្សិតវគ្គនាយកសាលា

**ញ៉ែម ឆា**

# មូលន័យសង្ខេប

អគារធនធានបានចាប់កកើតឡើងជាដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈ "គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ចុះថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០០៨" ក្រោមការខិតខំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍។ មកដល់ឆ្នាំសិក្សា២០១៨-២០១៩នេះ អគារធនធានសរុបនៅទូទាំងប្រទេសកម្ពុជាមានចំនួន៣៦ និងកំពុងសាងសង់ចំនួន១៤ទៀត ដែលគ្រោងនឹងសង់រួចរាល់នៅកំឡុងត្រីមាសទី១នៃឆ្នាំ២០២០ ពេលនោះនឹងមានអគារធនធានទាំងអស់ចំនួន៥០ នៅទូទាំងប្រទេស។

នៅក្នុងអគារធនធានរួមមានផ្នែកជាច្រើនដូចជា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ ការិយាល័យសម្រាប់នាយក នាយករង និងលេខា បន្ទប់គ្រូបង្រៀន បង្គន់អនាម័យ បណ្តាញទឹក បណ្តាញភ្លើងជាដើម។ វិទ្យាល័យដែលមានអគារធនធានស្ថិតនៅ គឺជាសាលាមធ្យមសិក្សាធនធាន ហើយមានចក្ខុវិស័យតឹកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងយល់ពី "ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន នៃសាលាមធ្យមសិក្សាធនធាន ដែលកំពុងដំណើរការ នៅក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងខេត្ត ព្រៃវែង ។ ម៉្យាងទៀតការសិក្សានេះ ក៏បានពិនិត្យរកបញ្ហាប្រឈមនានា នៃការប្រើប្រាស់បន្ទប់ពិសោធន៍ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន នៅក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងខេត្ត ព្រៃវែង។ ការសិក្សាស្រាវជ្រាវនេះកំណត់យកសំណាកចំនួន៦៨នាក់ ក្នុងចំណោមសំណាកសាកល១១១នាក់ ដោយជ្រើសរើសយកលោកនាយក ឬនាយករងបច្ចេកទេស ៤នាក់ បរិវច្ឆការីចំនួន១៦នាក់ និងលោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រពីថ្នាក់ទី១០ដល់ថ្នាក់ទី១២ ចំនួន៤៨នាក់។

ផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្ររបស់អគារធនធាន នៃសាលាមធ្យមសិក្សាធនធាន **នៅមានកម្រិតនៅឡើយ**។ ការប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធានរបស់សាលាមធ្យមសិក្សាធនធាន មិនទាន់អស់លទ្ធភាពនៅឡើយទេ។ គណៈគ្រប់គ្រងសាលា ត្រូវតែពង្រឹងយន្តការអនុវត្តបន្ទប់ពិសោធន៍ឱ្យបានសកម្មជាងនេះទៀត ជាពិសេសជំរុញគ្រូមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកមធ្យមសិក្សាទុតិយភូមិ ឱ្យអនុវត្តម៉ោងពិសោធន៍របស់គាត់ជាប្រចាំ តាមកម្មវិធីសិក្សាដែលមានក្នុងសៀវភៅសិក្សាគោល។

មាតិកា

ជំពូកទី១ ........ 5

សេចក្តីផ្តើម ........ 5

១.១.សាវតារ ........ 5

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 12

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 14

១.៤ សំណួរនៃការស្រាវជ្រាវ ........ 15

១.៥ សម្មតិកម្ម ........ 15

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ 15

១.៧ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ 16

១.៧.១ ខ្លឹមសារនៃការស្រាវជ្រាវ ........ 16

១.៧.២ ទីតាំងនិងពេលវេលា ........ 16

១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 17

........ 18

ជំពូកទី២ ........ 19

រំឭកទ្រឹស្តី ........ 19

២.១ សេចក្តីផ្តើម ........ 19

២. ២ និយមន័យ ........ 20

២. ៣ ឯកសារ-ទ្រឹស្តីពាក់ព័ន្ធ ........ 21

២.៣.១.គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន ........ 21

២.៣.២.ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន ........ 23

២.៣.៣.លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន 25
២.៣.៤.ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត 25
២.៣.៥.បណ្តាញសាលាមធ្យមសិក្សាធនធាន 26
២.៣.៦.យុទ្ធសាស្រ្ត 28
២.៣.៧.ការគ្រប់គ្រង និងដំណើរការអគារធនធាន 29
២.៣.៨.ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាធនធាន 37
២.៣.៩.ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាបណ្តាញ 42
ជំពូកទី៣ 51
វិធីសាស្រ្តស្រាវជ្រាវ 51
៣.១.ដំណើរការនៃការស្រាវជ្រាវ 51
៣.២.វិធីសាស្រ្តប្រមូលទិន្នន័យ 51
៣.៣.ការជ្រើសរើសសំណាក 52
៣.៤.ឧបករណ៍ស្រាវជ្រាវ 53
៣.៥.កម្រងសំណួរ និងគោលបំណង 54
៣.៦ វិធីសាស្រ្តប្រមូលទិន្នន័យ 55
៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ 56
៣.៨.ការវិភាគទិន្នន័យ 57
ជំពូកទី៤ 59
លទ្ធផលស្រាវជ្រាវ និងការពិភាក្សា 59
៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ 59
៤.១.១ កម្រងសំណួរផ្នែកទី១៖ ព័ត៌មានទូទៅ 59

៤.១.២ កម្រងសំណួរផ្នែកទី២៖ កម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់អគារធនធាន ..... 61
៤.២.១ កម្រងសំណួរផ្នែកទី២៖ ព័ត៌មានទូទៅ ..... 71
៤.២.២ កម្រងសំណួរផ្នែកទី២៖ កម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់អគារធនធាន ..... 73
ជំពូកទី ៥ ..... 86
សេចក្តីសន្និដ្ឋាន និងសំណូមពរ ..... 86
៥.១ សេចក្តីសន្និដ្ឋាន ..... 86
៥.២ សំណូមពរ ..... 87
១. សម្រាប់សាលា ..... 87
២. សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ..... 87
៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ..... 88

# ជំពូកទី១

# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១.សារតារ

សង្គមជាតិមួយមានការរីកចម្រើនជឿនលឿនទៅមុខបាន គឺដោយសារសង្គមជាតិនោះពោរពេញទៅដោយពលរដ្ឋមានចំណេះដឹង ចំណេះធ្វើ ពោលគឺពលរដ្ឋរបស់ពួកគេបានចូលមកទទួលការអប់រំនៅក្រោមដំបូលសាលា រួមជាមួយនិងលោកគ្រូអ្នកគ្រូដែលប៉ិនប្រសព្វក្នុងការផ្ទេរពុទ្ធិ បានផ្លាស់ប្តូរអកប្បកិរិយា ឬឥរិយាបថរបស់អ្នកសិក្សា ជាវិជ្ជមានហើយជាអចិន្ត្រៃយ៍។ ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជា គឺក្លាយជាប្រជាជាតិដែលមានចំណូលមធ្យមកម្រិតខ្ពស់ ប្រកបដោយវិបុលភាពត្រឹមឆ្នាំ២០៣០។ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ និងប្រែក្លាយប្រទេសនេះទៅជាសង្គមពុទ្ធិ ប្រកបដោយសុខសន្តិភាពនិងលទ្ធិប្រជាធិបតេយ្យ ដែលកាន់តែមានសមត្ថភាពប្រកួតប្រជែងនៅថ្នាក់តំបន់ និងអន្តរជាតិ(ផែនទី ២០១៩)។ក្នុងន័យនេះគឺរដ្ឋត្រូវការសាលារៀន ត្រូវការអគារ ដើម្បីបង្កើតឱកាសក្នុងការសិក្សាគ្រប់បរិបទ និងគ្រប់ទម្រង់ ក្នុងប្រព័ន្ធ ក្រៅប្រពន្ធ និងមិនផ្លូវការ សម្រាប់ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់។

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៤- ២០១៨ និងដំណាក់កាលទី៤ឆ្នាំ ២០១៨- ២០២៣ បានដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ពីឋានៈនៃប្រទេសចំណូលទាបទៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០។ក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ គឺមនុស្សត្រូវបានចាត់ទុកជាអាទិភាពខ្ពស់ បន្ទាប់មក ផ្លូវ ភ្លើង និងទឹក ហើយដំណាក់កាលទី៤ រាជរដ្ឋាបានសម្រេចបន្តអាទិភាពទាំងបួនដដែល ដោយកំណត់យកមនុស្សជាអាទិភាពទី១(ផែនទី ២០១៩)។ត្រង់នេះសបញ្ជាក់ឱ្យឃើញថា មនុស្សគឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ ដូចនេះរាជរដ្ឋាភិបាលត្រូវអប់រំ បណ្តុះបណ្តាលពលរដ្ឋរបស់ខ្លួនឱ្យក្លាយជាពលរដ្ឋពេញលេញដែលប្រកបទៅដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋត្រូវប្រមូលអ្នកសិក្សាទាំងអស់ចូលក្នុងសាលា ពីព្រោះថាយើងមិនអាចបណ្តុះបណ្តាលពលរដ្ឋទាំងនោះ នៅក្រោមដើមឈើ ឬនៅហាលវាលហាលខ្យល់បានទេ យើងត្រូវមានសាលារៀនដើម្បីឱ្យពួកគេទទួលបាននូវការអប់រំ។ដូចនេះសាលារៀន គឺជាកន្លែងមួយដែលអ្នកសិក្សាចូលមកក្រេបយកចំណេះដឹងគ្រប់រសជាតិ ដើម្បីអភិវឌ្ឍខ្លួនទៅជាមនុស្សវិជ្ជមានអចិន្ត្រៃយ៍។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងការទទួលបានការអប់រំ ដោយរដ្ឋត្រូវទទួលខុសត្រូវក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានការអប់រំគ្រប់កម្រិតទាំងអស់ប្រកបដោយគុណភាព។ មាត្រា៦៥ នៃរដ្ឋធម្មនុញ្ញ ចែងថា"រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប" ។ មាត្រា៦៦ នៃរដ្ឋធម្មនុញ្ញ បង្ហាញពីគោលការណ៍សំខាន់ៗនៃប្រពន្ធអប់រំ "រដ្ឋកសាងប្រពន្ធអប់រំមួយពេញលេញនិងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការ កសាងជីវិត" ។ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំនៅកម្ពុជា ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែធ្នូ ឆ្នាំ២០០៧ បានចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ រាជរដ្ឋាភិបាលកម្ពុជាទទួលយកទស្សនៈទាន ដែលថាការអប់រំគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលមានតួនាទីយ៉ាងសំខាន់ ដើម្បីឱ្យប្រជាពលរដ្ឋអាចមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្តីសិទ្ធកុមារ កាលពីឆ្នាំ១៩៩២ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការកាលពីឆ្នាំ២០១២។

ចក្ខុវិស័យសម្រាប់ប្រព័ន្ធអប់រំកម្ពុជាឆ្នាំ២០៣០គឺរឹងមាំនិងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។វិស័យអប់រំជាតិ គឺរួមចំណែកបង្កើតនូវសង្គមពុទ្ធិតាមរយៈការអភិវឌ្ឍ ធនធានមនុស្សដែលមានចំណេះដឹង និងសមត្ថភាព សម្បទាគ្រប់គ្រាន់ ជំនាញ ភាពច្នៃប្រឌិត នវានុវត្តន៍ ស្មារតីសហគ្រិនភាព និងក្រមសីលធម៌ខ្ពស់។ក្នុងន័យនេះគឺបង្កើតនូវឱកាសក្នុងការ សិក្សាគ្រប់បរិបទ និងទម្រង់ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការសម្រាប់ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់។ចំណែកឯចក្ខុវិស័យសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្តល់នូវការអប់រំ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកប ដោយគុណភាពដើម្បីក្លាយជាចលករក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច(ផែនទី ២០១៩)។ក្រសួងអប់រំ យុវជន និងកីឡា នឹងក្លាយជាក្រសួងមួយដែលមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញមុខងារដើម្បីធានាឱ្យបាននូវភាពប្រសើរឡើងលើការទទួលសេវា ប្រកបដោយ សមធម៌ គុណភាព និងភាពឆ្លើយតប ក៏ដូចជាអភិបាលកិច្ចនិងការគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងអស់នៅគ្រប់កម្រិតថ្នាក់។

ចក្ខុវិស័យរបស់សាលារៀនកម្ពុជា ឆ្នាំ២០៣០ គឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា(ផែនទី ២០១៩)។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងមានគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀននឹងទទួលនឹងទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការងារបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកប ដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការរៀននិងបង្រៀនប្រកប ដោយគុណភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។ ដូចគ្នានេះដែរ ចក្ខុវិស័យសម្រាប់បន្ទប់រៀនកម្ពុជាឆ្នាំ២០៣០ គឺជាបន្ទប់រៀនវៃឆ្លាតដែលផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការរៀនសូត្រ (ផែនទី ២០១៩)។ បន្ទប់រៀនកម្ពុជាត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យា ដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលសម្រាប់ការសិក្សាសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា តាមការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបអន្តរកម្ម និងបែបសហការ និងវិធីសាស្ត្រចម្រុះ។

គ្មានសិស្ស និស្សិត បណ្ឌិត បញ្ញាវន្ត ណាមួយដែនមានចំណេះវិជ្ជាប្រកបដោយសីលធម៌ដ៏ឧត្តុង្គឧត្តម ដោយមិនបានឆ្លងកាត់សាលារៀននោះទេ គឺសុទ្ធ តែបានចូលសាលាចាប់តាំងពីមត្តេយ្យ បឋម រហូតដល់វិទ្យាល័យ និងក្រោយឧត្តមសិក្សា។ យោងតាមស្ថិតិ និងសូចនាករអប់រំសាធារណៈ របស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថាក្នុងឆ្នាំសិក្សា២០១៧-២០១៨នៅទូទាំងប្រទេសកម្ពុជាមានអគារចំនួន២៦ ៣១៣១ខ្នង ត្រូវជា ៩៧៦០០បន្ទប់ ក្នុងនោះអគារសាងសង់អំពីស៊ីម៉ង់ត៍-ឥដ្ឋមានចំនួន ២០០២៧ខ្នង ត្រូវជា៨៩៥៣៩បន្ទប់ អគារសាងសង់អំពីឈើមានចំនួន២៩៤៨ខ្នងត្រូវជា ៧៨០០បន្ទប់ និងអគារសាងសង់អំពីឬស្សី មានចំនួន១៦០ខ្នង ត្រូវជា២៦១បន្ទប់។ អគារសិក្សាទាំងអស់នេះអាចស្រូបបានសិស្សានុសិស្សចំនួន៤.៣៧៩.៨៦២នាក់ក្នុងនោះស្រីមានចំនួន ២.១១៧.៥១៧នាក់។បើយោងតាមស្ថិតិ និងសូចនាករអប់រំសាធារណៈ របស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថាក្នុងឆ្នាំសិក្សា ២០១៨-២០១៩នៅទូទាំងប្រទេសកម្ពុជាមានអគារចំនួន២៣៨២៨ខ្នង ត្រូវជា ១០០៨៥៨បន្ទប់ ក្នុងនោះអគារសាងសង់អំពីស៊ីម៉ង់ត៍-ឥដ្ឋមានចំនួន២០៨១៥ខ្នង ត្រូវជា៩៣០២៩បន្ទប់ អគារ

សាងសង់អំពីឈើមានចំនួន២៨៨១ខ្នងត្រូវជា៧៥៩៣បន្ទប់ និងអគារសាងសង់អំពីឬស្សី មានចំនួន១២៨ខ្នង ត្រូវជា២៣៦បន្ទប់។ អគារសិក្សាទាំងអស់នេះអាចស្រូបបានសិស្សានុសិស្សចំនួន៩.៩៣១.៧៧៤នាក់ក្នុងនោះស្រីមានចំនួន២.១៩៣.២០១នាក់។ ក្រោយថ្ងៃ៧មករា ១៩៧៩ ប្រទេសកម្ពុជារស់រានឡើងវិញពីបាតដៃទទេ ពោលគឺគ្មានអ្វីៗទាំងអស់ អ្នកចេះដឹងត្រូវបានពួកខ្មែរក្រហមសម្លាប់អស់ គ្មានសាលារៀន គ្មានគ្រូបង្រៀន។ នៅឆ្នាំសិក្សា១៩៧៩-១៩៨០ ក្រសួងអប់រំបានចាប់ផ្ដើមឡើងវិញដោយមានសាលាចំនួនតែមត្តេយ្យសិក្សានិងបឋមសិក្សាចំនួន៩៦ខ្នង ត្រូវជា១២២៩៩បន្ទប់មានសិស្សចូលរៀនចំនួន៩៥៥៩៦នាក់ អនុវិទ្យាល័យចំនួន១៩ខ្នង ត្រូវជា១០១បន្ទប់មានសិស្សចូលរៀនចំនួន៩៨០៣នាក់ និងវិទ្យាល័យមានចំនួនមួយខ្នង ត្រូវជា៧បន្ទប់ មានសិស្សចូលរៀនចំនួន២៨០នាក់(ស្ថិតិអប់រំ២០១៨-២០១៩)។ រហូតដល់ឆ្នាំសិក្សា២០១៨-២០១៩ ក្រសួងអប់រំមានសាលារៀនចំនួន២៣៨២៩ខ្នង ត្រូវជា ១០០៨៥៨បន្ទប់ និងទទួលសិស្សានុសិស្សឱ្យចូលរៀនបានចំនួន ៩.៩៣១.៧៧៤ នាក់ ក្នុងនោះស្រីចំនួន ២.១៩៣.២០១នាក់។ តាមរបាយការណ៍សង្ខេបរបស់នាយកដ្ឋានចំណេះទូទៅ ចុះថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០១៤ ស្ដីពីការបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ បានបង្ហាញឱ្យឃើញថា ក្នុងឆ្នាំសិក្សា ១៩៧៩-១៩៨០ សិស្សចុះឈ្មោះប្រឡងមានតែ ៨២នាក់ និងប្រឡងជាប់មានចំនួន៧២នាក់ ត្រូវជា ៨៧,៨០ភាគរយ។ ពីមួយឆ្នាំទៅមួយឆ្នាំសិស្សចុះឈ្មោះចូលរៀនមានការកើនឡើងជានិច្ច ព្រមជាមួយនោះអគារសិក្សាក៏កើនឡើងដែរ រហូតដល់ក្នុងឆ្នាំសិក្សា ២០១២-២០១៣ មានសិស្សចុះឈ្មោះប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិមានចំនួន ១០៥.២៩៧នាក់ហើយប្រឡងជាប់មានចំនួន ៩១៣៧០នាក់ ត្រូវជា ៨៦,៧៧ភាគរយ(ក្រសួងអយក.២០១៤)។ ជារួមចាប់ពីឆ្នាំសិក្សា ១៩៧៩-១៩៨០ ដល់ឆ្នាំសិក្សា២០១២-២០១៣ មានសិស្សចុះឈ្មោះប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិចំនួន ១.០២៤.៦៣០នាក់ និងប្រឡងជាប់មានចំនួន ៧១៦.៦៩៦នាក់ ត្រូវជា៦៩,៩៥ភាគរយ។ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សចុះឈ្មោះប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិចំនួន១១៥.២០៨នាក់ និងប្រឡងជាប់ចំនួន ៧៩០៥២នាក់ ត្រូវជា៦៨,៦២ភាគរយ(ក្រសួងអយក.២០១៩)។ ចន្លោះពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សចុះឈ្មោះប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិចំនួន៥៩១.២២៤នាក់ និងប្រឡងជាប់ចំនួន៣៥៥.០៦៤នាក់ ត្រូវជា ៦០,០៥ភាគរយ (ក្រសួងអយក.២០១៤-២០១៩)។ សរុបជារួមចាប់ពីឆ្នាំសិក្សា១៩៧៩-១៩៨០ ដល់ឆ្នាំសិក្សា ២០១៨-២០១៩ មានសិស្សចុះឈ្មោះប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិចំនួន ១.៦១៥.៨៥៤ នាក់ និងប្រឡងជាប់ចំនួន ១.០៧១.៧៦០នាក់ ត្រូវជា ៦៦,៣៣ភាគរយ។

ប្រទេសកម្ពុជាបាននិងកំពុងឆ្លងកាត់សម័យកាលសកលភាវូបនីយកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហាគមន៍អាស៊ាន ជាកត្តាចាំបាច់កម្ពុជាត្រូវធានាឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមភាព។ ប្រការនេះទាមទារឱ្យកម្ពុជាមានសមត្ថភាពក្នុងការទទួលយកបាននិងប្រើប្រាស់ចំណេះដឹងនិងនវានុវត្តន៍ ដែលផ្អែកលើវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ វិទ្យាសាស្ត្រផ្តល់ដល់យើងនូវលទ្ធភាពក្នុងការបង្កើតនូវឧបករណ៍ជាច្រើន សម្រាប់បម្រើដល់ការរស់រាននិងការវិវត្តរបស់មនុស្ស ព្រមទាំងបង្កើតនូវកាលានុវត្តភាពនិងវេទិកាថ្មីសម្រាប់បច្ចេកវិទ្យាថ្មីៗ និងកាន់តែឿនលឿនជាងមុន។ ដោយហេតុនេះហើយ កម្ពុជាត្រូវការបណ្តុះបណ្តាលអ្នកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាជាច្រើនបន្ថែមទៀត។ បើតាមលទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)នៅឆ្នាំ២០១៥ កម្ពុជាត្រូវការវិស្វករចំនួន ៣៥០០០នាក់ និងអ្នកបច្ចេកទេសប្រហែលជា ៤៦០០០នាក់ ដើម្បីឱ្យកម្ពុជាទទួលបានកំណើនផលទុនក្នុងស្រុកសរុប (GDP)ចន្លោះពី៦ទៅ៨ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ(ក្រសួង២០១៦)។គោលនយោបាយនេះមានចក្ខុវិស័យ អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌លើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាពនិងស្មើភាពស្មើសិទ្ធិជាមួយអន្តរជាតិ ស្របតាមគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥។គោលនយោបាយនេះមានគោលបំណង អភិវឌ្ឍសិស្សចំណេះទូទៅ និងនិស្សិត ឧត្តមសិក្សា ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងសហាគមន៍អាស៊ាន។ អគារធនធានគឺជាអគារសិក្សាមួយដែលគាំទ្រដល់កម្មវិធីស្ទែម(STEM) ពីព្រោះនៅក្នុងអគារធនធានមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រសម្រាប់បួនមុខវិជ្ជាគឺ(១)បន្ទប់ពិសោធន៍រូបវិទ្យា(២)បន្ទប់ពិសោធន៍គីមីវិទ្យា (៣)បន្ទប់ពិសោធន៍ជីវវិទ្យា (៤)បន្ទប់ពិសោធន៍ផែនដីវិទ្យារួមទាំងមានបន្ទប់កំព្យូទ័រចំនួនពីរ និងបណ្ណាល័យចំនួនមួយ។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា (STEM) ក្នុងគោលបំណងលើកកម្ពស់សមត្ថភាព សិស្ស និស្សិត និងអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាព និងការទទួលខុសត្រូវ ក្នុងផ្នែក វិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ប្រកប ដោយបរិយាបន្ន និងចីរភាព(ក្រសួងអប់រំ២០១៨)។

អគារធនធានដែលបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្រោមគម្រោងអភិវឌ្ឍវិស័យអប់រំទី២ (ESDP2) តាមប្រកាសលេខ ៣២៧៧ អយក.ប្រក ចុះថ្ងៃទី៤ខែធ្នូ ឆ្នាំ

២០១០ មានចំនួន១៨ ដែលស្ថិតនៅក្នុងវិទ្យាល័យៈ(១)វិទ្យាល័យ ហ៊ុនសែនខ្លាកូន ស្ថិតនៅក្នុងសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ (២)វិទ្យាល័យ នេត យ៉ង់ ស្ថិតនៅក្នុងសង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបងខេត្តបាត់ដំបង (៣)វិទ្យាល័យ ព្រះសីហនុ ស្ថិតនៅក្នុង សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម (៤)វិទ្យាល័យ ព្រះបាទសុរាម្រឹក ស្ថិតនៅក្នុង សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំ ខេត្តកំពង់ឆ្នាំង (៥)វិទ្យាល័យ កំពង់ស្ពឺ ស្ថិតនៅក្នុងសង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ (៦)វិទ្យាល័យ ហ៊ុនសែនបល្ល័ង្គ ស្ថិតនៅក្នុងសង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ (៧)វិទ្យាល័យ ព្រះរាជសម្ភារ ស្ថិតនៅក្នុងសង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត (៨)វិទ្យាល័យ ហ៊ុនសែន សេរីភាព ស្ថិតនៅក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល (៩)វិទ្យាល័យ កោះកុង ស្ថិតនៅក្នុងសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (១០)វិទ្យាល័យ ក្រចេះក្រុង ស្ថិតនៅក្នុងសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ (១១) វិទ្យាល័យ ជាស៊ីម ត្បែងមានជ័យ ស្ថិតនៅក្នុងសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ (១២)វិទ្យាល័យ ព្រះអង្គឌួង ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង (១៣)វិទ្យាល័យ ពោធិ៍សាត់ ស្ថិតនៅក្នុងសង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ (១៤) វិទ្យាល័យ អង្គរ ស្ថិតនៅក្នុងសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប (១៥)វិទ្យាល័យ ក្រុងព្រះសីហនុ ស្ថិតនៅក្នុងសង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (១៦)វិទ្យាល័យ ព្រះរាជបូជនីយកិច្ច ស្ថិតនៅក្នុងសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង (១៧)វិទ្យាល័យ ស្វាយរៀង ស្ថិតនៅក្នុងសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង (១៨)វិទ្យាល័យ ជាស៊ីម តាកែវ ស្ថិតនៅក្នុងសង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ។ដំណាក់កាលទី២ ក្រោមគម្រោង អភិវឌ្ឍវិស័យអប់រំទី២ (EEQP2) តាមប្រកាសលេខ ២៥៩០ អយក.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១១ មានចំនួន៨ ដែលស្ថិតនៅក្នុងវិទ្យាល័យៈ(១)វិទ្យាល័យ ហ៊ុន សែន ជម្ពូវ័ន ស្ថិតនៅក្នុងសង្កាត់ចោមចៅ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ (២)វិទ្យាល័យ ទេពប្រណម្យ ស្ថិតនៅក្នុងឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល (៣)វិទ្យាល័យ សម្តេចតេជោហ៊ុនសែន.សួង ស្ថិតនៅក្នុងសង្កាត់សួង ក្រុងសួង ខេត្ត ត្បូងឃ្មុំ (៤)វិទ្យាល័យ ហ៊ុនសែន មណ្ឌលគិរី ស្ថិតនៅក្នុងសង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី (៥)វិទ្យាល័យ សម្តេចឪ-សម្តេចម៉ែ ស្ថិតនៅក្នុងសង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្ត រតនគិរី (៦)វិទ្យាល័យ រវៀង ស្ថិតនៅក្នុងឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ (៧)វិទ្យាល័យ ហ៊ុនសែន ក្រុងទេពនិម្មិត ស្ថិតនៅក្នុងសង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្ត ប៉ៃលិន (៨)វិទ្យាល័យ ហ៊ុនសែន ចំការដូង ស្ថិតនៅក្នុងឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ដំណាក់កាលទី៣ ក្រោមគម្រោង អភិវឌ្ឍវិស័យអប់រំទី

២ (EEQP) តាមប្រកាសលេខ ៦០៣ អយក.ប្រក ចុះថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ ២០១៣ មានចំនួន៣ ដែលស្ថិតនៅក្នុងវិទ្យាល័យ៖(១)វិទ្យាល័យ សម្តេចឪ ស្ថិតនៅក្នុងឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ (២)វិទ្យាល័យ ហ៊ុន សែនកំពង់ពពិល ស្ថិតនៅក្នុងឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង (៣)វិទ្យាល័យបវេល ស្ថិតនៅក្នុងឃុំបវេល ស្រុកបវេល ខេត្ត បាត់ដំបង។ដំណាក់កាលទី៤ ក្រោមគម្រោង អភិវឌ្ឍវិស័យអប់រំទី២ (EEQP) តាមប្រកាសលេខ១០១០ អយក.ប្រក ចុះថ្ងៃទី០២ខែឧសភា ឆ្នាំ ២០១៤ មានចំនួន៧ ដែលស្ថិតនៅក្នុងវិទ្យាល័យ៖(១)វិទ្យាល័យ ហ៊ុនសែនឧត្តរមានជ័យ ស្ថិតនៅក្នុងសង្កាត់សំរោង ក្រុងសំរោង ខេត្ត ឧត្តរមានជ័យ (២)វិទ្យាល័យច្បារអំពៅ ស្ថិតនៅក្នុងសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ (៣)វិទ្យាល័យ ហ៊ុនសែនប្រសូតិ ស្ថិតនៅក្នុងឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ (៤)វិទ្យាល័យ ហ៊ុនសែនឈូក ស្ថិតនៅក្នុងឃុំសត្វពង ស្រុកឈូក ខេត្ត កំពត (៥)វិទ្យាល័យ កំពង់ថ្ម ស្ថិតនៅក្នុងឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្ត កំពង់ធំ (៦)វិទ្យាល័យ ក្រឡាញ់ ស្ថិតនៅក្នុងឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្ត សៀមរាប (៧)វិទ្យាល័យ ជប់វារី ស្ថិតនៅក្នុងឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។សរុបទាំង៤ដំណាក់កាល យើងមាន អគារធនធានចំនួន៣៦ និងសាលាបណ្តាញចំនួន៧៥ ។

សព្វថ្ងៃក្រសួងអប់រំ យុវជន និងកីឡា កំពុងសាងសង់អគារធនធានចំនួន១៤ទៀត ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី១ (USESDP1) ដែលនឹងសង់រួចនៅក្នុងឆ្នាំ២០២០នេះ។ អគារធនធានទាំង១៤ ដែលកំពុងសាងសង់នោះរួមមាន (១)វិទ្យាល័យក្រុងប៉ោយប៉ែត ស្ថិតក្នុងខេត្តបន្ទាយមានជ័យ (២)វិទ្យាល័យហ៊ុនសែនភ្នំសំពៅ ស្ថិតក្នុងខេត្តបាត់ដំបង (៣)វិទ្យាល័យហ៊ុនសែនស្គន់ ស្ថិតក្នុងខេត្តកំពង់ចាម (៤)វិទ្យាល័យហ៊ុនសែនបរិបូរណ៍ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង (៥)វិទ្យាល័យ ឧដុង្គ ស្ថិតក្នុងខេត្តកំពង់ស្ពឺ (៦)វិទ្យាល័យកំពង់ធំ ស្ថិតក្នុងខេត្តកំពង់ធំ (៧)វិទ្យាល័យហ៊ុនសែនកោះធំ ស្ថិតក្នុងខេត្តកណ្តាល (៨)វិទ្យាល័យស្រែអំបិល ស្ថិតក្នុងខេត្តកោះកុង (៩)វិទ្យាល័យហ៊ុនសែនសុភៈបុរៈ ស្ថិតក្នុងខេត្តក្រចេះ (១០) វិទ្យាល័យពាមរក៍ ស្ថិតក្នុងខេត្តព្រៃវែង (១១)វិទ្យាល័យហ៊ុនសែនវាលរេញ ស្ថិតក្នុងខេត្តព្រះសីហនុ (១២)វិទ្យាល័យហ៊ុនសែនក្រគរ ស្ថិតក្នុងខេត្តពោធិ៍សាត់ (១៣)វិទ្យាល័យអន្លង់វែង ស្ថិតក្នុងខេត្តឧត្តរមានជ័យ និង(១៤)វិទ្យាល័យហ៊ុនសែនអូររាំងឪ ស្ថិតក្នុងខេត្តត្បូងឃ្មុំ។ សរុបក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជាយើងនឹងមានអគារធនធានចំនួន៥០ និងសាលាបណ្តាញចំនួន៨៧ ដើម្បីលើកកម្ពស់គុណភាពអប់រំនៃកម្ពុជាឱ្យមានភាពកាន់តែប្រសើរឡើង។

ការសាងសង់អគារធនធានទាំងនេះ គឺដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ ដោយផ្តោតលើគោលនយោបាយគន្លឹះសំខាន់ៗរួមមានៈការធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំ និងការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។អគារធនធាននីមួយៗមានបន្ទប់កំព្យូទ័រចំនួន២ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន២ សាលប្រជុំមួយ បណ្ណាល័យមួយ និងបន្ទប់ការិយាល័យព្រមទាំងមានបំពាក់គ្រឿងសង្ហារឹម និងសម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់បម្រើឱ្យការបង្រៀន និងរៀន លើផ្នែកសកម្មភាពប្រតិបត្តិសិក្សាស្រាវជ្រាវរបស់គ្រូបង្រៀននិងសិស្សានុសិស្សទាំងនៅក្នុងអគារធនធានវិទ្យាល័យ និងមកពីគ្រឹះស្ថានមធ្យមសិក្សាបណ្តាញផងដែរ។

នៅវិទ្យាល័យទេពប្រណម្យ ខេត្តកណ្តាល នាព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំពិធីសម្ពោធជានិមិត្តរូបដាក់ឱ្យដំណើរការអគារធនធានចំនួន ២៦ ដែលជាហិរញ្ញប្បទានធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ក្រោមអធិបតីភាពឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្តាល តំណាងធនាគារអភិវឌ្ឍអាស៊ីប្រចាំនៅកម្ពុជា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ មន្ត្រីអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់ ប្រតិភូអប់រំ យុវជន និងកីឡារាជធានី-ខេត្ត អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍន៍ តំណាងសហគមន៍ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សសរុបចំនួន ២ ១៥០ នាក់។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់ធ្វើ កំណែទម្រង់វិស័យអប់រំ ដើម្បីធ្វើ ឲ្យវិស័យអប់រំនៅកម្ពុជាមានការរីកចម្រើននិងមានសក្តានុពលភាពទាំងនៅក្នុងតំបន់ និងនៅលើសកលលោក។ មិនត្រឹមតែប៉ុណ្ណោះ យើងឃើញថា ក្រសួងអប់រំ យុវជន និងកីឡា សម័យបច្ចុប្បន្នបានបង្កើតសាលាមធ្យមសិក្សាធនធាន ដែលមានអគារធនធាននៅក្នុងនោះ ដើម្បីគាំទ្រនូវកម្មវិធីស្ទែម(Stem)។ សាលាមធ្យមសិក្សាធនធាន គឺជាសាលាមធ្យមសិក្សាមួយនៅក្នុងក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ដែលត្រូវបានជ្រើសរើស ដើម្បីនាំមុខក្នុងការធ្វើឱ្យសាលារៀនមានការរីកចម្រើនគ្រប់ផ្នែក ដូចជាការអនុវត្តកម្មវិធីសិក្សា លទ្ធផលសិក្សា ចែករំលែកបទពិសោធ (ការបង្រៀន រៀន ការគ្រប់គ្រង ការប្រើប្រាស់...) ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការអភិវឌ្ឍសាលារៀន និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។សាលា

មធ្យមសិក្សាធនធាននឹងក្លាយជា សាលាមធ្យមសិក្សានាំមុខក្នុងចំណោមសាលាមធ្យមសិក្សាបណ្តាញដែលមានក្នុងមូលដ្ឋាន(ក្រសួងអប់រំ២០១១)។

ដោយមើលឃើញនូវតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានពង្រីក និងលើកទឹកចិត្តចំពោះការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាក្នុងកម្រិតមូលដ្ឋាន និងកម្រិតខ្ពស់។ ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើជំនាញទាំងនេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិ។ ក្រសួងមានបេសកម្មក្នុងការផ្សារភ្ជាប់ខ្លឹមសារមេរៀន ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយផ្តោតលើការអភិវឌ្ឍជំនាញសម្រាប់សតវត្សទី២១។ ពិសេសជាងនេះទៅទៀត ការរៀបចំគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា មានភាពចាំបាច់និងបន្ទាន់បំផុត សម្រាប់ចង្អុលបង្ហាញជាយុទ្ធសាស្ត្រ និងជាផែនទីបង្ហាញផ្លូវសម្រាប់រាល់សកម្មភាពអប់រំនិងស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតិវិទ្យា។ ប្រការនេះកាន់តែធ្វើឱ្យការអភិវឌ្ឍធនធានមនុស្សមានគាំទ្រកាន់តែខ្លាំង ដល់ការសម្រេចដោយជោគជ័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា និងការពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាមួយសហគមន៍អន្តរជាតិ (ក្រសួងអប់រំ២០១៦)។

ភារកិច្ចរបស់សាលាមធ្យមសិក្សាធនធាន ជាសាលានាំមុខសាលាមធ្យមសិក្សាដទៃទៀត ក្នុងការអនុវត្តគោលនយោបាយ គោលការណ៍ កម្មវិធីសិក្សាគោល និងលិខិតបទដ្ឋាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធររាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អលើការងារគ្រប់គ្រង និងប្រើប្រាស់ធនធាន(មនុស្ស សម្ភារៈ ថវិកា) របស់សាលារៀន។ អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនទាំងផ្នែកចំណេះដឹង ផ្នែកជំនាញឯកទេស និងផ្នែកចិត្តគរុកោសល្យឱ្យដល់កម្រិតស្តង់ដាគ្រូក្នុងតំបន់ឬអន្តរជាតិ នៅសាលាមធ្យមសិក្សាធនធាននិងសាលាបណ្តាញ។ ពង្រឹងសមត្ថភាពវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដោយសាលារៀនធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីប្រែក្លាយសាលាឱ្យទៅជាមជ្ឈមណ្ឌលនៃឧត្តមភាពនៃការបង្រៀននិងរៀន។ ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន សំដៅបង្កលក្ខណៈឱ្យគ្រូបង្រៀនទាំងអស់ មានឥរិយាបថវិជ្ជមាន មានមនសិការវិជ្ជាជីវៈខ្ពស់ និងមានសីលធម៌ល្អ។ បង្កលក្ខណៈឱ្យសិស្សបានបន្តការសិក្សាប្រកបដោយសមធម៌ តាមរយៈការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សក្រីក្ររៀនពូកែ ជាពិសេសការយកចិត្តទុកដាក់ដល់

សិស្សកំព្រា សិស្សពិការ សិស្សជនជាតិភាគតិច សិស្សស្រី និងសិស្សស្ថិតក្នុងគ្រួសារមានវិបត្តិ ។ ពង្រឹងការចូលរួមអភិវឌ្ឍវិស័យអប់រំ និងការគ្រប់គ្រងរាល់សកម្មភាពក្នុងនិងក្រៅសាលារៀនរបស់សិស្ស ពីសំណាក់សហគមន៍ មាតាបិតា អ្នកអាណាព្យាបាលសិស្ស សំដៅដល់រាល់ការ អនុវត្តការងារមានស្វ័យភាព និងគណនេយ្យភាព។ ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានា និងសហគមន៍ ក្នុងគោលបំណងធានានិរន្តភាពសាលាមធ្យមសិក្សាធនធាន និងធ្វើឱ្យកាន់តែប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ(ក្រសួងអប់រំ២០១៨)។

ដោយមើលឃើញនូវសារប្រយោជន៍ដ៏វិសេសវិសាលនៃអគារធនធាន ក៏ដូចជាសាលាមធ្យមសិក្សាធនធានដែរ ហើយកន្លងមកមិនទាន់មានការសិក្សាណាមួយទៅលើស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា និយាយជារួម និងនិយាយដោយឡែកគឺការប្រើប្រាស់អគារធនធាននៅខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែងនៅឡើយទេ ។ ដោយយោងទៅតាមពេលវេលា អ្នកសិក្សាយល់ថា ការសិក្សាស្រាវជ្រាវពីស្ថានភាពនៃការប្រើប្រាស់អគារធនធានទាំងនេះ វាមានទំហំធំពេក ហេតុដូច្នេះហើយ អ្នកសិក្សាសម្រេចយកធ្វើការសិក្សាតែស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្រ នៅក្នុងអគារធនធាននៃសាលាសិក្សាមធ្យមសិក្សាធនធានតែប៉ុណ្ណោះ ហើយជ្រើសរើសយកសាលាមធ្យមសិក្សាធនធានដែលមានតែនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែងទេ។ អ្នកសិក្សាពិនិត្យឃើញថា បន្ទប់ពិសោធវិទ្យាសាស្ត្រ មានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀននិងបង្រៀន ពីព្រោះវាជួយឱ្យសិស្សយល់កាន់តែច្បាស់ពីទ្រឹស្តី និងបញ្ញត្តិផ្សេងៗក្នុងផ្នែកវិទ្យាសាស្ត្រ (Reinders Duit & Maike Tesch,2010)។ មួយវិញទៀតដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរ ក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ គឺចាំបាច់ណាស់ តម្រូវឱ្យ គ្រូបង្រៀននិងសិស្សធ្វើពិសោធ ដែលហៅថា"Learning by doing" (McComas,W.F.,1998)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ទាក់ទងទៅនឹងប្រធានបទអំពី ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា ដោយពេលវេលាមានកំណត់ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកតែ ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន នៃសាលាមធ្យមសិក្សធនធាន ហើយជ្រើសរើសយកតែសាលាមធ្យមសិក្សាធនធានដែលមាននៅក្នុងខេត្តចំនួន៣ប៉ុណ្ណោះ គឺខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង។ការស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

១.រកឲ្យឃើញនូវស្ថានភាព នៃការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន ដែលកំពុងដំណើរការ នៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង។

២.រកឱ្យឃើញនូវបញ្ហាប្រឈមនានា នៃការប្រើប្រាស់បន្ទប់ពិសោធន៍ របស់អគារធនធាននៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង។

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងខាងលើ អ្នកស្រាវជ្រាវត្រូវដោះស្រាយលើសំណួរចំនួនពីរគឺ៖

១.តើការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន នៃសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងព្រៃវែង មានប្រសិទ្ធភាពយ៉ាងដូចម្តេច?

២.តើការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន នៃសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងព្រៃវែង ជួបនូវបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥ សម្មតិកម្ម

- លោកនាយក/នាយិកា-លោកនាយករង/នាយិការង មានគំនិតវិជ្ជមានក្នុងការគ្រប់គ្រងដឹកនាំនៃដំណើរការអគារធនធាន ប៉ុន្តែមិនទាន់ប្រើប្រាស់អស់លទ្ធភាព
- លោកគ្រូ-អ្នកគ្រូ មុខវិជ្ជាឯកទេស រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាគច្រើនបង្រៀនមេរៀនតែនៅក្នុងថ្នាក់រៀន មិនសូវមានពេលចូលក្នុងបន្ទប់ពិសោធ
- បរិវច្ឆការីបន្ទប់ពិសោធនៅមានកម្រិត ក្នុងការប្រើប្រាស់ឧបករណ៍ពិសោធ និងថែរក្សា
- បន្ទប់ពិសោធតូចចង្អៀត ខ្វះតុអង្គុយសម្រាប់សិស្ស(ក្នុង១ថ្នាក់សិស្សប្រហែល៥០នាក់)
- បន្ទប់ពិសោធមួយមានពីរមុខវិជ្ជាវិទ្យាសាស្ត្រ ពិបាកក្នុងការទុកដាក់សម្ភារៈ

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ"ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធនៃអគាធនធាននៅកម្ពុជា" គឺដើម្បីគាំទ្រដល់គោលនយោបាយ ស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី០៩ ខែ មីនា ឆ្នាំ ២០១៦។ ទន្ទឹមនឹងគ្នានេះដែរ ការសិក្សាស្រាវជ្រាវនេះនឹងជួយគាំទ្រដល់សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ៣១៤២ អយក.មចទ ចុះថ្ងៃ អង្គារ ១៤រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨ ស្តីពី" ឯកសារស្តង់ដាសាលាមធ្យមសិក្សាធនធាន"។ ម្យ៉ាងវិញទៀតប្រធានបទនេះនៅមានសារៈសំខាន់មួយទៀត គឺលទ្ធផលនៃការស្រាវជ្រាវនេះនឹងជួយតម្រង់ទិស ក្នុងការប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្រដែលមាននៅ

ក្នុងអគារធនធាននៃសាលាមធ្យមសិក្សាធនធាន។ មួយចំណែកទៀត លទ្ធផលនៃការស្រាវជ្រាវនេះ នឹងជួយជំរុញនៃការប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្រដែលមាននៅក្នុងអគារធនធាន នៃសាលាមធ្យមសិក្សាធនធានឱ្យអស់លទ្ធភាព ហើយជាចុងក្រោយ គឺជាឯកសារសម្រាប់ជំនួយស្មារតីដល់អ្នកសិក្សាក្នុងការសិក្សារៀនសូត្រ និងការសិក្សាស្រាវជ្រាវផ្សេងៗផងដែរ។

## ១.៧ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ខ្លឹមសារក្នុងការសិក្សាស្រាវជ្រាវនៃប្រធានបទ“ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅក្នុងប្រទេសកម្ពុជា” ដោយសារតែវិសាលភាពនៃប្រធានបទនេះវាមានទំហំធំពេក អ្នកស្រាវជ្រាវសូមកំណត់យកដែនកំណត់ ត្រឹមតែស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្រដែលមាននៅក្នុងអគារធនធាននៃសាលាមធ្យមសិក្សាធនធាន ដែលមាននៅក្នុងខេត្តត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្ត ព្រៃវែង។ ការសិក្សាស្រាវជ្រាវនេះនឹងធ្វើឡើងនៅសាលាមធ្យមសិក្សាធនធានចំនួន៤ក្នុងខេត្ត៣ គឺខេត្ត ត្បូងឃ្មុំ មានអគារធនធាន១ ខេត្ត កំពង់ចាម មានអគារធនធាន១ និងខេត្ត ព្រៃវែងមានអគារធនធានចំនួន២។ ក្នុងនោះធាតុសំណាកគឺ អ្នកស្រាវជ្រាវជ្រើសរើសយកតែ លោកនាយក/នាយករងបច្ចេកទេស បរិវច្ឆការីបន្ទប់ពិសោធនិងលោកគ្រូ-អ្នកគ្រូដែលបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ដែលធាតុសំណាកទាំងអស់សរុប៦៨នាក់។

### ១.៧.១ ខ្លឹមសារនៃការស្រាវជ្រាវ

ខ្លឹមសារនៃការស្រាវជ្រាវនេះ គឺផ្តោតទាំងស្រុងទៅលើការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រដែលមាននៅក្នុងអគារធនធាននៃសាលាមធ្យមសិក្សាធនធាន ដែលស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងព្រៃវែង ហើយដែលយកជាឧបករណ៍សម្រាប់ស្រាវជ្រាវគឺ៖

១.នាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធ នៃសាលាមធ្យមសិក្សាធនធាន។

២.គ្រូឯកទេសមុខវិជ្ជាវិទ្យាសាស្ត្រ(រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា)នៃសាលាមធ្យមសិក្សាធនធាន។

### ១.៧.២ ទីតាំងនិងពេលវេលា

ការស្រាវជ្រាវនេះ ចាប់ពីថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដល់ង៥ថ្ងៃទី២៥ ខែ មករា ឆ្នាំ ២០២០ សម្រាប់តែសាលាមធ្យមសិក្សាធនធាន ដែលមាននៅក្នុងខេត្ត ត្បូងឃ្មុំ កំពង់ចាម និងព្រៃវែង។

## ១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១៖** សេចក្តីផ្តើមរួមមាន សារតានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សម្មតិកម្ម សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំឭកទ្រឹស្តី បង្ហាញពីនិយមន័យ របស់ពាក្យនិងឃ្លា ״ស្ថានភាពនៃការប្រើប្រាស់អគារធនធាន״ និងបង្ហាញពីឯកសារយោង ដែលមានខ្លឹមសារទាក់ទងនឹងអគារធនធាន ដើម្បីស្វែងយល់ពីការប្រើប្រាស់អគារធនធាន ក៏ដូចជាសាលាមធ្យមសិក្សាធនធាន។

**ជំពូកទី៣៖** រៀបរាប់អំពី វិធីសាស្ត្រស្រាវជ្រាវដែលអ្នកសិក្សាស្រាវជ្រាវ បានយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវ បង្ហាញពីរបៀបនៃការសិក្សា ការប្រមូលសំណាក ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**ជំពូកទី៤៖** លទ្ធផលនិងការបកស្រាយក្នុងផ្នែកនេះ អ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែងដែលខ្លួនបានធ្វើការសិក្សាស្រាវជ្រាវរួចហើយគឺត្រូវឆ្លើយតបទៅនឹង ចំណុចដែលចោទ សួរនៅក្នុង ចំណោទបញ្ហា។ ការបកស្រាយត្រូវបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្តីឬខ្លឹមសារដែលមានក្នុងកម្រងសំណួរ ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាននិងសំណូមពរ ជំពូកនេះអ្នកស្រាវជ្រាវត្រូវ ធ្វើការសង្ខេបការសិក្សាស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ឬសំណូមពរទៅ លើចំណុចដែលត្រូវកែលម្អ ។

# ជំពូកទី២

# រំឭកទ្រឹស្តី

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

គោលនយោបាយវិស័យអប់រំ បានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP) ២០០៦-១០ និងកម្មវិធីគាំទ្រវិស័យអប់រំ(ESSP)២០០៦-១០ មានមូលដ្ឋានមកពីយុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ បានចែងពី ចក្ខុវិស័យ បេសកកម្ម និងគោលនយោបាយសំខាន់ៗរបស់ក្រសួង អប់រំ យុវជន និងកីឡា។ ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក និងដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាៈដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក (ក្រសួងអប់រំ ២០០០៨)។

ដោយយោងទៅតាមគោលការណ៍ខាងលើនេះហើយ ទើបមានប្រកាសស្តីពីការបង្កើតអគារធនធាន លេខ៣២៧៧ អយក.ប្រក ចុះថ្ងៃទី៤ខែ ធ្នូ ឆ្នាំ២០១០ បានអគារធនធានចំនួន១៨ស្ថិតក្នុងវិទ្យាល័យ១៨ ដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេងៗគ្នា។ ក្រោយមកទៀតមានប្រកាសស្តីពីការបង្កើតអគារធនធាន លេខ ២៥៩០ អយក.ប្រក ចុះថ្ងៃទី២២ខែ វិច្ឆិកាឆ្នាំ២០១១ បានអគារធនធានចំនួន៨ ដែលស្ថិតនៅក្នុង វិទ្យាល័យ និងខេត្ត ក្រុងផ្សេងៗគ្នាដែរ។ រយៈពេល២ឆ្នាំក្រោយទៀតមក មានប្រកាសស្តីពីការបង្កើតអគារធនធាន លេខ ៦០៣ អយក.ប្រក ចុះថ្ងៃទី២២ខែ កុម្ភៈឆ្នាំ២០១៣ បានអគារធនធានចំនួន៣។ មួយឆ្នាំក្រោយមកទៀតមានប្រកាសស្តីពីការបង្កើតអគារធនធាន លេខ៣១០១០ អយក.ប្រក ចុះថ្ងៃទី២ខែ ឧសភាឆ្នាំ២០១៤ បានអគារធនធានចំនួន៧។ មកដល់បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា មានអគារធនធានចំនួន ៣៦ ដែលស្ថិតនៅក្នុងវិទ្យាល័យមធ្យមសិក្សាធនធានទាំង៣៦ និងមានសាលាបណ្តាញចំនួន៧៥។ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី១

(USESDP1) បានសាងសង់អគារធនធានចំនួន១៤ទៀត ដែលគ្រោងនឹងបញ្ចប់ការសាងសង់នៅត្រីមាសទី១ នៃឆ្នាំ២០២០នេះ ជារួមយើងនឹងមានសាលាមធ្យមសិក្សាធនធានចំនួន៥០។

## ២.២ និយមន័យ

ពាក្យគន្លឹះនៅក្នុងប្រធានបទទាំងមូលមាន"ស្ថានភាព,ការប្រើប្រាស់,បន្ទប់ពិសោធ"និង"អគារធនធាន"។ តាមវចនានុក្រមរបស់សម្តេច ជួន ណាត ពាក្យថា"ស្ថានភាព"មានន័យថាទីតាំងនៅពិតប្រាកដ ដំណើរទំនង បែបបទ ដំណើរការណ៍ដែលប្រព្រឹត្តទៅ។ ឯពាក្យថា "ការប្រើប្រាស់" មានពាក្យបីព្យាង្គរួមជាមួយគ្នា គឺពាក្យថា"ការ"(ន)=ពាក្យសម្រាប់ប្រើដាក់នៅខាងដើមពាក្យដែលជាកិរិយាសព្ទ ដើម្បីធ្វើឱ្យ ទៅជានាមសព្ទ។ ប្រើប្រាស់=ប្រើ+ប្រាស់ ,ប្រើ(កិ)=បង្គាប់បង្គាប់ឱ្យធ្វើតាម ប្រកបកិច្ចការតាមតម្រូវការ ប្រាស់(ប)=ពាក្យសម្រាប់ប្រើផ្សំជាមួយនិងពាក្យប្រើថា៖ប្រើប្រាស់។ ចំពោះពាក្យថា"បន្ទប់ពិសោធ"មកពីពាក្យ"បន្ទប់"+"ពិសោធន៍" ,បន្ទប់(ន)=ទីកន្លែងមានជញ្ជាំងបិទជិត សម្រាប់សម្រាក ដឹក ឬធ្វើការអ្វីៗ,ពិសោធន៍(ន)=ការសាកល្បងមើល,ដំណើរពិនិត្យ ឬសាកមើលឱ្យឃើញពិត។ ចំណែកឯពាក្យថា"អគារធនធាន"មកពីពាក្យ"អគារ"+"ធនធាន" ។"អគារ" (សំស្ក្រឹត)(បាលី)= មន្ទីរ ផ្ទះ រោង ។"ធនធាន"=ធន(បាលី)(សំស្ក្រឹត)ទ្រព្យ សម្បត្តិ,+ ធាន មានន័យថាទ្រព្យរបស់ផ្សេងៗដែលគង់នៅ។ ដូចនេះ "អគារធនធាន"មានន័យថាគឺជាមន្ទីរ រោងឬសាលាដែលមានទ្រព្យគង់នៅ,សាលារៀនដែលមានទ្រព្យសម្បត្តិស្ថិតនៅ។ សរុបសេចក្តីមកពាក្យថា"ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាននៅកម្ពុជា" មានន័យថា ដំណើរ ទំនង បែបបទ ដំណើរការណ៍ដែលប្រព្រឹត្តទៅនៃការបង្គាប់ឱ្យធ្វើតាមនៅទីកន្លែងដែលមានជញ្ជាំងបិតជិត ដើម្បីសាកល្បងមើលឱ្យឃើញការពិត របស់មន្ទីរ ផ្ទះ រោងឬសាលាដែលមានទ្រព្យគង់នៅ។ បើយើងនិយាយឱ្យស្រួលស្តាប់ គឺមានន័យថា ដំណើរការណ៍ប្រព្រឹត្តទៅដែលបង្គាប់ឱ្យធ្វើតាមក្នុងកន្លែងដែលមានជញ្ជាំងបិទជិត ដើម្បីសាកល្បងមើលឱ្យឃើញការពិតនៃសាលារៀនដែលមានទ្រព្យគង់នៅ។

តាមគោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៨ បានកំណត់ថា"សាលាមធ្យមសិក្សាធនធាន គឺជាសាលាដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្ត(អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើង...) និងបណ្តុះបណ្តាលការប្រើប្រាស់សម្ភាររូបវន្តទាំងនោះ។ សាលាមធ្យមសិក្សាធនធាននឹងចែករំលែកបទពិសោធ ក្នុងការប្រើប្រាស់ធនធានទាំងនោះ ដល់សាលារៀនក្នុងបណ្តាញ" នេះនិយាយជារួម។ និយាយដោយឡែក តាមឯកសារស្តង់ដាសាលាមធ្យមសិក្សាធនធាន លេខ៣១៤២ អយក.មចទ ចុះថ្ងៃ អង្គារ ១៤រោច

ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនិងថ្ងៃទី១២ខែ មិថុនា ឆ្នាំ ២០១៨ បានកណត់ថា "អគារធនធាន" គឺជាអគារដែលមាន សាលប្រជុំ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បន្ទប់នាយក-នាយករង បន្ទប់លេខាធិការ បន្ទប់សម្រាប់គ្រូរៀបចំមេរៀន បន្ទប់រៀបអាហារសម្រន់ មានបង្គន់អនាម័យនិងបន្ទប់ទឹកសម្រាប់នារី ឃ្លាំងសម្រាប់ដាក់សម្ភារៈ មានបណ្ដាញទឹក បណ្ដាញភ្លើង។ ដូចនេះ"ស្ថានភាពនៃការប្រើប្រាស់អគារធនធាន"មានន័យថាដំណើរការណ៍ប្រព្រឹត្តទៅដែលបង្គាប់ឱ្យធ្វើតាមនៃអគារដែលមានសាលប្រជុំ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បន្ទប់នាយក-នាយករង បន្ទប់លេខាធិការ បន្ទប់សម្រាប់គ្រូរៀបចំមេរៀន បន្ទប់រៀបអាហារសម្រន់ មានបង្គន់អនាម័យនិងបន្ទប់ទឹកសម្រាប់នារី ឃ្លាំងសម្រាប់ដាក់សម្ភារៈ មានបណ្ដាញទឹក បណ្ដាញភ្លើង។

## ២. ៣ ឯកសារ-ទ្រឹស្ដីពាក់ព័ន្ធ

នៅក្នុងការសិក្សាស្រាវជ្រាវអំពីប្រធានបទ «ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា» រួមមានទ្រឹស្ដីពាក់ព័ន្ធមួយចំនួនដូចជា ច្បាប់រដ្ឋធម្មនុញ្ញ ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ គោលនយោបាយស្ដីពីសាលាមធ្យមសិក្សាធនធាន សៀវភៅណែនាំប្រតិបត្តិសាលាមធ្យមសិក្សាធនធាន ឯកសារស្ដង់ដាសាលាមធ្យមសិក្សាធនធាន គោលនយោបាយស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា សមិទ្ធិការអនុវត្តគោលនយោបាយស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម) ស្ថិតិ និងសូចនាករអប់រំសាធារណៈ(២០១៨-២០១៩) សេចក្ដីប្រកាសព័ត៌មានស្ដីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

### ២.៣.១.គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន

សាលាមធ្យមសិក្សាធនធាននឹងផ្ដល់ដល់ក្រសួងអប់រំ យុវជន និងកីឡា ធុរជន និងរាជរដ្ឋាភិបាលនូវឱកាសសម្រាប់ធ្វើការមួយគ្នា ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធមួយ ដែលផ្ដល់ជាផែនការលម្អិតសម្រាប់ភាពល្អប្រសើរក្នុងការងារអប់រំ ដោយផ្ដោតជាពិសេសលើការអនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី។

សាលាមធ្យមសិក្សាធនធានជានិមិត្តរូបនៃគំរូប្រតិបត្តិនិងកម្មវិធីសកម្មភាពល្អប្រសើរសម្រាប់សាលាមធ្យមសិក្សាដទៃយកទៅអនុវត្ត ដើម្បីសម្រេចបានលទ្ធផលអប់រំ។

សាលាមធ្យមសិក្សាធនធានប្ដេជ្ញាចែករំលែកបទពិសោធ ដែលពួកគេមាន ព្រមទាំងធ្វើការជាមួយនឹងសហាគមន៍អប់រំទូលំទូលាយ ដើម្បីបន្តអភិវឌ្ឍការបង្រៀននិងរៀន ធ្វើឱ្យសាលារៀនអភិវឌ្ឍជាបន្តបន្ទាប់។

**សាលាមធ្យមសិក្សាធនធានអាចជា៖**

-សាលារៀនមានស្រាប់ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់

-សាលារៀនមានស្រាប់តែពុំទាន់មានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ហើយត្រូវបានគាំទ្រដើម្បីអភិវឌ្ឍសាលារៀននោះ ឱ្យបំពេញបានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់(រយៈពេលប៉ាន់ស្មានប្រហែលជា៣ឆ្នាំ)លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាននឹងមាននៅក្នុងការណែនាំមួយ

**សាលាមធ្យមសិក្សាធនធាននឹង៖**

-ផ្ដល់ការដឹកនាំ និងតម្រង់ទិសក្នុងការជួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ។

-ប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនដែលល្អ ដើម្បីគាំទ្រគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាថ្មី។

-ក្លាយជា(ឬក្នុងអំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា) មជ្ឈមណ្ឌលឧត្ដមភាពនៃការបង្រៀន និងរៀន។

-ក្លាយជា(ឬក្នុងអំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា) មជ្ឈមណ្ឌលឧត្ដមភាពមួយនៃការប្រតិបត្តិអប់រំ និងគំរូនៃលទ្ធផលសិក្សាដែលអាចផ្សព្វផ្សាយបន្តទៅសាលារៀនដទៃទៀត។

-បង្ហាញថាគ្រប់ផ្នែកទាំងអស់នៃដំណើរការសាលារៀន និងទំនាក់ទំនងសាលារៀន-សហគមន៍ មានការអភិវឌ្ឍទៅមុខ ដោយយកការអភិវឌ្ឍគុណភាពសាលារៀនធ្វើជាមូលដ្ឋាន

-សរសេរចងក្រងឯកសារ ចែករំលែកឯកសារ និងបង្ហាញបទពិសោធរបស់ពួកគេដែលមានក្នុងការផ្ដើមគំនិតអនុវត្តកម្មវិធីសិក្សាថ្មី ព្រមទាំងជួយសាលារៀនដទៃទៀតឱ្យចេះតាក់តែង និងអនុវត្តការផ្លាស់ប្ដូរ ក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគេ។

-ចែករំលែកបទពិសោធនៃការអភិវឌ្ឍធនធានមនុស្ស និងធនធានសម្ភារៈជាមួយសាលារៀនដទៃទៀត។

-ខិតខំឱ្យស្មើនឹងសាលារៀនដែលមានប្រតិបត្តិនិងលទ្ធផលលេចធ្លោរបស់ប្រទេសមួយចំនួនក្នុងតំបន់។

-ត្រូវបានសាងសង់ថ្មីនិង /ឬជួសជុលដោយផ្អែកទៅតាមលក្ខខណ្ឌមូលដ្ឋាននិងផ្តល់នូវរូបវន្តពិសេស ដូចជាបណ្ណាល័យ បន្ទប់ពិសោធវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)។

-ទទួលមូលនិធិគ្រប់គ្រាន់ពីគ្រប់អ្នកពាក់ព័ន្ធ និងពីគ្រប់មជ្ឈដ្ឋាន។

-ទទួលមូលនិធិគ្រប់គ្រាន់ ដើម្បីឱ្យសាលារៀនអាចមានបរិក្ខារសំខាន់ៗ ដូចជាសៀវភៅសិក្សា បរិក្ខារបន្ទប់ពិសោធ កញ្ចប់សម្ភារៈ (Kit) និងកុំព្យូទ័រដែលមានកម្មវិធីផ្នែកទន់ថ្មីៗ និងកម្មវិធីប្រឆាំងនិងមេរោគដែលមានអាជ្ញាប័ណ្ណអាចធ្វើឱ្យការប្រើប្រាស់មានប្រសិទ្ធភាព និងធ្វើឱ្យ មានបច្ចុប្បន្នភាពនូវកម្មវិធីមួយចំនួន។

-ត្រូវបានផ្តល់អាហារូបករណ៍ ដើម្បីជួយសិស្សឱ្យសម្រេចបានការសិក្សាខ្ពស់តាមរយៈអាហារូបករណ៍ ២ប្រភេទគឺ:

១.អាហារូបករណ៍ចំពោះសិស្សពូកែ

២.អាហារូបករណ៍ចំពោះសិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

## ២.៣.២.ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន

ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន

២.១.ចំពោះសិស្ស

-មានឱកាសទទួលយកការបង្រៀន និងរៀនដែលមានគុណភាពខ្ពស់

-មានឱកាសសម្រេចបានលទ្ធផលសិក្សាល្អប្រសើរសម្រាប់សិស្សពូកែភាគច្រើន

-ទទួលបានគោលនយោបាយជួយសិស្សក្រីក្រ និងផ្តល់អាហារូបករណ៍ ចំពោះសិស្សពូកែ សិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

២.២.ចំពោះបុគ្គលិកអប់រំ

-មាននាយក នាយករងសាលារៀនដឹកនាំប្រកបដោយគុណភាពល្អ និងកោសល្យខ្ពស់ក្នុងមុខវិជ្ជាជីវៈ។

-ទទួលបានរបៀបរៀន និងបន្តរៀនពេញមួយជីវិតជាគម្រូសម្រាប់សិស្សយកទៅប្រតិបត្តិតាម។

-ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ និងមានឱកាសបង្កើនបំណិនបង្រៀនតាមមុខវិជ្ជាឯកទេសប្រកបដោយភាពល្អប្រសើរ។

-ទទួលបានការពណ៌នាពីមុខតំណែង(Job Description) (លក្ខណៈសម្បត្តិ បទពិសោធ គុណសម្បត្តិបុគ្គល និងលក្ខណៈដទៃទៀត) ច្បាស់លាស់សម្រាប់គ្រប់តួនាទីបង្រៀនទាំងអស់

ព្រមទាំងតម្រូវការបំពេញការងារដទៃទៀតឱ្យស័ក្តិសមជាសាលាមួយដែលមានបុគ្គលិកអប់រំប្រកបដោយស្តង់ដាខ្ពស់។

-ចូលរួមអភិវឌ្ឍកម្មវិធីវាយតម្លៃការបំពេញការងារមួយ ដោយប្រើប្រាស់អាំងឌីកាទ័រស្វ័យវាយតម្លៃការប្រតិបត្តិលើផ្នែកខ្លះដូចជា ខ្លឹមសារមុខវិជ្ជា និងវិធីសាស្រ្តបង្រៀន-រៀន។

២.៣.ចំពោះមាតាបិតា និងអាណាព្យាបាលសិស្ស

-មានមោទនភាពដោយសារកូនចៅគាត់ទទួលបានឱកាសអប់រំដ៏ល្អបំផុត មានការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងហិរញ្ញវត្ថុមានតម្លាភាព ដោយមានការចូលរួមពីមាតាបិតាអាណាព្យាបាលសិស្ស និងសហគមន៍។

-ទទួលបានព័ត៌មានត្រឡប់ជាប្រចាំ ពីការអភិវឌ្ឍរបស់កូនចៅគាត់។

-ត្រូវបានគាត់មើលឃើញថាសាលារៀនជាមជ្ឈមណ្ឌលមួយនៃ " សហគមន៍សិក្សា" (ការសិក្សាទៅវិញទៅមក រវាងសិស្ស គ្រូ និងសហគមន៍)។

២.៤.ចំពោះសាលារៀន

-ទទួលយក និងគាំទ្រការផ្តួចផ្តើមកម្មវិធីសិក្សាដែលបង្កើតឡើងដោយសិស្សនិងគ្រូបង្រៀន ព្រមទាំងគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅទៅរកការសិក្សាពេញមួយជីវិត និងការសិក្សាប្រកប ដោយភាពបត់បែន ទន់ភ្លន់រស់រវើក។

-ត្រូវបានទទួលស្គាល់ជាសាលារៀនមួយឈានមុខ (ក្នុងការដឹកនាំអនុវត្តគ្រប់ផ្នែក)ដែលផ្តល់ការបង្រៀននិងរៀនប្រកបដោយគុណភាពក្នុងស្រុក/ខណ្ឌ ខេត្ត/ក្រុង និងក្នុងប្រទេស។

-ត្រូវបានបំពាក់សម្ភាររូបវន្ត ប្រកបដោយគុណភាព និងបំប៉នបុគ្គលិកឱ្យមានសមត្ថភាព ពេញលេញ ដើម្បីសម្រេចបានវត្ថុបំណងសាលាមធ្យមសិក្សាធនធាន។

-ក្លាយជា(ក្នុងរយៈពេលជាក់លាក់ណាមួយ) មជ្ឈមណ្ឌលមួយមានលទផលសិក្សាល្អប្រសើរ និងមានការទទួលស្គាល់ដោយផ្អែកលើគោលការណ៍សាលារៀនមានប្រសិទ្ធភាព។

-កំណត់ចំណុចដៅជាក់លាក់(ផ្អែកលើលក្ខខណ្ឌមូលដ្ឋាន) ដើម្បីបង្កើនចំនួនសិស្សប្រចាំឆ្នាំ ដែលមានប្រភពមកពីតំបន់ជនបទដាច់ស្រយាល សិស្សក្រីក្រ និងសិស្សជនជាតិភាគតិច។

-កំណត់ចំណុចដៅជាក់លាក់(ផ្អែកលើលក្ខខណ្ឌមូលដ្ឋាន) ដើម្បីបង្កើនភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំសិក្សា រួមទាំងសិស្សស្រី សិស្សមកពីតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល សិស្សក្រីក្រ និងសិស្សជនជាតិភាគតិច។

២.៥.ចំពោះសាលារៀនក្នុងបណ្ដាញ

-មានការប្រតិបត្តិបង្រៀននិងរៀនល្អបំផុតដែលបង្ហាញឡើងតាមរយៈការអនុវត្តកម្មវិធីសិក្សាថ្មី។

-អាចរៀនសូត្រយកធ្វើជាគំរូក្នុងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការរៀន ការដឹកនាំគ្រប់គ្រងសាលារៀន។

-អនុវត្តការងារតាមបែបសហប្រតិបត្តិការមួយ ស្របតាមចក្ខុវិស័យ និងបេសកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយធំទាំង៣ គឺសមធម៌ក្នុងការចូលរៀន គុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការកសាងសមត្ថភាពដើម្បីឈានទៅរបបការងារបែបរិមជ្ឈការ។

-អភិវឌ្ឍសាលារៀនឱ្យក្លាយជាមជ្ឈមណ្ឌលនៃឧត្តមភាពអប់រំ ដោយយកការបង្រៀននិងរៀនជាមូលដ្ឋាន។

-អភិវឌ្ឍសាលារៀនឱ្យក្លាយជាមជ្ឈមណ្ឌល នៃការប្រតិបត្តិគម្រូសម្រេចលទ្ធផលខ្ពស់ អាចផ្សព្វផ្សាយបទពិសោធទៅសាលារៀនដទៃទៀត។

-ផ្ដល់ឱកាសសម្រាប់ការទទួលស្គាល់ការរៀនពូកែ និងមានគោលនយោបាយគាំទ្រចំពោះសិស្សក្រីក្រ សិស្សស្រី សិស្សមកពីតំបន់ជួបការលំបាក និងសិស្សជនជាតិភាគតិច។

## ២.៣.៣.លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន

១.សាលារៀនមានទីតាំងក្នុងទីប្រជុំជនខេត្ត-ក្រុង ស្រុក-ខណ្ឌ

២.សាលាមានការគ្រប់គ្រង និងសហការល្អជាមួយសហគមន៍

៣.សាលារៀនមានទីតាំងធំទូលាយ ងាយស្រួលក្នុងការសាងសង់អគារបន្ថែមនៅពេលអនាគត

៤.សាលារៀនមានសុវត្ថិភាព និងសន្តិសុខ ធានាការពារបានរាល់វត្ថុមានតម្លៃក្នុងសាលា

៥.សាលារៀនមានប្រភពថាមពលអគ្គិសនី និងទឹកស្អាតសម្រាប់បម្រើឱ្យបន្ទប់ពិសោធនិងកុំព្យូទ័រ

## ២.៣.៤.ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

កម្រិតអប្បបរមា នៃសម្ភាររូបវ័ន្តសម្រាប់សាលាមធ្យមសិក្សាធនធានគឺ៖

- មានការិយាល័យសម្រាប់នាយក នាយករងសាលារៀន និងលេខាធិការ
- មានសាលប្រជុំ សាលគ្រូបង្រៀន បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ ឃ្លាំងសម្រាប់ដាក់សម្ភារៈ និងបន្ទប់សម្រាប់គ្រូរៀបចំមេរៀន
- មានបណ្ណាល័យ
- មានអាហារដ្ឋាន ឬបន្ទប់រៀបអាហារសម្រន់

➢ មានបង្គន់អនាម័យ និងបន្ទប់ទឹកនារីគ្រប់គ្រាន់

## ២.៣.៥.បណ្តាញសាលាមធ្យមសិក្សាធនធាន

៥.១.បណ្តាញសាលាមធ្យមសិក្សាធនធាន

យុទ្ធសាស្ត្របណ្តាញសាលាមធ្យមសិក្សាធនធាន រួមមានការបណ្តុះវប្បធម៌ធ្វើការងារជាមួយគ្នា ដកពិសោធការងារពីគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នា រវាងសាលារៀននានា និងសាលារៀនក្នុងបណ្តាញព្រមទាំងសហគមន៍ទូលំទូលាយ។

សាលាមធ្យមសិក្សាទាំងអស់នឹងស្ថិតក្នុងបណ្តាញនៃសាលាមធ្យមសិក្សាធនធានដែលមានកិច្ចសហការគ្នាមួយយ៉ាងជិតស្និទ្ធ។សាលាមធ្យមសិក្សាធនធានជាស្នូលរបស់បណ្តាញ។ សាលាមធ្យមសិក្សាធនធាននឹងត្រូវបានផ្តល់អគារ និងសម្ភារបរិក្ខារបន្ថែម ដើម្បីជំរុញសហប្រតិបត្តិការរវាងសាលារៀននៅក្នុងបណ្តាញ និងផ្តល់ភាពជាអ្នកដឹកនាំក្នុងផ្នែកអភិវឌ្ឍកម្មវិធីសិក្សា។

៥.២.វត្ថុបំណងរបស់បណ្តាញសាលាមធ្យមសិក្សាធនធាន

- ➢ បង្កើនឱកាស និងលទ្ធផលអប់រំ ចំពោះសិស្សនៅក្នុងតំបន់របស់បណ្តាញ
- ➢ ជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- ➢ លើកកម្ពស់ស្មារតីចែករំលែកបទពិសោធនៃការរៀន និងបង្រៀន
- ➢ ពង្រឹងការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលារៀន
- ➢ ណែនាំកសាងផែនការដែលនាំឱ្យសាលារៀនមានការរីកចម្រើន
- ➢ អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន តាមរយៈការណែនាំផ្ទាល់និងការអភិវឌ្ឍវិជ្ជាជីវៈ
- ➢ ប្រែក្លាយសាលាមធ្យមសិក្សាធនធានទៅជាសមាសភាគដ៏រឹងមាំមួយ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើឱ្យមានអភិវឌ្ឍនៅមធ្យមសិក្សា។

៥.៣.បណ្តាញសាលាមធ្យមសិក្សាធនធាននឹងៈ

- ➢ ប្រើធនធានសម្រាប់បណ្តាញដើម្បីលើកទឹកចិត្តនិងជួយគាំទ្រដល់ការបង្កើតថ្មី
- ➢ កសាងទំនុកចិត្តដល់នាយកសាលារៀន និងគ្រូបង្រៀនក្នុងការគាំទ្រដល់ការធ្វើឱ្យមានការផ្លាស់ប្តូរ និងការបង្កើតថ្មី
- ➢ ស្វែងរកភាពជឿនលឿនបំផុតដើម្បីឈានដល់ឧត្តមភាព គាំទ្រយ៉ាងសកម្មដល់ការបង្រៀន ការដឹកនាំក្រុមសិក្សា ការងារពិភាក្សា និងការស្រាវជ្រាវជាគម្រោង
- ➢ ធ្វើឱ្យលទ្ធផលការអប់រំរបស់សិស្សកើនឡើង

- កំណត់អាទិភាពគោលដៅបណ្ដាញរបស់ថ្នាក់ខេត្ត-ក្រុងនិងថ្នាក់ស្រុក-ខណ្ឌដើរស្រគ្នា
- ប្រើទិន្នន័យរបស់បណ្ដាញ ដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្វះខាតដែលត្រូវកែលម្អ
- រាយការណ៍ពីប្រសិទ្ធភាព នៃការប្រើប្រាស់ធនធាន
- ប្រើធនធានរបស់បណ្ដាញ ដើម្បីលើកទឹកចិត្តនិងជួយគាំទ្រដល់ការបង្កើតថ្មី តាមរយៈសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ
- សម្របសម្រួល និងផ្សព្វផ្សាយភាពជោគជ័យរបស់បណ្ដាញ
- កសាងភាពជាដៃគូដ៏ទូលាយជាមួយសហគមន៍ ដើម្បីជំរុញការសិក្សារបស់សិស្ស និងស្វែងរកមាគ៌ាសម្រាប់ការសិក្សា និងបម្រើការងារនៅអនាគត។
- រៀបចំពេលវេលាទៀងទាត់ក្នុងប្រព័ន្ធ ដើម្បីចែករំលែកបទពិសោធល្អៗ
- ទទួលស្គាល់សក្ដានុពលនៃគំនិតផ្ដួចផ្ដើម កម្មវិធីគម្រូនានាដោយជំរុញនិងគាំទ្រដល់ទង្វើទាំងនោះ
- កំណត់កន្លែងដែលមានតម្រូវការដូចគ្នា ដែលអាចទៅជាចំណុចដៅរួមនៃការប្រឹងប្រែងសម្រាប់ការរីកចម្រើន
- ជំរុញសាលារៀន ឱ្យសហការគ្នាចែករំលែកគំនិត និងផែនការ
- ប្រើប្រាស់ទិន្នន័យពីបណ្ដាញ ដើម្បីកំណត់តម្រូវការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលារៀន និងគ្រូបង្រៀន

៥.៤.គំនូសតាងបណ្ដាញសាលាមធ្យមសិក្សាធនធាន



## ២.៣.៦.យុទ្ធសាស្ត្រ

៦.១.ភារកិច្ចតាមស្ថាប័នអប់រំ

១.អង្គភាពថ្នាក់កណ្តាល(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ,នាយកដ្ឋានបណ្តុះបណ្តាល,នាយកដ្ឋានបុគ្គលិក,នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ,អធិការដ្ឋានអប់រំ...)

-ផ្សព្វផ្សាយគោលនយោបាយសាលាមធ្យមសិក្សាធនធានឱ្យបានទូលំទូលាយតាមគ្រប់រូបភាព

-រៀបចំការណែនាំនិងលិខិតបទដ្ឋាននានាទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន

-ទាក់ទងជាមួយដៃគូអភិវឌ្ឍ ដើម្បីរៀបចំផែនការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តដល់សាលាមធ្យមសិក្សាធនធាន

-ចុះពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន

-រៀបចំប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាធនធាន

**២.មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង**

-អភិវឌ្ឍផែនការសម្រាប់រៀបចំបណ្តាញសាលាមធ្យមសិក្សាធនធាន

-រៀបចំការណែនាំដល់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ

-ចុះពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន

-លើកសំណើទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)ដើម្បីសុំប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាធនធាន។

**៣.ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក-ខណ្ឌ**

-សម្របសម្រួលការងាររដ្ឋបាលរវាងសាលាមធ្យមសិក្សាធនធាន និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង។

**៤.នាយក នាយករងសាលាមធ្យមសិក្សាធនធាន**

-រៀបចំធ្វើផែនការអភិវឌ្ឍនិងអនុវត្តគោលនយោបាយសាលាមធ្យមសិក្សាធនធាន

-រៀបចំការប្រជុំសាលារៀនក្នុងបណ្តាញ

-ផ្សព្វផ្សាយគោលនយោបាយសាលាមធ្យមសិក្សាធនធានដល់អ្នកពាក់ព័ន្ធទាំងអស់

-អភិវឌ្ឍយុទ្ធសាស្ត្រមួយ ដើម្បីកសាងវប្បធម៌នៃការធ្វើការរួមគ្នារវាងបណ្តាសាលារៀន

-ផ្តល់យោបល់ និងចែករំលែកបទពិសោធលើការគ្រប់គ្រង ការរៀន និងបង្រៀននៅក្នុង បណ្តាញសាលារៀនរបស់ខ្លួន

-ធានាសុវត្ថិភាព សន្តិសុខ ថែទាំបានរាល់ទ្រព្យសម្បត្តិសាលារៀន។

៦.២.កំណត់សាលារៀនដែលជាបណ្តាញរបស់សាលាមធ្យមសិក្សាធនធាននីមួយៗ

៦.៣.រៀបចំលិខិតបទដ្ឋាន ដើម្បីផ្សព្វផ្សាយដល់សាលារៀនមធ្យមសិក្សាទាំងអស់

៦.៤.រៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់គ្រប់សាលាមធ្យមសិក្សាធនធាន ដែលបានជ្រើសរើស ដើម្បីកំណត់ពីតួនាទី ការទទួលខុសត្រូវ និងលទ្ធផលរំពឹងទុក។

៦.៥.គ្រោងសាងសង់អគារធនធាន

-សាងសង់ចាប់ផ្តើមពីខែ ធ្នូ ២០០៧ ដល់ខែ មិថុនា ២០០៨ ចំនួន៧អគារធនធាននៅ ៧ខេត្ត-ក្រុង

-សាងសង់ចាប់ផ្តើមពីខែ ឧសភា ២០០៨ ដល់ខែ ធ្នូ ២០០៨ ចំនួន៩អគារ ធនធាន នៅ ៩ខេត្ត-ក្រុង

-សាងសង់ចាប់ផ្តើមពីខែ ធ្នូ ២០០៨ ដល់ខែ មិថុនា ២០០៩ ចំនួន៨អគារ ធនធាន នៅ ៨ខេត្ត-ក្រុង

-តាមរយៈគម្រោងបង្កើនគុណភាពអប់រំ (EEQP) នឹងមានការកំណត់សាលាមធ្យមសិក្សាធនធានបន្ថែម ចំនួន ៣៦ទៀត។ ក្រសួងអប់រំ យុវជន និងកីឡា នឹងពិភាក្សាជាមួយគណៈកម្មការនាយកនៃគម្រោងបង្កើនគុណភាពអប់រំ(EEQP) លើកម្មវិធីសាងសង់ និងការរៀបចំថវិកា។

៦.៦.គ្រោងអភិវឌ្ឍសមត្ថភាព

-អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំនៅមធ្យមសិក្សា

-អភិវឌ្ឍសមត្ថភាពគ្រប់គ្រងរបស់នាយក នាយករងសាលាមធ្យមសិក្សា

-ជំរុញបណ្តាញសាលាមធ្យមសិក្សាធនធានដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ឱ្យទៅជាសាលាមធ្យមសិក្សាធនធាន។

## ២.៣.៧.ការគ្រប់គ្រង និងដំណើរការអគារធនធាន

### ១.ធនធានមនុស្ស

**ក.គណៈគ្រប់គ្រងអគារធនធាន**

ក.១.*សមាសភាព*

១.នាយក/នាយិកាវិទ្យាល័យ(ដែលមានអគារធនធានស្ថិតនៅ)　　　ប្រធាន

២.នាយករង/នាយិការងទទួលបន្ទុកបច្ចេកទេស អនុប្រធាន

៣.ក្រុមប្រឹក្សាបច្ចេកទេស សមាជិក

ក.២.***ភារកិច្ច***

សហការជាមួយគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ ព្រមទាំងគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ដំណើរការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ និងការសិក្សារបស់សិស្សានុសិស្សក្នុងវិទ្យាល័យ និងសាលាមធ្យមសិក្សាបណ្ដាញ។ សហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការទ្រទ្រង់សាលារៀន គណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ ក្នុងការស្វែងរក និងចាត់ចែងប្រើប្រាស់ មូលនិធិ ប្រាក់ចំណូល សម្រាប់ធានានិរន្តរភាព ដំណើរការអគារធនធាន។ ធានាការ ប្រើប្រាស់ឱ្យអស់លទ្ធភាព ប្រកបដោយសុវត្ថិភាព និងថែរក្សាទុកដាក់បរិក្ខារ/ឧបករណ៍។ ធ្វើឱ្យប្រាកដថា បុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់។ ចូលរួមប្រជុំតាមកាលកំណត់ដែលសម្រេចដោយគណៈគ្រប់គ្រងអគារធនធាន។

រូបទី១.***រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន ព្រមទាំងគណៈគ្រប់គ្រងអគារធនធាន***




តាមសេចក្ដីណែនាំលេខ ០៧ អយក.សណន ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១០ មានបុគ្គលិកបន្ថែមចំនួន ៨នាក់ទៀតសម្រាប់ជួយគណៈគ្រប់គ្រងអគារធនធានក្នុងដំណើរការរបស់អគារធនធាន។ អ្នកទាំងនោះគឺ:

ខ.***បរិវច្ឆការីបន្ទប់ពិសោធន៍***

ដើម្បីធានាដំណើរការរលូនក្នុងបន្ទប់ពិសោធន៍ អគារធនធានត្រូវមានបរិវច្ឆការី (អ្នករៀបចំ)បន្ទប់ពិសោធន៍ចំនួន៤នាក់ សម្រាប់មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។

បុគ្គលិកទាំង៤នាក់នេះ គួរប្រើប្រាស់គ្រូនៅក្នុងសាលាមធ្យមសិក្សាធនធាន ឬសាលាមធ្យមសិក្សាបណ្ដាញតាមឯកទេស ដោយគិតម៉ោងកំណត់ចំនួន១៦ ឬ១៨ម៉ោងក្នុងមួយសប្ដាហ៍ ហើយមានភារកិច្ចៈ

-គ្រប់គ្រងឧបករណ៍ពិសោធន៍ សម្ភារៈបរិក្ខារ និងវត្ថុធាតុដើមដែលមានក្នុងបន្ទប់ពិសោធន៍ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

-ធ្វើរបាយការណ៍ និងលើកសំណើរសុំជួសជុលសម្ភារៈពិសោធន៍បន្ថែម សហការជាមួយគ្រូមុខវិជ្ជាឯកទេសវិទ្យាសាស្ត្រដែលត្រូវធ្វើពិសោធន៍ ដើម្បីរៀបចំផែនការសកម្មភាពធ្វើសកម្មភាពប្រតិបត្តិក្នុងបន្ទប់ពិសោធន៍។

-រៀបចំនិងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់បន្ទប់ពិសោធន៍

-រៀបចំសម្ភារៈ វត្ថុធាតុដើមត្រៀមដំណើរការពិសោធន៍

-ជាជំនួយការគ្រូមុខវិជ្ជាឯកទេសក្នុងដំណើរការពិសោធន៍

-រៀបចំទុកដាក់ឧបករណ៍ពិសោធន៍ សម្ភារៈ និងវត្ថុធាតុដើមឱ្យមានរបៀបរៀបរយ និងធានាសុវត្ថិភាព។

គ. ***បុគ្គលិកទទួលបន្ទុកគ្រប់គ្រងកុំព្យូទ័រ***

ដើម្បីជួយសម្រួលដល់ការសិក្សានៅក្នុងបន្ទប់កុំព្យូទ័រ អគារធនធានត្រូវមានបុគ្គលិកទទួលបន្ទុកកុំព្យូទ័រចំនួន០២នាក់ គឺម្នាក់ទទួលបន្ទុកមួយបន្ទប់។បុគ្គលិកទាំងពីរនាក់នេះ គួរជ្រើសរើសគួរប្រើប្រាស់គ្រូនៅក្នុងសាលាមធ្យមសិក្សាធនធាន ឬសាលាមធ្យមសិក្សាបណ្ដាញ ដោយគិតម៉ោងកំណត់ចំនួន១៦ ឬ១៨ម៉ោងក្នុងមួយសប្ដាហ៍ហើយមានភារកិច្ចៈ

-គ្រប់គ្រងសម្ភារៈបរិក្ខារ និងឧបករណ៍អេឡិចត្រូនិច ដែលមានក្នុងបន្ទប់កុំព្យូទ័រ ដោយស្មារតីទទួលខុសត្រូវខ្ពស់

-សហការជាប្រចាំជាមួយគ្រូមុខវិជ្ជាឯកទេសពេលដំណើរការបង្រៀន-រៀន

-រៀបចំនិងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់បន្ទប់កុំព្យូទ័រ

-ត្រៀមរៀបចំដំណើរការបន្ទប់កុំព្យូទ័រ

-រៀបចំទុកដាក់សម្ភារៈឧបករណ៍អេឡិចត្រូនិចឱ្យមានរបៀបរៀបរយនិងធានាសុវត្ថិភាព

-លើកគម្រោងតម្រូវការសម្ភារៈចាំបាច់ ទឹកខ្មៅម៉ាស៊ីនបោះពុម្ព ទឹកខ្មៅម៉ាស៊ីនថតចម្លង (ប្រសិនជាមាន)

-ជួសជុលកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិច តាមសមត្ថភាពដែលអាចធ្វើបាន ដូចជាការជួសជុសតូច(កម្មវិធីសម្លាប់មេរោគ Anti-virus) ។ បើហួសពីសមត្ថភាពជួសជុស ត្រូវលើកគម្រោងស្នើសុំជួសជុល។

**ឃ.*ពលករអណ្តែត***

ដើម្បីជួយសម្រួលដល់ដំណើរការ និងសកម្មភាពសិក្សានៅក្នុងអគារធនធាន ត្រូវមានបុគ្គលិកដែលជាពលករអណ្តែតចំនួន០២នាក់ ដែលមានភារកិច្ចដូចតទៅ:

-ពលករអណ្តែតម្នាក់មានតួនាទីយាមកាមសុវត្ថិភាពអគារធនធាន

-ពលករអណ្តែតម្នាក់ទៀតមានភារកិច្ចសម្អាតបន្ទប់ សម្ភារៈនៅក្នុងធគារធនធាន ជួយបម្រើភេសជ្ជៈនៅពេលមានប្រជុំម្តងៗ

-ពលករទាំងពីរនាក់នេះ ត្រូវចេះសហាការគ្នាក្នុងការងារ

-ក្នុងករណីដែលការងារនៅអគារធនធានមានច្រើនហួសពីសមត្ថភាពអាចធ្វើបានរបស់ពលករ គណៈគ្រប់គ្រងអគារធនធានគប្បីចាត់ចែងទៅតាមលទ្ធភាពជាក់ស្តែង។

## ២.ការប្រើប្រាស់អគារធនធាន

**ក.*ដំណាក់កាលដំបូង***

នៅដំណាក់កាលដំបូង គណៈគ្រប់គ្រងអគារធនធាន ត្រូវរៀបចំកម្មវិធីមួយចំនួនដើម្បីណែនាំឱ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងសាលាមធ្យមសិក្សាបណ្តាញស្គាល់ពីសម្ភាររូបវន្តនិងផលប្រយោជន៍របស់វាក្នុងការសិក្សា។

**ខ.*អាទិភាពនៃការប្រើប្រាស់អគារធនធាន***

អគារធនធានគឺជាធនធានសម្បូរបែបដែលមានតែមួយគត់នៅក្នុងសាលាមធ្យមសិក្សាបណ្តាញ។ វាមិនត្រឹមតែផ្តល់ការប្រើប្រាស់ដល់សាលាមធ្យមសិក្សាបណ្តាញប៉ុណ្ណោះទេ គឺសម្រាប់សហគមន៍សិក្សាក្នុងមូលដ្ឋានទាំងមូលដែរ។ តម្រូវការប្រើប្រាស់អគារធនធានប្រាកដជាមានធំធេង ធៀបទៅនឹងលទ្ធភាពផ្គត់ផ្គង់ ដូច្នេះការកំណត់អាទិភាពជាការសំខាន់ណាស់។ កំណត់អាទិភាព អាស្រ័យលើលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ។

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញត្រូវប្រជុំគ្នាវិភាគពីតម្រូវការជាអាទិភាពរួមសម្រាប់សាលាមធ្យមសិក្សាបណ្តាញទាំងមូល ដោយស្របតាមបេសកកម្ម និងចក្ខុវិស័យរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ ដូចជាសាលារៀន

ណាដែលខ្វះខាតជាងគេ? សាលារៀនណា ដែលមានតម្រូវការជាងគេ(ចំពោះសាលារៀនដែលគ្មានសម្ភារ:សោះ មានអាទិភាពជាងសាលារៀនដែលមានសម្ភារ:ដែរតែមិនទំនើប)

ខាងក្រោមនេះជាឧទាហរណ៍នៃអាទិភាពមួយចំនួន ដែលសាលាមធ្យមសិក្សាបណ្តាញអាចមាន ៖

-ការណែនាំឱ្យស្គាល់ពីតួនាទីរបស់សាលាមធ្យមសិក្សាធនធាន អគារធនធាន សាលាមធ្យមសិក្សាបណ្តាញ និងផលប្រយោជន៍របស់វា

-ការណែនាំឱ្យយល់ដឹងពីបញ្ហាសុវត្ថិភាព ការប្រើប្រាស់ ការថែរក្សាបរិក្ខារ ការសម្អាត និងកិច្ចការរដ្ឋបាលចាំបាច់មួយចំនួន។(កម្មវិធីនេះគួររៀបចំមុនពេលដែលចាប់បើកឱ្យដំណើរការអគារធនធាន សម្រាប់សាលារៀននិងសហគមន៍)

-ការបំប៉នគ្រូចេញថ្មី ក្នុងសាលាមធ្យមសិក្សាបណ្តាញទាំងមូល

-ការបំប៉នគ្រូពីបច្ចេកវិទ្យា

-ការបំប៉នពីការងារបណ្ណារក្ស។ល។

គ.***កម្មវិធីផ្សេងទៀត ដែលអាចប្រើប្រាស់អគារធនធាន***

ខាងក្រោមនេះជាឧទាហរណ៍នៃវគ្គសិក្សា ឬកម្មវិធីផ្សេងៗដែលអាចប្រព្រឹត្តទៅនៅអគារធនធាន

-សិក្ខាសាលាបំប៉នការគ្រប់គ្រង និងដឹកនាំដល់នាយកសាលាមធ្យមសិក្សាធនធាន និងបណ្តាញ

-កម្មវិធីបណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេស ដែលអាចរៀបចំឡើងដោយអង្គការST STEPSAM II ឬ VVOB ស្តីអំពីរបៀបដំឡើង និងប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្រ សម្រាប់គ្រូ និងគ្រូដឹកនាំពិសោធន៍

- សិក្ខាសាលាសម្រាប់គ្រូបង្រៀនអំពីការប្រើប្រាស់ និងកសាងសម្ភារ:ឧបទេសបង្រៀនICT និងប្រព័ន្ធ ផ្សព្វផ្សាយចម្រុះ(Multi-media)ដែលបង្រៀន ដោយគ្រូឧទ្ទេសនៃគម្រោងលើកកម្ពស់គុណភាពអប់រំ

-ប្រជុំផ្សព្វផ្សាយដល់សាលារៀនមធ្យមសិក្សាបណ្តាញអំពីរបកគំហើញថ្មី

-វគ្គសិក្សាពីចម្ងាយសម្រាប់អ្នកដែលចង់បន្តការសិក្សាទៅថ្នាក់ខ្ពស់

-កម្មវិធីតាំងបង្ហាញកម្រងស្នាដៃសិស្ស-គ្រូ សម្ភារ:ពិសោធន៍/ ឧបទេសបង្រៀន

-កម្មវិធីឱ្យសិស្សចូលរួមស្តាប់បាឋកថាថ្លែងដោយអ្នកឯកទេស ដែលអញ្ជើញមកធ្វើបទឧទ្ទេសលើប្រធានបទដែលមានប្រយោជន៍ចំពោះសង្គម និងសាលារៀន។ល។

## ៣.មូលនិធិ និងប្រាក់ចំណូល

ក.*ការប្រើប្រាស់មូលនិធិ:* បច្ចុប្បន្នប្រភពផ្តល់មូលនិធិដល់អគារធនធានមាន៖

ក.១.*រដ្ឋាភិបាល*

ថវិការតាមកម្មវិធី(PB) នាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅ មានតួនាទីសំខាន់ក្នុងការផ្តល់យោបល់ដល់ក្រសួងអយក និងរាយការណ៍ច្បាស់លាស់ពីតម្រូវការហិរញ្ញវត្ថុចំណាយចរន្ត និងតម្លៃរំលោះរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញសម្រាប់ដំណើរការសាលារៀន។ *គម្រោងចំណាយប្រចាំឆ្នាំសម្រាប់អគារធនធានមាន៖*

- *ប្រើប្រាស់ទឹកក្នុងអគារធនធាន*
- *ការប្រើប្រាស់ថាមពលអគ្គិសនីក្នុងអគារធនធាន*
- *ការចំណាយលើវត្ថុធាតុដើម និងសម្ភារៈចាំបាច់សម្រាប់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ។*

ក.២.*ដៃគូអភិវឌ្ឍ*

សេចក្តីណែនាំលេខ ២៦ អយក.អណន ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការទទួលស្គាល់លក្ខណៈសម្បត្តិ និងការប្រើប្រាស់ថវិកាសម្រាប់ដំណើរការរបស់វិទ្យាល័យធនធាន បានចែងថាការចំណាយទៅលើទឹក អគ្គិសនី សកម្មភាពប្រតិបត្តិក្នុងបន្ទប់ពិសោធន៍ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងចំណាយផ្សេងៗដែលកើតមាន ត្រូវបានឧបត្ថម្ភដោយថវិការគម្រោងលើកកម្ពស់គុណភាពអប់រំ និងថវិការដ្ឋតាមគោលការណ៍ដូចខាងក្រោម៖

- នៅឆ្នាំទី១គម្រោងនឹងជួយឧបត្ថម្ភថវិកាសម្រាប់ដំណើរការអគារធនធាន ១០០%
- នៅឆ្នាំទី២គម្រោងនឹងជួយឧបត្ថម្ភថវិកាសម្រាប់ដំណើរការអគារធនធាន ១០០% ដូចឆ្នាំទី១
- នៅឆ្នាំទី៣ គម្រោងនឹងជួយឧបត្ថម្ភថវិកាសម្រាប់ដំណើរការអគារធនធាន៥០% រីឯ៥០%ទៀតត្រូវប្រើប្រាស់ថវិការបស់សាលា (PB) ។
- នៅឆ្នាំទី៤ និងឆ្នាំបន្តបន្ទាប់ និរន្តរភាពនៃការចំណាយត្រូវរ៉ាប់រងដោយថវិកាកម្មវិធីរបស់សាលារៀន គួបផ្សំប្រាក់ចំណូលពីការជួលសាលប្រជុំ ការបង្រៀនកុំព្យូទ័រយកប្រាក់ឈ្នួល...និងជំនួយផ្សេងៗពីដៃគូអភិវឌ្ឍ និងពីសប្បុរសជន។

ខ.*ការរក និងប្រើប្រាស់ប្រាក់ចំណូល*

ដើម្បីត្រៀមទទួលខុសត្រូវផ្នែកមូលនិធិរបស់សាលាមធ្យមសិក្សាធនធាននៅឆ្នាំទី៣ និងឆ្នាំបន្តបន្ទាប់ ទាមទារឱ្យគណៈគ្រប់គ្រងអគារធនធាន គណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ ព្រមទាំងអ្នកពាក់ព័ន្ធ ចូលរួមក្នុងដំណើរការកសាងផែនការ និងទទួលខុសត្រូវក្នុងការពង្រឹកសមត្ថភាពធនធានហិរញ្ញវត្ថុរបស់សាលារៀន ដើម្បីដោះស្រាយរាល់ចំណាយចាំបាច់ទៅលើការប្រើប្រាស់(ទឹក ភ្លើង ...) បុគ្គលិក (កម្មករ...) ការជួសជុលសម្ភាររូបវន្ត ការផ្គត់ផ្គង់ និងសម្ភារនានា។

***គ. មធ្យោបាយ ប្រភព និងជម្រើសមួយចំនួនដែលសាលាមធ្យមសិក្សាធនធានអាចរកថវិកាសម្រាប់ធានានិរន្តរភាពអគារធនធាន***

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងផ្ដល់ការជួយឧបត្ថម្ភប្រាក់ចំណាយសម្រាប់ដំណើរការអគារធនធាន ដែលមានចំនួន៧៨០០ដុល្លារ ដល់អគារធនធានមួយក្នុងមួយឆ្នាំ។ យ៉ាងណាក៏ដោយ ការប៉ាន់ស្មានចំណាយនេះ មិនបានគិតបញ្ចូលតម្លៃរំលោះនោះទេ។ តាមការប៉ាន់ស្មានទៅលើការចំណាយចរន្តសម្រាប់មួយខែទៅលើដំណើរការ និងតម្លៃរំលោះសម្ភាររូបវន្តគឺមានតម្លៃប្រមាណ ១៩០០ដុល្លារ សម្រាប់អគារធនធានមួយក្នុងមួយខែ។ នេះជាតម្លៃចំណាយខ្ពស់ បើធៀបនឹងលទ្ធភាពផ្គត់ផ្គង់របស់រដ្ឋ ដូច្នេះគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន គួរតែស្វែងរកមូលនិធិ(ប្រាក់ចំណូល)បន្ថែមដើម្បីបន្តនិរន្តរភាព។

គោលបំណងនៃការរកចំណូលសម្រាប់ធានានិរន្តរភាពអគារធនធាន មិនមែនដើម្បីរកប្រាក់ចំណេញដូចជាវិស័យឯកជនទេ តែអាចជាការប្រើកម្រៃនៃការប្រើប្រាស់សេវាកម្ម(User Fee) នៅពេលដែលសាលាមិនប្រើប្រាស់សម្ភារទាំងនោះសម្រាប់បង្រៀនសិស្ស ឬផ្ដល់សេវាកម្មនានាក្នុងន័យអនុវត្តបំណិនដល់សិស្ស។

សេចក្ដីណែនាំលេខ ០៧ បានកំណត់អំពីការរកប្រាក់ចំណូលថា" *នាយកវិទ្យាល័យធនធាន អាចរកប្រាក់ចំណូលពី៖*

- *ការជួលបន្ទប់ប្រជុំឱ្យអង្គភាព ឬអង្គការ ឬសហគមន៍នានាដើម្បីរៀបចំបើកសិក្ខាសាលា ឬធ្វើការប្រជុំផ្សេងៗ។*
- *ការបើកបង្រៀនកុំព្យូទ័រក្រៅម៉ោងសិក្សាដល់អ្នកសិក្សាគ្រប់ប្រភេទ។*

ខាងក្រោមនេះគ្រាន់តែជាសំណើមធ្យោបាយ ឬជម្រើសបន្ថែមមួយចំនួន ដែលសាលាមធ្យមសិក្សាធនធានអាចរកប្រាក់ចំណូលបាន។ វិធីនីមួយៗពុំមានលក្ខណៈសកលទេ ដូច្នេះចាំបាច់ត្រូវអនុវត្តវិធីណាមួយដែលមានលក្ខណៈសមស្របបំផុតចំពោះមូលដ្ឋាន។ឧទាហរណ៍

ជួលសម្ភារបរិក្ខារ (បន្ទប់ បរិក្ខារ ឧបករណ៍បំពងសម្លេង ឧបករណ៍តន្ត្រី រថយន្ត...)ដល់អង្គភាពនានា បុណ្យផ្កាសាមគ្គី

យកកម្រៃលើការប្រើប្រាស់សេវាកម្មដូចជា៖

- ការប្រើប្រាស់បណ្ណាល័យ(កម្រៃសមាជិកភាព)
- ការជួលឱ្យដាក់ផ្សាយ " ទូលក់ភេសជ្ជៈ ការឃោសនា ទូរស័ព្ទ ATM..."
- ថតចម្លងឯកសារ( ក្រដាស ស៊ីឌី...)
- ប្រើប្រាស់សេវាអ៊ិនធើណែត
- .....

យកកម្រៃលើការផ្តល់សេវាកម្មដូចជា៖

- កម្មវិធីមើលកុមារ (ពេលថ្ងៃ)
- ការអប់រំសហគមន៍ អប់រំច្បាប់ចរាចរណ៍ (បើកបរ...)
- ការណែនាំអំពីអាជីព ឬកម្មវិធីស្វែងរកការងារសម្រាប់យុវជន (សរសេរប្រវត្តិរូប ការសម្ភាស កន្លែងដែលអាចរកការងារធ្វើបាន...)
- កម្មវិធីថែរក្សាប្រព័ន្ធកុំព្យូទ័រ (ចែករំលែកអ្នកឯកទេស IT)
- បច្ចេកវិទ្យា (សន្និសីទតាមរយៈវីដេអូ...)
- កម្មវិធីសិក្សា/សរសេរតេស្ត (ជួយសរសេរកម្មវិធីសិក្សាពិសេសដល់សាលារៀនឯកជន...)
- .សេវាកម្មដេញថ្លៃ (ឱ្យសិស្សជួយផ្សព្វផ្សាយការលក់ឡាយឡុងអ្វីមួយ...)
- ផ្តល់សេវាកម្មនានា (សម្អាត ច្រូតស្រូវ...)

បើកការបណ្តុះបណ្តាល/ បំប៉នវគ្គខ្លីៗ ដូចជា៖បំណិនវិជ្ជាជីវៈ បង្រៀនបំណិនមូលដ្ឋានមួយចំនួនដូចជាការបណ្តុះផ្សិត បណ្តុះសណ្តែក ផលិតសាប៊ូ តភ្លើង ធ្វើនំ គ្រប់គ្រងខ្នាតតូច ភាសាបរទេស (អង់គ្លេស បារាំង ចិន កូរ៉េ... )តម្រូវការទីផ្សារ ទំនាក់ទំនងទីផ្សារ។

កម្មវិធីសិក្សាៈ *ការរៀបចំរវាងសាលារៀននិងផ្នែកឯកជនចំពោះសិស្សដែលរៀននៅសាលារៀនមួយពេល និងមួយពេលទៀតធ្វើការនៅសហគ្រាស ដោយម្ចាស់សហគ្រាសយកសាលារៀនធ្វើជាកន្លែងប្រតិបត្តិសម្រាប់សិស្សពួកគេ។ ឧទាហរណ៍ កាត់សក់ ជួលជុលម៉ូតូ... ។*

សហករណ៍សិស្សៈ

សេវាកម្មលក់សៀវភៅ (ជួលកន្លែងលក់សៀវភៅ សាលាដឹកនាំ និងធ្វើប្រតិបត្តិ)

ការបោះពុម្ពឯកសារលក់សម្រាប់អ្នកសិក្សាទូទៅ ឬការសរសេរឯកសារដើម្បីលក់ដល់អ្នកសិក្សាទូទៅ (ចម្លើយ លំហាត់...)

***ឃ.ការធានានិរន្តរភាពដំណើរការអគារធនធាន***

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាននិងបណ្ដាញ ត្រូវតែសិក្សាពីរបៀបរកទីផ្សារ និងបង្កើតប្រព័ន្ធទទួលខុសត្រូវមួយដើម្បីគ្រប់គ្រងកម្មវិធីរកប្រាក់ចំណូល ពីព្រោះកម្មវិធីទាំងនេះមិនមែនដើម្បីស្វែងរកផលប្រយោជន៍ គិតតែប្រាក់ចំណេញនោះទេ ប៉ុន្តែគួរតែប្រើប្រាស់កម្មវិធីទាំងនេះសម្រាប់៖

-ជាផលប្រយោជន៍ដល់បុគ្គលិកដែលបានធ្វើលើសម៉ោង ឬគ្រប់គ្រងកម្មវិធីនោះ

-ការថែរក្សា/ ជួសជុលសម្ភាររូបវន្ត

-ទិញវត្ថុធាតុដើម

-ចំណាយចាំបាច់ផ្សេងៗក្នុងអគារធនធាន ។ល។

វិធីរកប្រាក់ចំណូលនេះ(ទីផ្សារ)នេះ មិនមែនសុទ្ធតែជាកិច្ចការដែលពិបាកស្មុគស្មាញ ឬមានតម្លៃខ្ពស់នោះទេ គឺអាចងាយនិងសាមញ្ញ។ ឧទាហរណ៍ ការផ្សព្វផ្សាយពីសម្ភាររូបវន្តដែលមានក្នុងអគារធនធាន ការជួល/ផ្ដល់សេវាកម្មតាមរយៈការបិទព័ត៌មាននៅលើក្ដារខៀនព័ត៌មាន ការផ្សាយអគារធនធានតាមប័ណ្ណរបស់សាលារៀន។ល។

តាមស្មារតីអនុសារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)ជាមួយនឹងក្រសួងអយក គឺតម្រូវឱ្យក្រសួងធ្វើការវាយតម្លៃពីសមត្ថភាពរកប្រាក់ចំណូលរបស់ សាលាមធ្យមសិក្សាធនធាននៅជំណាច់ឆ្នាំ២០១២ ដើម្បីធានានិរន្តរភាពនិងដំណើរការរបស់សាលារៀន។ ដូច្នេះគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញត្រូវអភិវឌ្ឍយុទ្ធសាស្ត្ររកមូលនិធិ និងប្រាក់ចំណូល សិក្សាពីជម្រើស និងមធ្យោបាយនានាដើម្បីបន្តនិរន្តរភាពការងារ។

## ២.៣.៨.ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាធនធាន

ដើម្បីពង្រឹង និងគាំទ្រដល់ដំណើរការសាលារៀន រួមទាំងអគារធនធាន និងសាលាមធ្យមសិក្សាបណ្ដាញ ពិសេសក្នុងដំណាក់កាលដំបូង ការបង្កើតគណៈកម្មការគ្រប់គ្រងសាលាមមធ្យមសិក្សាធនធានត្រូវធ្វើជាចាំបាច់ និងបន្ទាន់ បន្ទាប់ពីទទួលបានប្រកាសស្ដីពីការបង្កើតអគារធនធាន និងប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាបណ្ដាញជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា។

## ១.គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញត្រូវបង្កើតឡើងដើម្បីជួយគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន អគារធនធាន និងសាលាមធ្យមសិក្សាបណ្ដាញ។ សមាសភាព ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការនេះមានដូចខាងក្រោម៖

**ក.*សមាសភាព***

១.នាយកសាលាមធ្យមសិក្សាធនធាន(ដែលមានអគារធនធានស្ថិតនៅ) ប្រធាន

២.នាយកសាលាមធ្យមសិក្សា(សាលាមធ្យមសិក្សាបណ្ដាញទាំងអស់) សមាជិក

គណៈកម្មការនេះត្រូវបានចាត់តាំងតាមលិខិតឧទ្ទេសនាមរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ។

**ខ.*ភារកិច្ច***

•ជួយសម្រួលលក្ខខណ្ឌចាំបាច់ទាំងផ្នែកបច្ចេកទេស និងរដ្ឋបាលរបស់សាលាមធ្យមសិក្សាធនធាន និងបណ្ដាញឱ្យមានដំណើរការ និងទទួលលទ្ធផលល្អ ពិសេសក្នុងការអនុវត្តគោលនយោបាយសាលាមធ្យមសិក្សាធនធានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

•ប្រើប្រាស់ឱ្យអស់លទ្ធភាព និងដោះស្រាយនិរន្តរភាពដំណើរការរបស់អគារធនធានរួមមានរៀបចំលក្ខខណ្ឌដម្បីប្រើប្រាស់សម្ភារបរិក្ខារ ព្រមទាំងស្វែងរកនិងប្រើប្រាស់ថវិការបស់អគារធនធាន។

•ធ្វើការប្រាស្រ័យទាក់ទងជាមួយសហគមន៍សិក្សា និងអ្នកពាក់ព័ន្ធដើម្បីបញ្ជ្រាបបញ្ញត្តិថ្មី (សាលាមធ្យមសិក្សាធនធាន អគារធនធាន និងសាលាមធ្យមសិក្សាបណ្ដាញ)។

•ធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន និងបណ្ដាញផ្អែកលើការវិភាគទិន្នន័យនិងអាទិភាពរបស់មូលដ្ឋាន ដូចជាកំណត់បណ្ដាកន្លែងដែលមានតម្រូវការដូចគ្នា ធ្វើជាចំណុចរួមនៃការប្រឹងប្រែងសម្រាប់ការរីកចម្រើន ហើយផ្ញើទៅក្រសួង អប់រំ យុវជន និងកីឡា(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ/ គម្រោងលើកកម្ពស់គុណភាពអប់រំ)។

•ផ្សព្វផ្សាយ អនុវត្ត និងវាយតម្លៃ(ការអនុវត្តការងារ) ផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន។

•បង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សក្នុងសាលាមធ្យមសិក្សាបណ្ដាញ ឱ្យទទួលបានការប្រើប្រាស់អគារធនធាន។

•អភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំទាំងចំណេះដឹង សមត្ថភាព(Competencies) និងឥរិយាបថ(វិធីសាស្ត្របង្រៀន ស្រាវជ្រាវ ភាសាអង់គ្លេស និង ICT ...) ឱ្យដល់កម្រិតស្តង់ដារក្នុងតំបន់ ឬអន្តរជាតិទាំងនៅសាលាមធ្យមសិក្សាធនធាន ទាំងសាលាមធ្យមសិក្សាបណ្តាញ និងអនុវត្តវប្បធម៌ចែករំលែក។

•ចាត់តាំងបុគ្គលិកដែលមានស្រាប់នៅក្នុងវិទ្យាល័យ ឬសាលាមធ្យមសិក្សាបណ្តាញតាមស្មារតីសេចក្តីណែនាំលេខ០៧អយក.សណន ចុះថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០១០។

•ធ្វើរបាយការណ៍លទ្ធផលការងារតាមកាលកំណត់ (ខែ ត្រីមាស និងឆ្នាំ) ជូនក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ/ គម្រោងលើកកម្ពស់គុណភាពអប់រំ)។

•ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ លើការងារគ្រប់គ្រង ការប្រើប្រាស់ធនធាន (មនុស្ស សម្ភារៈ ថវិកា) របស់សាលារៀន។

•ធ្វើសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ស្ថាប័ននានា និងសហគមន៍ដើម្បីធានានិរន្តរភាពដំណើរការសាលាមធ្យមសិក្សាធនធាន សំដៅផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធចូលរួមទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិកា ធ្វើផែនការអភិវឌ្ឍ អនុវត្តផែនការ និងវាយតម្លៃ។

•ចូលរួមប្រជុំតាមកាលកំណត់ ដែលសម្រេចដោយគណៈកម្មការសាលាមធ្យមសិក្សាធនធាន និងបណ្តាញ។

***គ. ទំនាក់ទំនងរបស់គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ***

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញតាមរចនាសម្ព័ន្ធខាងក្រោម៖

*រូបទី២. **ទំនាក់ទំនងរវាងគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាននិងបណ្តាញ សាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញ***




## ២.ធនធានមនុស្សរបស់សាលាមធ្យមសិក្សាធនធាន

**ក.គណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន**

នាយក/ នាយិកា នាយករង/ នាយិការងត្រូវរក្សាតាមរចនាសម្ព័ន្ធដែលមានស្រាប់របស់វិទ្យាល័យស្របតាមសេចក្ដីណែនាំលេខ២៥៦អយក.សណនចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០០២។

**ខ.គណៈគ្រប់គ្រងអគារធនធាន** (មើល២.៣.១)

**គ.បុគ្គលិកបង្រៀន មិនបង្រៀន និងបុគ្គលិកផ្សេងទៀត**

ការប្រើប្រាស់បុគ្គលិកបង្រៀន មិនបង្រៀន និងបុគ្គលិកផ្សេងទៀត ត្រូវអនុវត្តតាមសេចក្ដីណែនាំលេខ ២៥៦ អយក.សណនចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្ដីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងគរុកោសល្យ។

**ឃ.ធនធានមនុស្សសម្រាប់បន្តវេន និងធានានិរន្តរភាព**

ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីក្រុមការងារថ្នាក់ជាតិ(គ្រូឧទ្ទេសដែលមកពីក្រសួងអ.យ.ក) នៃគម្រោងលើកកម្ពស់គុណភាពអប់រំ ពិសេសក្នុងដំណាក់កាលដំបូង សាលាមធ្យមសិក្សាធនធានគួរជ្រើសរើសបុគ្គលិកអប់រំឆ្នើម ( អាចជានាយករងទទួលបន្ទុកបច្ចេកទេស ប្រធានក្រុមបច្ចេកទេស អ្នកស្ម័គ្រចិត្ត...) នៅក្នុងសាលាមធ្យមសិក្សាធនធាន ឬបណ្តាញដែលមានឆន្ទៈ និងមានសមត្ថភាពធ្វើជាធនធានពិសេសសម្រាប់ជួយដល់សាលារៀន និងសាលាមធ្យមសិក្សាបណ្តាញ ឧទាហរណ៍ បំណិនភាសាអង់គ្លេស បំណិនគ្រប់គ្រងដឹកនាំ បំណិនកុំព្យូទ័រ ជាដើម។

## ៣.ការគាំទ្ររបស់សាលាមធ្យមសិក្សាធនធានចំពោះសាលាមធ្យមសិក្សាបណ្តាញ

សាលាមធ្យមសិក្សាធនធាន ជាសាលារៀនមួយដែលបានទទួលធនធានសម្ភារ មួយចំនួន ហើយដែលធនធានសម្ភារៈទាំងនោះពុំទាន់មាននៅតាមសាលាមធ្យមសិក្សាមួយចំនួនធំក្នុងសាលាមធ្យមសិក្សាបណ្តាញ។ក្នុងន័យនេះ សាលាមធ្យមសិក្សាធនធានត្រូវទទួលខុសត្រូវអប់រំដល់សិស្ស បុគ្គលិកអប់រំ និងសហគមន៍ ហើយធ្វើឱ្យធនធាន និងសម្ភារៈទាំងនោះ អាចប្រើប្រាស់បានជាអតិបរមាដោយអ្នកឯទៀតក្នុងសាលាមធ្យមសិក្សាបណ្តាញ សំដៅបង្កើនគុណភាពសេវាកម្មអប់រំ។ សាលាមធ្យមសិក្សាធនធានអាចផ្តល់៖

•កន្លែងឱ្យគ្រូ និងអ្នកគ្រប់គ្រងអប់រំនៅក្នុងសាលាមធ្យមសិក្សាបណ្តាញមកជួបជុំគ្នា ដើម្បីស្វែងយល់ពីផលប្រយោជន៍នានា ដែលសាលាមធ្យមសិក្សាធនធានអាចផ្តល់ដល់ពួកគេ។

•ធនធានដែលមានក្នុងសាលាមធ្យមសិក្សាធនធាន(ដែលធនធានទាំងនោះពុំទាន់មាន ឬពុំទាន់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក្នុងសាលារៀននានា ក្នុងសាលាមធ្យមសិក្សាបណ្តាញ) ដើម្បីអភិវឌ្ឍសមត្ថភាពដល់គ្រូបង្រៀនក្នុងសាលាមធ្យមសិក្សាបណ្តាញ។

•មូលដ្ឋានសម្រាប់គ្រូឧទ្ទេស(ក្រុមបច្ចេកទេស)អភិវឌ្ឍបំណិន និងសមត្ថភាពណាដែលពួកគេពុំទាន់មាន។

•មូលដ្ឋានមួយសម្រាប់អង្គភាពអប់រំដទៃទៀត រៀបចំជាកម្មវិធីបណ្តុះបណ្តាលដល់មូលដ្ឋាន និងផ្តល់ឱកាសដល់គ្រូបន្តការសិក្សា ដើម្បីបង្កើនចំណេះដឹងសម្រាប់មេរៀនខ្លះ។

•ឱកាលសម្រាប់ការចែករំលែកសម្ភាររូបវន្តឱ្យបានប្រើប្រាស់ជាអតិបរមា។ ឧទាហរណ៍នៅខេត្ត កំពង់ចាម សាលាមធ្យមសិក្សាធនធាន មណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យខេត្ត មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សាលាសម្រាប់កុមារគថ្លង់

និងសាលាអនុវត្ត(បឋមសិក្សា)មានទីតាំងស្ថិតនៅក្នុងស្រុកជាមួយគ្នា អាចចែករំលែកការប្រើប្រាស់សម្ភាររូបវន្តគ្នាបាន។

•បំណិនផ្នែកបច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍(ICT)និងណែនាំគ្រូអំពីវិធីប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះ(Multi-media)។

•បណ្ណាល័យសម្រាប់ផ្តល់សម្ភារៈជំនួយដល់ការបង្រៀន និងជាប្រភពឯកសារយោងមួយសម្រាប់សាលាមធ្យមសិក្សាបណ្តាញ។

•កន្លែងមួយដែលបង្ហាញសិស្សឱ្យមើលឃើញបញ្ញត្តិវិទ្យាសាស្ត្រ និងសង្គម ពិសេសចំពោះបញ្ញត្តិដែលមានការពិបាកក្នុងការបង្ហាញ ប្រសិនគ្មានការអនុវត្តនៅក្នុងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ។

## ២.៣.៩.ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាបណ្តាញ

ដើម្បីអភិវឌ្ឍសាលាមធ្យមសិក្សាបណ្តាញឱ្យមានសក្តានុពលពេញលេញតាមតម្រូវការចាំបាច់ត្រូវតែមានការគ្រប់គ្រងសាលាមធ្យមសិក្សាបណ្តាញដ៏រឹងមាំមួយដែលកើតឡើងតាមរយៈការសហការក្នុងសាលាមធ្យមសិក្សាបណ្តាញទាំងមូល។ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាទាំងនេះ សាលាមធ្យមសិក្សាធនធាន និងបណ្តាញត្រូវតែមានការរៀបចំតាមយន្តការមួយដែលច្បាស់លាស់ និងងាយយល់។

### ១.សាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញ

សាលាមធ្យមសិក្សាធនធាន ត្រូវសហការជាមួយសាលាមធ្យមសិក្សាបណ្តាញ ដើម្បីរៀបចំសកម្មភាពមួយចំនួនដូចជា:

- រៀបចំកម្មវិធីប្រជុំដំបូងជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ ដើម្បីឱ្យពួកគេយល់ដឹងពីតួនាទីរបស់ពួកគេនៅក្នុងសាលាមធ្យមសិក្សាបណ្តាញ។ ការប្រជុំនេះផ្តោតទៅលើ៖

  - របៀបចែករំលែកការប្រើប្រាស់ធនធាន និងការទទួលសេវាកម្ម
  - ការចងក្រង និងចែករំលែកបទពិសោធរបស់គ្រូ និងអ្នកឯកទេស
  - ការកំណត់ការចូលរួមរបស់អ្នកពាក់ព័ន្ធ(សហគមន៍...)និងយន្តការទទួលខុសត្រូវ

- រៀបកំណត់អាទិភាពនៃតម្រូវការបណ្តុះបណ្តាល និងអភិវឌ្ឍសម្រាប់សាលាមធ្យមសិក្សាបណ្តាញ និងរបៀបដែលគ្រូឧទ្ទេស(ប្រធានក្រុមបច្ចេកទេស)អាចប្រើប្រាស់អគារធនធាន
- កំណត់ពីតម្រូវការបណ្តុះបណ្តាលរបស់អ្នកគ្រប់គ្រង
- របៀបដែលសាលាមធ្យមសិក្សាបណ្តាញអាចផ្សព្វផ្សាយសេវាកម្មនេះដល់សហគមន៍ និងវិស័យអប់រំ។

-កំណត់និងកសាងបេសកម្ម ចក្ខុវិស័យ និងគោលដៅរួមមួយរបស់សាលាមធ្យមសិក្សាបណ្តាញ តាមរយៈការវិភាគផ្អែកលើទិន្នន័យ នៃស្ថានភាពបច្ចុប្បន្ន និងនិន្នាការអនាគតរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញទាំងមូល។

-ធ្វើផែនការសម្រាប់អភិវឌ្ឍ និងធ្វើឱ្យកម្រិតអប់រំនៅមធ្យមសិក្សារបស់សាលាមធ្យមសិក្សាបណ្តាញទាំងមូលមានការរីកចម្រើន ដោយកំណត់អាទិភាពសំខាន់ៗដែលជាចំណុចដៅរួមរបស់សាលាមធ្យមសិក្សាបណ្តាញ។ អាទិភាពរបស់សាលាមធ្យមសិក្សាបណ្តាញមួយអាចខុសពីសាលាមធ្យមសិក្សាបណ្តាញមួយទៀត អាស្រ័យនឹងអត្ថិភាពធនធាន(មនុស្ស ថវិកា សម្ភារៈ ពេលវេលា ) ឧទាហរណ៍ ការងារគ្រប់គ្រង លទ្ធផលសិក្សារបស់សិស្ស តម្រូវការបំប៉នសមត្ថភាពគ្រូចេញថ្មី...។

-រៀបចំកម្មវិធីបណ្តុះបណ្តាលដល់នាយកសាលាមធ្យមសិក្សាបណ្តាញឱ្យចេះអភិវឌ្ឍសាលារៀន ដឹងពីរបៀបគ្រប់គ្រង ដឹកនាំ ការធ្វើផែនការ ការរៀបចំថវិកា ស្វ័យវាយតម្លៃ និងផែនការអភិវឌ្ឍសាលារៀនឱ្យស្របតាមផែនការរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ។

## ២.ភារកិច្ចរបស់សាលាមធ្យមសិក្សាបណ្តាញ

សាលាមធ្យមសិក្សាបណ្តាញនីមួយៗត្រូវ៖

- យល់ឱ្យបានច្បាស់ពីគោលបំណង ផលប្រយោជន៍ និងតួនាទីរបស់សាលាមធ្យមសិក្សាបណ្តាញ ក្នុងការចូលរួមគ្រប់គ្រង និងប្រើប្រាស់អគារធនធាន ដូចជាត្រូវទាមទារឱ្យមានការប្តេជ្ញាចិត្ត បង្កើតវប្បធម៌នៃការរៀនបែបវិជ្ជាជីវៈ មានបំណិនសហការ កសាងក្រុម (Team) និងចែករំលែក។ ឧទាហរណ៍ គ្រូសាលាមធ្យមសិក្សាបណ្តាញខ្លះឆ្នើមជាងសាលាមធ្យមសិក្សាធនធាន អាចមកជួយសាលាមធ្យមសិក្សាធនធាន សាលាមធ្យមសិក្សាបណ្តាញបាន។

- សម្រួល បង្កលក្ខណៈ និងផ្តល់ឱកាសឱ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធអប់រំមានឱកាសចូលរួមទទួលផលប្រយោជន៍ពីសាលាមធ្យមសិក្សាធនធាន រួមមានការប្រើប្រាស់អគារធនធាន។
- ដោះស្រាយតាមលទ្ធភាពចំពោះការធ្វើដំណើររបស់បុគ្គលិកអប់រំ និងសិស្សានុសិស្សពេលមកទទួលការសិក្សា ឬបំប៉ននៅសាលាមធ្យមសិក្សាធនធាន ដោយសហការជាមួយគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញព្រមទាំងអ្នកពាក់ព័ន្ធអប់រំ។ ក្នុងករណីដែលការធ្វើដំណើរទៅអគារធនធានមានការលំបាក(ផ្លូវឆ្ងាយ) នោះការបំប៉នគណៈគ្រប់គ្រងសាលា ឬប្រធានក្រុមបច្ចេកទេសមានសារៈសំខាន់ណាស់ក្នុងការផ្សព្វផ្សាយ និងបំប៉នបន្ត ។

# ឧបសម្ព័ន្ធ

## ១.លំនាំផែនការសកម្មភាព៣ខែរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ

### ១.១.សេចក្តីផ្តើម

**ឈ្មោះសាលាមធ្យមសិក្សាធនធាន** : *វិទ្យាល័យ* ក មានទីតាំង: ស្ថិតនៅក្នុងស្រុក កំពង់សៀម ខេត្ត កំពង់ចាម

**មានសាលាមធ្យមសិក្សាបណ្តាញចំនួន** : ១២ (៣វិទ្យាល័យ និង៩ អនុវិទ្យាល័យ)

**ស្ថិតិសរុប (គិតទាំងបណ្តាញ)** : ចំនួនសិស្ស xxx នាក់ ចំនួនថ្នាក់ xxx នាក់ និងបុគ្គលិក ចំនួន xxx នាក់ ។

១.២.តារាង Gantt Chart ផែនការសកម្មភាព

| **សកម្មភាពសំខាន់ៗ** | រយៈពេល | ខែទី១ : មករា | | | | ខែទី២ : កុម្ភៈ | | | | ខែទី៣ : មិនា | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | W 1 | W 2 | W 3 | W 4 | W 1 | W 2 | W 3 | W 4 | W 1 | W 2 | W 3 | W 4 | |
| **១.គណៈកម្មការគ្រប់គ្រងសាលាស.ម.ធ** | | | | | | | | | | | | | | |
| ១.១.ធ្វើសំណើសុំបង្កើតគណៈកម្មកាគ្រប់គ្រង ស.ម.ធបញ្ជូនទៅមន្ទីរ អយក | | X | | | | | | | | | | | | |
| ១.២.ប្រជុំដំបូងរបស់គណៈកម្មកាគ្រប់គ្រង សាលាធនធាន | | | X | | | | | | | | | | | |
| ១.៣.ប្រជុំផ្សព្វផ្សាយបញ្ញត្តិសាលាធ.ធ អគារធ.ធ.និងបណ្តាញដល់អ្នកពាក់ព័ន្ធ | | | | X | | | | | | | | | | |
| ១.៤.ប្រជុំកំណត់បេសកម្មចក្ខុវិស័យ គោល ដៅរួម កំណត់អាទិភាព | | | | | X | | | | | | | | | |
| ១.៥.កសាងផែនការធ្វើសកម្មភាពសម្រាប់ រយៈពេល៣ខែដំបូងសម្រាប់សាលាធ.ធ | | | X | X | X | | | | | | | | | |
| ១.៦.បញ្ជូនផែនការរយៈពេល៣ខែដំបូងទៅ គម្រោងដើម្បីសុំការយល់ព្រម | | | | X | X | | | | | | | | | |
| ១.៧.វាយតម្លៃការប្រតិបត្តិរបស់សាលាធ.ធ | | | | | | | | | | | | | X | |
| ........... | | | | | | | | | | | | | | |
| **២.សាលាមធ្យមសិក្សាធនធាន** | | | | | | | | | | | | | | |
| ២.១.ទទួលប្រកាសសាលាមធ្យមសិក្សាធនធាន និងផ្សព្វផ្សាយដល់បណ្តាញ | | X | | | | | | | | | | | | |
| ២.២.ចូលរួមវគ្គណែនាំរដ្ឋបាល និងហិរញ្ញវត្ថុពី ក្រុមការងារ | | | X | | | | | | | | | | | |
| ២.៣.ប្រជុំក្រុមប្រឹក្សាវិន័យ | | | X | | | | | | | | | | | SAP |
| ២.៤.ចាត់តាំងគណនេយ្យករ( ចាស់ឬថ្មី ) | | X | | | | | | | | | | | | |
| ២.៥.បើកគណនីធនាគារសម្រាប់សាលាមធ្យម សិក្សាធនធាន | | | X | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.៦.ធ្វើសំណើតែងតាំងបុគ្គលិក កម្មករ បន្ថែម បញ្ជូនទៅមន្ទីរ អ.យ.ក | | X | | | | | | | | | | | | |
| ២.៧.ធ្វើសំណើសុំថវិកាដំណើការអគារធ.ធ | | | | X | | | | | | | | | | |
| **៣.សម្រាប់អគារធនធាន** | | | | | | | | | | | | | | |
| ៣.១.ការរៀបចំដំណើការទាំងបុគ្គលិក និងសម្ភារៈ | | X | X | X | X | | | | | | | | | |
| ៣.២.ដាក់ឱ្យដំណើរការគ្រប់ផ្នែក | | | | | | X | X | X | X | | | | | |
| ៣.៣.ផ្សព្វផ្សាយដល់បណ្តាញ | | | | | | | | | | X | X | X | X | |
| ............................ | | | | | | | | | | | | | | |
| **៤.សម្រាប់សាលាមធ្យមសិក្សាបណ្តាញ** | | | | | | | | | | | | | | |
| ៤.១.ចូលរួមវគ្គផ្សព្វផ្សាយ | ៤ម៉ | | | | | | | | | X | X | X | X | |
| ..................... | | | | | | | | | | | | | | |

សំគាល់ : W1=សប្តាហ៍ទី១ SAP =សកម្មភាពក្នុងផែនការប្រចាំឆ្នាំរបស់សាលារៀន

ចំពោះ " ចំណុច៤. សម្រាប់សាលាមធ្យមសិក្សាបណ្តាញ" សាលាមធ្យមសិក្សាបណ្តាញនីមួយៗ ត្រូវជ្រើសរើសយកសកម្មភាពណាដែលទាក់ទងទៅនឹងសាលាមធ្យមសិក្សាធនធាន និងអគារធនធាន។

ធ្វើនៅ ថ្ងៃទី ខែ មករា ឆ្នាំ ២០១១

នាយកសាលាមធ្យមសិក្សាធនធាន

## ២.លំនាំផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ

### ២.១.ព័ត៌មានទូទៅ

**ឈ្មោះសាលាមធ្យមសិក្សាធនធាន** : *វិទ្យាល័យ* **ក** មានទីតាំង: ស្ថិតនៅក្នុងស្រុក កំពង់សៀម ខេត្ត កំពង់ចាម

**មានសាលមធ្យមសិក្សាបណ្តាញចំនួន** : ១២ (៣វិទ្យាល័យ និង៩ អនុវិទ្យាល័យ)

**ស្ថិតិសរុប (គិតទាំងបណ្តាញ)** : ចំនួនសិស្ស xxx នាក់ ចំនួនថ្នាក់ xxx នាក់ និងបុគ្គលិកចំនួន xxx នាក់ ។

**ទំនាក់ទំនងទូរស័ព្ទ៖** 01X XXXXXX អ៊ីម៉េល: srsx@gmail.com

វេបសាយ:http:/www.srs.com

### ២.២.ផែនការសកម្មភាព

ក.តារាង Gantt Chart ផែនការសកម្មភាព

| សកម្មភាពសំខាន់ៗ | រយៈពេល | ត្រីមាសទី១ | | | ត្រីមាសទី២ | | | ត្រីមាសទី៣ | | | ត្រីមាសទី៤ | | | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| **១.គណៈកម្មការគ្រប់គ្រងសាលា.ម.ធ.ធ** | | | | | | | | | | | | | | |
| ១.១.ធ្វើសំណើសុំបង្កើតគណៈកម្មកាគ្រប់គ្រងស.ម.ធបញ្ជូនទៅមន្ទីរ អយក | | X | | | | | | | | | | | | |
| ១.២.ប្រជុំគណៈកម្មកាគ្រប់គ្រងសាលាធ.ធ | ៣ម៉ោ/ខែ | X | X | X | X | X | X | X | X | X | X | X | X | sap |
| ១.៣.ប្រជុំគណៈកម្មការទ្រទ្រង់សាលារៀន | | | X | | | | X | | | | X | | | |
| ១.៣.ប្រជុំផ្សព្វផ្សាយគោលន.បសាលាធ.ធដល់អ្នកពាក់ព័ន្ធ | | X | X | X | | | | | X | X | | | | |
| ១.៤.កសាងសកម្មភាពខែដំបូងសម្រាប់សាលាធ.ធ | | X | | | | | | | | | | | | ..... |
| ១.៥.ប្រមូលនិងវិភាគទិន្នន័យបណ្តាញដើម្បីត្រៀមរៀបចំផែនការប្រចាំឆ្នាំ | | X | X | | | | | | | | | | | |
| ១.៦.កំណត់បេសកម្ម ចក្ខុវិស័យ គោលដៅរួម កំណត់អាទីភាពរបស់បណ្តាញ | | X | | | | | | | | | | | | |
| ១.៧.កសាងផែនការសកម្មភាពប្រចាំឆ្នាំ | | | | | | | | | | | X | X | | |
| ១.៨.វាយតម្លៃប្រតិបត្តិការរបស់សាលាធ.ធ | | | X | | | | X | | | | X | | | |
| ១.៩.ពិនិត្យយន្តការការងារក្នុងបណ្តាញទាំងមូល | | | | X | | | X | | | X | | | X | |
| ............ | | | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **២.សាលាមធ្យមសិក្សាធនធាន** | | | | | | | | | | | | | |
| ២.១.ចូលរួមវគ្គណែនាំរដ្ឋបាល និងហិរញ្ញវត្ថុពីក្រុមការងារ | | X | | | | | | | | | | | |
| ២.២.ប្រជុំក្រុមប្រឹក្សាវិន័យ | | X | | | X | | | X | | | X | | sap |
| ២.៣.ចាត់តាំងគណនេយ្យករ(ចាស់ឬថ្មី) | | X | | | | | | | | | | | |
| ២.៤.បើកគណនីធនាគារសម្រាប់សាលាមធ្យមសិក្សាធនធាន | | X | | | | | | | | | | | |
| ២.៥.ធ្វើសំណើតែងតាំងបុគ្គលិក កម្មករបន្ថែមបញ្ជូនទៅមន្ទីរ អ.យ.ក | | X | | | | | | | | | | | |
| ២.៦.ធ្វើសំណើសុំថវិកាដំណើការអគារធ.ធ | | X | | | X | | | X | | | X | | ពាក់ខែ |
| ២.៧.ជ្រើសគ្រូឧទ្ទេស ឬអ្នកបង្វឹកសម្រាប់កម្មវិធីមួយចំនួនដូចជា ការបំប៉នភាសាអង់គ្លេស កុំព្យូទ័រ..... | | | X | | | | | | | | | | |
| ២.៨.ប្រឡងឆមាស | | | X | X | | X | X | | | | | | sap |
| ២.៩.បូកសរុបលទ្ធផលសិក្សារបស់សិស្ស | | | | X | | | X | | | X | | | sap |
| ២.១០.ប្រឡងជ្រើសរើសសិស្សពូកែប្រចាំសាលារៀន | | | | X | | | | | | | | | |
| ២.១១.ជ្រើសរើសមុខសញ្ញាដែលត្រូវបំប៉នតាមដំណាក់ | | | X | | | | X | | | X | | | X | |
| ២.១២.ប្រជុំក្រុមបច្ចេកទេស | | X | X | X | X | X | X | X | X | X | X | X | X | sap |
| .......... | | | | | | | | | | | | | |
| **៣.សម្រាប់អគារធនធាន** | | | | | | | | | | | | | |
| ៣.១.បង្កើតគណៈគ្រប់គ្រងអគារធនធាន | | X | | | | | | | | | | | |
| ៣.២.ប្រជុំអ្នកពាក់ព័ន្ធឱ្យស្គាល់ពីបំណង តួនាទី ផលប្រយោជន៍អគារធនធាន | | | X | X | | | | | X | | | | |
| ៣.៣.បំប៉នការងារគ្រប់គ្រង ដឹកនាំ ដល់នាយក | | | | X | | | | | | | | | |
| ៣.៤.បំប៉នការងារគ្រប់គ្រង ដឹកនាំ ដល់ក្រុមបច្ចេកទេស | | | | X | | | | | X | | | | |
| ៣.៥.បំប៉នគ្រូបន្ទប់ពិសោធន៍ | | | X | X | X | | | | X | | | | |
| ៣.៦.បំប៉នភាសាអង់គ្លេស | | | X | X | X | | | | X | | | | |
| ៣.៧.បំប៉នកុំព្យូទ័រដល់បុគ្គលិកអប់រំ | | | X | X | X | | | | x | | | | |
| ៣.៨.វាយតម្លៃការងារអនុវត្ត | | | X | | | | X | | | | | | X | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៩.ប្រជុំធ្វើថ្នាក់និទស្សន៍សម្រាប់គ្រូបណ្តាញ | | | | X | | | X | | | X | | | X | |
| ៣.១០.ការបំប៉នគ្រូចេញថ្មីក្នុងបណ្តាញ | | | | | X | | | | X | X | | | | |
| ៣.១១.បូកសរុបលទ្ធផលសិក្សារបស់សិស្សតាមឯកទេស( ពិ.ស/កុំ.ទ/ បណ.. ) | | | | X | | | X | | | X | | | | |
| ៣.១២.រៀបចំកាលវិភាគប្រើប្រាស់សម្ភាររូបវិទ្ត | | X | X | | | | | | | | | | | |
| ៣.១៣.ពិនិត្យឡើងវិញ និងវាយតម្លៃកាលវិភាគប្រើប្រាស់សម្ភាររូបវ័ន្ត | | | | X | | | X | | | X | | | X | |
| ……………………… | | | | | | | | | | | | | | |
| **៤.សម្រាប់សាលាមធ្យមសិក្សាបណ្តាញ** | | | | | | | | | | | | | | |
| ៤.១.កំណត់គ្រូមកពីសាលាម.ធ.ស.បចូលរួមក្នុងវគ្គបំប៉ននៅអគារធនធាន | ២ថ្ងៃ | X | X | X | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.២.កំណត់គ្រូមកពីសាលាម.ធ.ស.បចូលរួមប្រើប្រាស់រូបវ័ន្តនៅអគារធនធាន | | | | x | | | | | | | | | | |
| ៤.៣.ចូលរួមវគ្គផ្សព្វផ្សាយគោលន.បនិងស.ភ ណែនាំប្រតិបត្តិសាលាធនធានដល់គ្រូ | | | | X | | X | | | | | | | | |
| ៤.៤.ចូលរួមវគ្គផ្សព្វផ្សាយគោលន.បនិងសភណែនាំប្រតិបត្តិសាលាធ.ធ ដល់សិស្ស | | | X | X | | | | | | | X | X | | |
| ៤.៥.ការប្រជុំក្រុមបច្ចេកទេស | | X | X | X | X | X | X | X | X | X | X | X | x | |
| ………………… | | | | | | | | | | | | | | |

សំគាល់ : W1=សប្តាហ៍ទី១ SAP =សកម្មភាពក្នុងផែនការប្រចាំឆ្នាំរបស់សាលារៀន

ចំពោះ " ចំណុច៤.សម្រាប់សម្រាប់សាលាមធ្យមសិក្សាបណ្តាញ" សាលាមធ្យមសិក្សាបណ្តាញនីមួយៗ ត្រូវជ្រើសរើសយកសកម្មភាពណាដែលទាក់ទងទៅនឹងសាលាមធ្យមសិក្សាធនធាន និងអគារធនធាន។

ធ្វើនៅ ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ២០១១

នាយកសាលាមធ្យមសិក្សាធនធាន

សំគាល់ : ផែនការសកម្មភាពប្រចាំឆ្នាំនេះត្រូវផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) និងចម្លងជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត រៀងរាល់សប្តាហ៍ទី១នៃខែធ្នូ នៃឆ្នាំសិក្សា។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ដំណើរការនៃការស្រាវជ្រាវ

យោងតាមលិខិតឧទ្ទេសនាមលេខៈ៩៦៣៣ អយក.ឧទន ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់ក្រសួងអប់រំយុវជននិងកីឡា ស្តីពីការចាត់តាំងឲ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវតាមសាកលវិទ្យាល័យនិងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករាឆ្នាំ២០២០នៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ និង ផែនការអនុត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ របស់វិទ្យាស្ថានជាតិអប់រំ។ អ្នកសិក្សាបានរៀបចំរួចរាល់ ដើម្បីយកលិខិតឧទ្ទេសនាមទៅឲ្យមន្ទីរអប់រំខេត្តនិងសាលារៀនគោលដៅ ព្រមទាំងភ្ជាប់ជាមួយនូវកម្រងសំណួរនិងសំណួរសម្ភាសពេលចុះប្រមូលទិន្នន័យសម្រាប់ធ្វើការវិភាគទិន្នន័យសម្រាប់សរសេរក្នុងនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ការស្រាវជ្រាវនេះត្រូវបានចែកជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទីមួយគឺជាការ ពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធដែលមានពីមុនស្រាប់។ នៅដំណាក់កាលទីមួយនេះ អ្នកស្រាវ ជ្រាវ ព្យាយាមសិក្សាស្វែងរកឯកសារផ្សេងៗ ដែលទាក់ទងនឹងប្រធានបទហើយយកវាមកសិក្សាបន្ថែម និងយកវាជាឯកសារយោងផងដែរ។ ដំណាក់កាលទីពីរគឺជាការចុះប្រមូលព័ត៌មាន ពីអ្នកពាក់ព័ន្ធ ដោយផ្ទាល់ ។ នៅក្នុងដំណាក់កាលនេះ កម្រងសំណួរត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋាន ក្នុងការប្រមូលព័ត៌មាន។ ការយកកម្រងសំណួរទៅប្រមូលព័ត៌មានមានគោលបំណងស្វែង រកព័ត៌មាន ផ្សេងៗពីភាគីពាក់ព័ន្ធគឺចង់បានព័ត៌មានពីពួកគាត់ ។

## ៣.២.វិធីសាស្ត្រប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទៅសុំការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ដើម្បីចុះប្រមូលទិន្នន័យនៅតាមសាលាមធ្យមសិក្សាធនធានតាមគោលដៅ។ ពេលទៅដល់សាលារៀន អ្នកស្រាវជ្រាវបានបង្ហាញលិខិតឧទ្ទេសនាមបេសកកម្មចុះប្រមូលទិន្នន័យនោះទៅនាយកសាលា និងសុំការអនុញ្ញាតពីគាត់ដើម្បីធ្វើការប្រមូលទិន្នន័យ ដោយកោះអញ្ជើញគ្រូបង្រៀនទាំងអស់ប្រជុំធ្វើការ

ណែនាំក្នុងការបំពេញកម្រងសំណួរ និងធ្វើការបំពេញកម្រងសំណួរនោះ ចំណែកសិស្សានុសិស្ស អ្នកស្រាវជ្រាវសុំដោយខ្មែរ ដោយគោរពតាមក្រមសីលធម៌អ្នកស្រាវជ្រាវតាមការស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឡើយ។ ក្នុងការបំពេញកម្រងសំណួរនេះ ប្រើប្រាស់ពេលវេលាប្រហែលមួយម៉ោង។

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបចម្រុះមានទាំងបែបបរិមាណវិស័យនិងបែបគុណវិស័យ ប៉ុន្តែអ្នកស្រាវជ្រាវផ្តោតទៅលើសំណួរបែបបរិមាណវិស័យច្រើនជាង ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់ បិទ និងទម្រង់បើកដើម្បីប្រមូលទិន្នន័យពីនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍សាលាមធ្យមសិក្សាធនធាន និងពីគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅកម្រិតថ្នាក់ទី១០ ១១និងទី១២ ។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ ចែកចេញជាពីរប្រភេទគឺប្រភេទទី១សម្រាប់បំពេញដោយនាយកសាលា ឬនាយករងទទួលបន្ទុកការងារបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធ។ ប្រភេទទី២ សម្រាប់បំពេញដោយគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ មានគ្រូបង្រៀនរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងគ្រូមុខវិជ្ជាផែនដីវិទ្យា ។

## ៣.៣.ការជ្រើសរើសសំណាក

នៅក្នុងការវិភាគទិន្នន័យនេះ គឺអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យនិងគុណវិស័យ។ វិធីសាស្ត្រនេះមានការចូលរួមក្នុងការសម្ភាស និងបំពេញសម្ភាសសំណួរពីសំណាក់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូនិងភាគីពាក់ព័ន្ធ។ទាក់ទងទិន្នន័យតាមបែបបរិមាណវិស័យ គឺប្រមូលតាមរយៈការបំពេញកម្រងសំណួរបិទ និងការវិភាគទិន្នន័យតាមបែបបរិមាណវិស័យ ។ ចំណែកទិន្នន័យតាមគុណវិស័យវិញប្រមូលតាមរយៈការបំពេញកម្រងសំណួរបើក។ វិភាគទិន្នន័យបែបគុណវិស័យតាមរយៈការចាត់ថ្នាក់ជាក្រុមនិងដាក់ចំណងជើងដោយផ្អែកលើកម្រិត និងអត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលរួចធ្វើការបរិយាយនិងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

ដើម្បីធ្វើជាមូលដ្ឋានសម្រាប់សំណាកសកល (Population) និងធ្វើការជ្រើសរើសសំណាកស្រាវជ្រាវ (Sample) ដោយផ្អែកទៅតាមប្រភេទសាលាមធ្យមសិក្សាធនធានចំនួន៣ គឺប្រភេទសាលាមធ្យមសិក្សាធនធាននៅទីក្រុងចំនួន២ សាលាមធ្យមសិក្សាធនធាននៅទីប្រជុំជនចំនួន១ និងសាលាមធ្យមសិក្សាធនធាននៅជាយក្រុងចំនួន១។

ចំពោះសាលាមធ្យមសិក្សាធនធាននៅទីក្រុង អ្នកស្រាវជ្រាវកំណត់យកវិទ្យាល័យព្រះសីហនុ ស្ថិតនៅក្នុងទីរួមខេត្តកំពង់ចាម និងមួយទៀតគឺវិទ្យាល័យព្រះអង្គឌួង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ចំណែកសាលាមធ្យមសិក្សាធនធាននៅទីប្រជុំជន អ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យសម្តេចតេជោហ៊ុនសែន.សូង ដែលមានទីតាំងស្ថិតនៅក្នុងភូមិត្បូង សង្កាត់សូង ក្រុងសូង ខេត្តត្បូងឃ្មុំ។ ដោយឡែកចំពោះសាលាមធ្យមសិក្សាធនធានដែលស្ថិតនៅជាយក្រុង អ្នកស្រាវជ្រាវបានកំណត់យកវិទ្យាល័យហ៊ុនសែនកំពង់ពពិល ដែលមានទីតាំងស្ថិតនៅក្នុងភូមិកំពង់ពពិល ឃុំកំពង់ពពិស ស្រុកពារាំង ខេត្តព្រៃវែង។

អ្នកស្រាវជ្រាវកំណត់យកនាយកឬនាយករងទទួលបន្ទុកការងារបច្ចេកទេស បរិវច្ឆការីបន្ទប់ពិសោធន៍ និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ ដល់ទី១២ តាមសាលានីមួយៗទាំងអស់ជាសំណាកសកល ហើយកំណត់យកសំណាកស្រាវជ្រាវស្មើនឹងសំណាកសកល នោះកម្រិតជឿជាក់ ៩៩% និងកម្រិតលម្អៀង ១%។

តារាងទី១៖ សំណាកសកល និងសំណាកស្រាវជ្រាវសម្រាប់នាយក/នាយករងបច្ចេកទេស និងគ្រូវិទ្យាសាស្ត្របង្រៀនថ្នាក់ទី១០ដល់ថ្នាក់ទី១២។

| ល.រ | វិទ្យាល័យមធ្យមសិក្សាធនធាន | ស្រុក/ខណ្ឌ | ខេត្ត/រាជធានី | ចំនួននាយក នាយករងបច្ចេកទេស | ចំនួនបរិវច្ឆការី | ចំនួនគ្រូវិទ្យាសាស្ត្រ | ចំនួនសំណាកស្រាវជ្រាវ | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | ចំនួននាយក នាយករង ប.ទ | ចំនួនបរិវច្ឆការី | ចំនួនគ្រូ វិទ្យាសាស្ត្រ |
| ១ | វិ.សតហស.សូង | សូង | ត្បូងឃ្មុំ | ២ | ៤ | ១៥ | ១ | ៤ | ១២ |
| ២ | វិ.ព្រះសីហនុ | កំពង់ចាម | កំពង់ចាម | ២ | ៤ | ៤៤ | ១ | ៤ | ១២ |
| ៣ | វិ.ព្រះអង្គឌួង | ព្រៃវែង | ព្រៃវែង | ២ | ៤ | ១៨ | ១ | ៤ | ១២ |
| ៤ | វិ.ហស.កំពង់ពពិល | ពារាំង | ព្រៃវែង | ២ | ៤ | ១០ | ១ | ៤ | ១២ |
| សរុប | | | | ៨ | ១៦ | ៨៧ | ៤ | ១៦ | ៤៨ |

## ៣.៤.ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរចំនួន២ប្រភេទក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ កម្រងសំណួរទាំង២ប្រភេទនោះរួមមាន

ប្រភេទទី១គឺកម្រងសំណួរសម្រាប់នាយក/នាយករងនិងបរិវច្ឆការីបន្ទប់ពិសោធន៍ មាន៣ផ្នែក គឺផ្នែកទី១"ព័ត៌មានទូទៅ" តាមបែបគុណវិស័យនិងបរិមាណវិស័យ ផ្នែកទី២"កម្រិតសមត្ថភាព របស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន"តាមបែប បរិមាណវិស័យ និងផ្នែកទី៣"យោបល់បន្ថែម" តាមបែបគុណវិស័យ សម្រាប់លោកនាយក/ នាយករងទទួលបន្ទុកបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ បញ្ចេញយោបល់បន្ថែមក្នុង ការដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន។កម្រងសំណួរទី២គឺ កម្រងសំណួរសម្រាប់លោកគ្រូ-អ្នកគ្រូ បង្រៀនផ្នែកមុខវិជ្ជាវិទ្យាសាស្ត្រនិងពិសោធន៍ ដែល កំពុងបង្រៀនថ្នាក់ទី១០ដល់ថ្នាក់ទី១២ ខាងផ្នែកវិទ្យាសាស្ត្រ។ កម្រងសំណួរទី២នេះមាន៣ ផ្នែកដែរ គឺផ្នែកទី១"ព័ត៌មានទូទៅ" តាមបែបគុណវិស័យនិងបរិមាណវិស័យ ផ្នែកទី២"កម្រិត សមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន" តាម បែបបរិមាណវិស័យ និងផ្នែកទី៣"យោបល់បន្ថែម"តាមបែបគុណវិស័យ សម្រាប់លោកគ្រូ-អ្នក គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០-១២ សម្រាប់ពួកគាត់បញ្ចេញយោបល់បន្ថែមក្នុងការ ដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន។

កម្រងសំណួរទាំង២ប្រភេទនេះ ត្រូវបានបង្កើតឡើង ដោយផ្អែកលើទ្រឹស្តីនានាទាក់ទង នឹងការគ្រប់គ្រងដឹកនាំការអនុវត្តបន្ទប់ពិសោធន៍ និងការបង្រៀន-រៀននៅបន្ទប់ពិសោធន៍ ព្រមទាំងឯកសារណែនាំស្តីពីការគ្រប់គ្រងដឹកនាំ បន្ទប់ពិសោធន៍របស់អគារធនធាន នៃ ក្រសួងអប់រំ យុវជន និងកីឡា ។

## ៣.៥.កម្រងសំណួរ និងគោលបំណង

### ក.កម្រងសំណួរប្រភេទទី១

កម្រងសំណួរប្រភេទទី១ ដែលត្រូវប្រើប្រាស់សម្រាប់លោកនាយក/នាយករង និងបរិវច្ឆការី បន្ទប់ពិសោធន៍របស់សាលាមធ្យមសិក្សាធនធានចែកចេញជា៣ផ្នែកគឺៈ

- ផ្នែកទី១ ៖ "ព័ត៌មានទូទៅ" ចាប់ពីសំណួរទី១ដល់ទី៩ តាមបែបបរិមាណវិស័យ និង គុណវិស័យ
- ផ្នែកទី២៖ "កម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់អគារធនធាន" មាន២២សំណួរ តាមបែបបរិមាណវិស័យ ចែកជា៤ផ្នែកតូចៗទៀត គឺផ្នែកទី១"ការ គ្រប់គ្រងបន្ទប់ពិសោធន៍"ចាប់ពីសំណួរទី១ដល់ទី៧ផ្នែកទី២"ក្របខណ្ឌសមត្ថភាព បច្ចេកទេស"ចាប់ពីសំណួរទី៨ដល់១២ ផ្នែកទី៣"កិច្ចគាំទ្រការបង្រៀន និងរៀន"

ចាប់ពីសំណួរទី១៣ដល់១៧ និងផ្នែកទី៤"កិច្ចសហប្រតិបត្តិការ" ចាប់ពីសំណួរទី១៨ដល់២២។

- ផ្នែកទី៣ ៖"យោបល់បន្ថែម" តាមបែបគុណវិស័យ មានពីរសំណួរ គឺសំណួរទី១និងទី២ សម្រាប់លោកនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍របស់សាលាមធ្យមសិក្សាធនធាន គាត់បញ្ចេញយោបល់បន្ថែម ក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន។

**ខ.កម្រងសំណួរប្រភេទទី២**

កម្រងសំណួរប្រភេទទី២ ដែលត្រូវប្រើប្រាស់សម្រាប់លោកគ្រូ-អ្នកគ្រូបង្រៀនថ្នាក់ទី១០ដល់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្ររបស់សាលាមធ្យមសិក្សាធនធាន ចែកចេញជា៣ផ្នែកគឺ៖

- ផ្នែកទី១ ៖ "ព័ត៌មានទូទៅ" ចាប់ពីសំណួរទី១ដល់ទី៩ តាមបែបបរិមាណវិស័យ និងគុណវិស័យ
- ផ្នែកទី២៖ "កម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់អគារធនធាន" មាន២៣សំណួរ តាមបែបបរិមាណវិស័យ ចែកជា៣ផ្នែកតូចៗទៀត គឺផ្នែកទី១"ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍"ចាប់ពីសំណួរទី១ដល់ទី១០ ផ្នែកទី២"ចំណេះដឹងសមត្ថភាព" ចាប់ពីសំណួរទី១១ដល់១៦ និងផ្នែកទី៣"ការលើកទឹកចិត្ត" ចាប់ពីសំណួរទី១៧ដល់២៣។
- ផ្នែកទី៣ ៖"យោបល់បន្ថែម" តាមបែបគុណវិស័យ មានពីរសំណួរ គឺសំណួរទី១និងទី២ សម្រាប់លោកគ្រូ-អ្នកគ្រូបង្រៀនថ្នាក់ទី១០ដល់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្ររបស់សាលាមធ្យមសិក្សាធនធាន គាត់បញ្ចេញយោបល់បន្ថែម ក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន។

## ៣.៦ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ក្នុងការប្រមូលទិន្នន័យ ។ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យ គឺបានផ្តល់កម្រងសំណួរ (សំណួរបិទ) ដែលបានរៀបចំទុកជាមុនស្របតាមគោលបំណងនៃការស្រាវជ្រាវដល់នាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ លោកគ្រូ/អ្នកគ្រូ បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ ១១ និងថ្នាក់ទី១២ ដោយមានការសម្របសម្រួលផ្ទាល់ពីអ្នកស្រាវជ្រាវ ។ ចំណែកឯ

ទិន្នន័យសម្រាប់គុណវិស័យវិញ គឺបានផ្តល់កម្រងសំណួរ (សំណួរបើក) ដល់នាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ លោកគ្រូ/អ្នកគ្រូ បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ ១១ និងថ្នាក់ទី១២ ដោយមានការសម្ភាសបន្ថែមផ្ទាល់ជាមួយលោកនាយក/នាយករងគ្រប់សាលា ស្តីពី ទី១) ការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន ទី២) បញ្ហាប្រឈមនិងសំណូមពរ ឬអនុសាសន៍ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

## ៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងដោយអ្នកស្រាវជ្រាវបានធ្វើការទាក់ទងសុំការអនុញ្ញាតជាមុនពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងគ្រឹះស្ថានសិក្សា ដែលជាគោលដៅនៃការសិក្សាស្រាវជ្រាវនេះ ។ ជាដំបូង អ្នកសិក្សាបានជួបជាមួយប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយយកទៅជាមួយនូវលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡាលេខ ៦៥២០ អយក.វជអ ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១៩ និងចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ផ្ញើជូនលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ស្តីពីការ ចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមសាកលវិទ្យាល័យ និងរាជធានី ខេត្ត និងលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ៩៦៣៣ អយក.ឧទន ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ស្តីពីការចាត់តាំងឱ្យនិស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន ១៣ នាក់ ចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ ទៅជាមួយផង ។

បន្ទាប់ពីបានការអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរួចមក អ្នកស្រាវជ្រាវក៏បានថតចម្លងលិខិតទាំងពីររបស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតអនុញ្ញាតរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដាក់ជូនដល់ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក នៅគ្រប់ស្រុកដែលជាគោលដៅជាមុនៗចុះទៅប្រមូលទិន្នន័យនៅតាមគ្រឹះស្ថានសិក្សាក្នុងស្រុកនីមួយៗ ។ បន្ទាប់ពីដាក់លិខិតជូនប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុករួចមក អ្នកសិក្សាស្រាវជ្រាវបានធ្វើការទាក់ទងតាមទូរស័ព្ទដោយផ្ទាល់ជាមួយនាយក/នាយករងគ្រប់សាលាគោលដៅ ដើម្បីជម្រាបជូនពួកគាត់ពីគោលបំណងនៃការសិក្សា

ស្រាវជ្រាវ ហើយក៏បានធ្វើការណាត់ជួប និងសុំកិច្ចសហការណ៍ ដោយកំណត់ថ្ងៃខែ និងក្រុមគោលដៅដែលត្រូវជួបជាមុន ។

នៅថ្ងៃចុះប្រមូលទិន្នន័យ អ្នកសិក្សាបានទៅដល់សាលាគោលដៅតាមកាលកំណត់ ដោយដំបូងជួបជារួមជាមួយនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍ ដោយជូនលិខិតអនុញ្ញាត និងជម្រាបជូនពួកគាត់ពីគោលបំណងនៃកាសិក្សាស្រាវជ្រាវបន្ថែមម្តងទៀត និងសុំឱ្យពួកគាត់ជួយឆ្លើយកម្រងសំណួរ ។ ក្រោយមក អ្នកសិក្សាបានជួបដាច់ដោយឡែកជាមួយនាយក/នាយករង ដើម្បីសម្ភាសបន្ថែមលើបញ្ហាមួយចំនួនដែល ពាក់ព័ន្ធនឹងប្រធានបទនៃការស្រាវជ្រាវនេះ ។ ជាចុងក្រោយ អ្នកសិក្សាជួបជាមួយលោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ នៅបន្ទប់រួមមួយដែលមានគ្រូចម្រុះគ្នាថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ដែលគណៈគ្រប់គ្រងសាលាបានរៀបចំចាត់ចែងឱ្យ និងបានជម្រាបជូនពួកគេពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងសុំឱ្យពួកគេជួយបំពេញកម្រងសំណួរ ដោយមានការពន្យល់ និងណែនាំពីរបៀបឆ្លើយយ៉ាងល្អិតល្អន់មុននឹងឱ្យពួកគេឆ្លើយសំណួរ ។ ក្រោយពីក្រុមគោលដៅបំពេញកម្រងសំណួរចប់សព្វគ្រប់ អ្នកសិក្សាបានប្រមូលកម្រងសំណួរ និងចម្លើយដែលបានពីការសម្ភាសនាយក/នាយករងមកធ្វើការវិភាគទិន្នន័យ ។

## ៣.៨.ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យបែបបរិមាណវិស័យត្រូវធ្វើឡើង ដោយលទ្ធផលនៃចម្លើយនឹងត្រូវរៀបទៅតាមតារាងដែលត្រូវស្រង់ចេញពីកម្មវិធី SPSS ហើយធ្វើការវិភាគទៅលើតារាងនីមួយៗ ដោយត្រូវវិភាគលើសំណួរដែលមាន ហើយរកតម្លៃមធ្យម ផ្តល់ចំណាត់ថ្នាក់ទៅតាមតម្លៃមធ្យម (M) និងពិនិត្យមើលគម្លាតស្តង់ដារ (SD) ដើម្បីពិនិត្យមើលថាតើតម្លៃមធ្យមដែលរកឃើញនោះ មានកម្រិតខុសគ្នាអាចទទួលបានឬទេ (statistically signification)។ ម្យ៉ាងទៀតការវិភាគទិន្នន័យបែបគុណវិស័យ ត្រូវធ្វើទៅតាមកម្រងសំណួរទម្រង់បើក ដែលភ្ជាប់ជាមួយនឹងសំណួរទម្រង់បិទនៅក្នុងកម្រងសំណួរសម្រាប់លោកនាយក/នាយករង និងបរិវច្ឆការី និងលោកគ្រូ-អ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្របង្រៀនថ្នាក់ទី១០ដល់ទី១២ទាំងអស់ចំនួន៦៨នាក់ ។ អ្នកស្រាវជ្រាវវិភាគលើចម្លើយដែលបានមកពីសំណួរទម្រង់បើកចំនួន៦៨ របស់កម្រងសំណួរទាំងពីរប្រភេទ ដោយធ្វើការស្រង់ពាក្យពេចន៍ក្នុងចម្លើយដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីទាញព័ត៌មានបន្ថែមពីការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន និងទាញសេចក្តីសន្និដ្ឋាន។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនៃការវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និងការសម្ភាសនាយក/នាយករងបច្ចេកទេស បរិវច្ឆការីបន្ទប់ពិសោធន៍ និងគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ដើម្បីឱ្យដឹងថាតើការប្រើប្រាស់បន្ទប់ពិសោធន៍នៅវិទ្យាល័យសាលាមធ្យមសិក្សាធនធាន ក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង មានប្រសិទ្ធផលបែបណា ទាំងអ្នកគ្រប់គ្រងដឹកនាំ និងអ្នកចូលទៅអនុវត្ត ហើយម្យ៉ាងទៀតថាតើទាំងអ្នកគ្រប់គ្រងដឹកនាំនិងអ្នកអនុវត្តបន្ទប់ពិសោធន៍ នៅក្នុងខេត្តទាំង៣ខាងលើមានបញ្ហាប្រឈមអ្វីខ្លះ និងថាតើពួកគាត់មានអនុសាសន៍ ឬសំណូមពរយ៉ាងណាក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ ។

## ៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរទី១

### ៤.១.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកសាលាមធ្យមសិក្សាធនធានចំនួន ៤ ស្ថិតនៅក្នុងខេត្តចំនួន៣ គឺខេត្ត ត្បូងឃ្មុំ សាលាមធ្យមសិក្សាធនធានចំនួន១ ខេត្តកំពង់ចាម សាលាមធ្យមសិក្សាធនធានចំនួន១ និងខេត្ត ព្រៃវែង សាលាមធ្យមសិក្សាធនធានចំនួន២ ជាគោលដៅនៃការសិក្សាស្រាវជ្រាវ។ ក្នុងចំណោមសាលាមធ្យមសិក្សាធនធានទាំង៤ រួមមានសាលាមធ្យមសិក្សាធនធានចំនួន២ ស្ថិតនៅក្នុងក្រុង(ទីរួមខេត្ត) សាលាមធ្យមសិក្សាធនធានចំនួន១ស្ថិតនៅទីប្រជុំជន និងសាលាមធ្យមសិក្សាធនធានចំនួន១ស្ថិតនៅជាយក្រុង។

តាមការគ្រោងទុកទំហំនៃភាគសំណាក អ្នកស្រាវជ្រាវបានកំណត់យកក្នុង១សាលាមធ្យមសិក្សាធនធាន ១៥នាក់ គឺលោកនាយក ឬនាយករងបច្ចេកទេស១ បរិវច្ឆការីបន្ទប់ពិសោធន៍៤មុខវិជ្ជា ចំនួន៤នាក់ និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤មុខវិជ្ជា ចំនួន១២នាក់ (១មុខវិជ្ជា៣នាក់) សរុបទាំងអស់១៧នាក់ ក្នុង១សាលាមធ្យមសិក្សាធនធាន។ នៅពេលដែលអ្នកស្រាវជ្រាវចុះទៅទំនាក់ទំនងសុំការសហការពីលោកនាយក/នាយករងបច្ចេកទេស ទើបដឹងថាមានសាលាមធ្យមសិក្សាធនធាន១ខ្វះគ្រូបង្រៀន និងសាលាមធ្យមសិក្សាធនធានមួយទៀតលើសគ្រូបង្រៀន ដូច្នេះអ្នកស្រាវជ្រាវសម្រេចទូទាត់សំណាកស្រាវជ្រាវរវាង សាលាមធ្យមសិក្សាធនធានដែលខ្វះគ្រូ និងសាលាមធ្យមសិក្សាធនធានដែលលើសគ្រូ ដើម្បីបង្គ្រប់ឱ្យសំណាកស្រាវជ្រាវនៅចំនួន៦៨ដដែល។

តារាង៤.១៖ ចំនួនគណៈគ្រប់គ្រងគិតតាមភេទ អាយុ កម្រិតវប្បធម៌ ក្របខណ្ឌ និងបទពិសោធន៍

| ល.រ | បរិយាយ | | ត្បូងឃ្មុំ | កំពង់ចាម | ព្រៃវែង | ព្រៃវែង | សរុប | |
|---|---|---|---|---|---|---|---|---|
| | | | វិ.សតហស សួង | វិទ្យាល័យ ព្រះសីហនុ | វិទ្យាល័យ ព្រះអង្គឌួង | វិទ្យាល័យ កំពង់ពពិល | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 4 | 3 | 2 | 4 | 13 | 65.0% |
| | | ស្រី | 1 | 3 | 3 | 0 | 7 | 35.0% |
| | | សរុប | 5 | 6 | 5 | 4 | 20 | 100.0% |
| ២ | អាយុ | 20-30 ឆ្នាំ | 4 | 0 | 0 | 0 | 4 | 20.0% |
| | | 31-40 ឆ្នាំ | 0 | 2 | 0 | 0 | 2 | 10.0% |
| | | 41-50 ឆ្នាំ | 1 | 4 | 4 | 4 | 13 | 65.0% |
| | | លើស50 ឆ្នាំ | 0 | 0 | 1 | 0 | 1 | 5.00% |
| | | សរុប | 5 | 6 | 5 | 4 | 20 | 100.0% |
| ៣ | កម្រិតវប្បធម៌ | ម.ទ.ភ | 0 | 4 | 4 | 1 | 9 | 45.00% |
| | | បរិញ្ញាបត្រ | 4 | 2 | 0 | 1 | 7 | 35.00% |
| | | បរិ.ជាន់ខ្ពស់ | 1 | 0 | 1 | 2 | 4 | 20.00% |
| | | សរុប | 5 | 6 | 5 | 4 | 20 | 100.0% |
| ៤ | ក្របខណ្ឌគ្រូបង្រៀន | កម្រិតមូលដ្ឋាន | 0 | 4 | 4 | 1 | 9 | 45.00% |
| | | កម្រិតឧត្តម | 5 | 2 | 1 | 3 | 11 | 55.00% |
| | | សរុប | 5 | 6 | 5 | 4 | 20 | 100.0% |
| ៥ | បទពិសោធន៍ជាគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន | 1-3 ឆ្នាំ | 3 | 1 | 0 | 1 | 5 | 25.00% |
| | | 4-6 ឆ្នាំ | 2 | 3 | 3 | 1 | 9 | 45.00% |
| | | 7-9 ឆ្នាំ | 0 | 0 | 0 | 1 | 1 | 05.00% |
| | | 10 ឆ្នាំឡើង | 0 | 2 | 2 | 1 | 5 | 25.00% |
| | | សរុប | 5 | 6 | 5 | 4 | 20 | 100.0% |

តាមរយៈលទ្ធផលនៅតារាងទី៤.១ បានបង្ហាញថាភាគរយភេទនៃនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍ នៅតាមសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មានបុរសចំនួន១៣នាក់ ស្មើនឹង ៦៥% នៃសមាមាត្រសរុប ១០០%។ តាមរយៈលទ្ធផលក្នុងតារាងនេះ ក៏បង្ហាញឱ្យឃើញដែរថា ភាគរយអាយុ នៃនាយក/នាយករង

និងបរិវច្ឆការីបន្ទប់ពិសោធន៍ នៅតាមសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង អាយុនៅចន្លោះពី៤១-៥០ឆ្នាំមានចំនួនច្រើនជាងគេគឺរហូតដល់៦៥% និងអាយុចាប់ពី៥០ឆ្នាំឡើងមានចំនួនតិចជាងគេគឺ៥% នៃសមាមាត្រសរុប ១០០%។ ជាមួយគ្នានេះដែរ តារាងក៏បានបង្ហាញថា ភាគរយកម្រិតវប្បធម៌ នៃនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍ នៅតាមសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងព្រៃវែង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានចំនួនច្រើនជាងគេគឺ ៤៥% និងបរិញ្ញាបត្រជាន់ខ្ពស់មានចំនួនតិចជាងគេគឺ២០% នៃសមាមាត្រសរុប ១០០%។ ម្យ៉ាងទៀតតាមរយៈតារាងនេះ ក៏បានបង្ហាញថា ភាគរយគ្រូកម្រិតមូលដ្ឋាន និងគ្រូកម្រិតឧត្តម នៃនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍ នៅតាមសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មានចំនួនលម្អៀងគ្នាបន្តិច គឺគ្រូកម្រិតមូលដ្ឋាន៤៥% និងគ្រូកម្រិតឧត្តម៥៥% នៃសមាមាត្រសរុប ១០០%។ ចំណែកឯបទពិសោធន៍ជាគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាននៃនាយក/នាយករង និងបរិវច្ឆការីបន្ទប់ពិសោធន៍ នៅតាមសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង ចាប់ពី៤-៦ឆ្នាំ មានចំនួន៩នាក់ច្រើនជាងគេ ស្មើនឹង៤៥% ហើយបទពិសោធន៍ចាប់ពី៧-៩ឆ្នាំ មានចំនួនតែម្នាក់គឺស្មើនឹង៥%។

### ៤.១.២ កម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់អគារធនធាន

នៅក្នុងចំណុចនេះ យើងសង្កេតឃើញថា អ្នកឆ្លើយសំណួរក្នុងកម្រិតនៃការអនុវត្តបានមធ្យម មានចំនួនច្រើនជាងគេគឺ២៨.៤១% បន្ទាប់មកកម្រិតនៃការអនុវត្តបានច្រើនមានចំនួន២៧.៩៦% ចំនែកឯកម្រិតនៃការអនុវត្តបានច្រើនបំផុតមានចំនួន២៦.៥៩%។ មួយវិញទៀតកម្រិតនៃការអនុវត្តបានតិចមានចំនួន១៣.១៨% និងចុងក្រោយកម្រិតនៃការអនុវត្តបានតិចបំផុត មានចំនួនតែ៣.៨៦%ប៉ុណ្ណោះ។ តាមរយៈតារាងបង្ហាញថា ក្នុងចំណោមលោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ចំនួន២០នាក់ បានឆ្លើយសំណួរទាំង២២ ដោយជ្រើសរើសយកកម្រិតទី៣"អនុវត្តបានមធ្យម" មានភាគរយច្រើនជាងគេ និងជ្រើសរើសយកកម្រិតទី១"អនុវត្តបានតិចបំផុត"មានភាគរយតិចជាងគេ។

*តារាង៤.២.ចំនួនអ្នកឆ្លើយតបសំណួរតាមកម្រិតនៃការអនុវត្ត*

| ល.រ | សំណួរស្តីពីកម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | |
|---|---|---|---|---|---|---|
| | | តិចបំផុត | តិច | មធ្យម | ច្រើន | ច្រើនបំផុត |
| ១. | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | 1 | 4 | 3 | 3 | 9 |
| ២ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលគ្រូ ទាក់ទងការងារបន្ទប់ពិសោធន៍ | 1 | 6 | 8 | 4 | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 0 | 1 | 9 | 5 | 5 |
| ៤ | ធ្វើឱ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់ | 0 | 3 | 7 | 9 | 1 |
| ៥ | ស្វែងរកប្រាក់ចំណូល-ថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | 2 | 7 | 6 | 4 | 1 |
| ៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | 1 | 3 | 7 | 5 | 4 |
| ៧ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | 0 | 0 | 3 | 8 | 9 |
| ៨. | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 2 | 1 | 8 | 5 | 4 |
| ៩ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 0 | 0 | 5 | 7 | 8 |
| ១០ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ | 1 | 1 | 3 | 5 | 10 |
| ១១ | ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 0 | 1 | 7 | 7 | 5 |
| ១២ | មានកាលវិភាគថ្នាក់-គ្រូនៅមុខបន្ទប់ពិសោធន៍ | 0 | 3 | 3 | 6 | 8 |
| ១៣. | មានការគាំទ្រនិងលើកទឹកចិត្តគ្រូ-សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | 0 | 1 | 6 | 7 | 6 |
| ១៤ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | 0 | 3 | 4 | 6 | 7 |
| ១៥ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | 2 | 7 | 10 | 1 | 0 |
| ១៦ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ-អ្នកគ្រូ | 2 | 5 | 5 | 4 | 4 |
| ១៧ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | 4 | 5 | 6 | 4 | 1 |
| ១៨. | សាលាមធ្យមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 0 | 2 | 7 | 4 | 7 |
| ១៩ | បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 0 | 2 | 6 | 5 | 7 |
| ២០ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | 0 | 0 | 5 | 7 | 8 |
| ២១ | ចែករំលែក ធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | 0 | 0 | 6 | 8 | 6 |
| ២២ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 1 | 3 | 1 | 9 | 6 |
| | ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ | 03.86 % | 13.18 % | 28.41% | 27.96% | 26.59% |

អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ ដោយប្រើកម្មវិធី SPSS Version 25. ដើម្បីធ្វើការវិភាគទិន្នន័យតាមបែបពណ៌នាស្ថិតិ (Descriptive Statistics) រកតម្លៃមធ្យម (M) រកតម្លៃគម្លាតស្តង់ដារ (SD) និងកម្រិត (Level) ដើម្បីស្វែងយល់ចំពោះចម្ងល់ទី១។ កម្រិតនៃចម្លើយជ្រើសរើសមាន៥កម្រិត ក្នុង១សំណួរ គឺកម្រិតទី១ កម្រិតទី២ កម្រិតទី៣ កម្រិតទី៤ និងកម្រិតទី៥ ហើយអ្នកឆ្លើយជ្រើសរើសយកតែមួយគត់ ក្នុងចំណោមជម្រើសទាំង ៥។ តាមទ្រឹស្តី Likert $\frac{Hihgestlevel - Lowestlevel}{TotalLevel} = \frac{5-1}{5} = \frac{4}{5} = 0.80$ ។ មធ្យមភាគនៅចន្លោះពី ១ទៅ១.៨០ អនុវត្តបានតិចបំផុត, មធ្យមភាគនៅចន្លោះពី១.៨១ទៅ២.៦០ អនុវត្តបានតិច, មធ្យមភាគនៅចន្លោះពី២.៦១ទៅ៣.៤០ អនុវត្តបានមធ្យម, មធ្យមភាគនៅចន្លោះពី៣.៤១ទៅ៤.២០ អនុវត្តបានច្រើន ,មធ្យមភាគនៅចន្លោះពី៤.២១ទៅ៥.០០ អនុវត្តបានច្រើនបំផុត។

***តារាង៤.៣ ស្តីពីតម្លៃមធ្យម(M)តម្លៃគម្លាតស្តង់ដារ(SD)និងកម្រិតសមត្ថភាពក្នុងការប្រើប្រាស់***

| ល.រ | កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន | M | SD | Level |
|---|---|---|---|---|
| ១. | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | 3.75 | 1.37 | ល្អ |
| ២ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលគ្រូ ទាក់ទងការងារបន្ទប់ពិសោធន៍ | 2.90 | 0.96 | មធ្យម |
| ៣ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 3.70 | 0.92 | ល្អ |
| ៤ | ធ្វើឱ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់ | 3.40 | 0.82 | មធ្យម |
| ៥ | ស្វែងរកប្រាក់ចំណូល-ថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | 2.75 | 1.07 | មធ្យម |
| ៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | 3.40 | 1.14 | មធ្យម |
| ៧ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | 4.30 | 0.73 | ល្អ |
| ៨. | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 3.40 | 1.19 | មធ្យម |
| ៩ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 4.15 | 0.81 | ល្អ |
| ១០ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ | 4.10 | 1.17 | ល្អ |
| ១១ | ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 3.80 | 0.90 | ល្អ |
| ១២ | មានកាលវិភាគថ្នាក់-គ្រូនៅមុខបន្ទប់ពិសោធន៍ | 3.95 | 1.10 | ល្អ |
| ១៣. | មានការគាំទ្រនិងលើកទឹកចិត្តគ្រូ-សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | 3.90 | 0.91 | ល្អ |
| ១៤ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | 3.85 | 1.09 | ល្អ |
| ១៥ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | 2.50 | 0.76 | មធ្យម |
| ១៦ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ-អ្នកគ្រូ | 3.15 | 1.30 | មធ្យម |
| ១៧ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | 2.65 | 1.18 | មធ្យម |
| ១៨. | សាលាមធ្យមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 3.80 | 1.06 | ល្អ |

| | | | | |
|---|---|---|---|---|
| ១៩ | បានបង្កបរិយាកាស ឱកាតីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 3.85 | 1.04 | ល្អ |
| ២០ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | 4.15 | 0.81 | ល្អ |
| ២១ | ចែករំលែក ធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | 4.00 | 0.79 | ល្អ |
| ២២ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 3.80 | 1.20 | ល្អ |
| | សរុប | 3.61 | 0.76 | ល្អ |

តាមតារាង៤.៣ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដារ និងកម្រិតនៃសំណួរបែបបរិមាណវិស័យទាំង២២សំណួរ ទៅលើកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន។ បើយោងតាមលទ្ធផលនៃតារាងខាងលើ បង្ហាញថាសំណួរចំនួន១៤មានតម្លៃមធ្យមកម្រិតខ្ពស់ គឺមានន័យថាអនុវត្តបានច្រើន (គឺសំណួរទី១,៣,៧,៩,១០, ១១, ១២,១៣,១៤,១៨,១៩,២០,២១និង២២) រីឯកម្រិតមធ្យមមានចំនួន៨ គឺមានន័យថាអនុវត្តបានមធ្យម(គឺសំណួរទី២,៤,៥,៦,៨,១៥,១៦និង១៧)។ សំណួរដែលឈរនៅលំដាប់ទី១ គឺសំណួរទី៧ ដែលលើកឡើងថា״ បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច״ (M=4.30, SD=0.73) គឺមានតម្លៃមធ្យមខ្ពស់ជាងគេបំផុត។ ចំណាត់ថ្នាក់ទី២បានទៅសំណួរទី៩״មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង״ និងសំណួរទី២០״បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ״ គឺមានតម្លៃមធ្យមនិងតម្លៃគម្លាតស្តង់ដារដូចគ្នា(M=4.15, SD=0.81)។ បន្ទាប់មក មានចំណាត់ជាបន្តបន្ទាប់រហូតដល់សំណួរដែលមានតម្លៃមធ្យមទាបជាងគេបំផុត គឺសំណួរទី១៥ ដែលបានលើកឡើងថា״បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់״ (M=2.50, SD=0.76) ។ ជារួម កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន មានតម្លៃមធ្យមកម្រិតខ្ពស់គឺ(M=3.61, SD=0.76) គឺមានន័យថា ពួកគាត់អនុវត្តបានច្រើន ប៉ុន្តែបើយោងទៅតាមតម្លៃមធ្យម អ្នកស្រាវជ្រាវរកឃើញថា អនុវត្តបានច្រើនកម្រិតទាប ពោលគឺដំណើរការគ្រប់គ្រងរបស់លោកនាយក-នាយករងបច្ចេកទេស និងបរិវច្ឆការីក្នុងបន្ទប់ពិសោធន៍ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន នៅមានកម្រិតនៅឡើយ។ ការគ្រប់គ្រងរបស់លោកនាយកនៅមានកម្រិត ហើយការចូលមកប្រើប្រាស់អគារធនធានរបស់សាលាបណ្តាញ រិតតែមានកម្រិតទៀត។ ចំណែកឯសម្ភារៈពិសោធន៍មានការខ្វះខាតច្រើនណាស់ ជាពិសេសសារធាតុគីមីមានតម្លៃថ្លៃ ហើយពិបាករកទិញទៀត។

អ្នកស្រាវជ្រាវបានបែងចែកនៃកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាននោះទៅជា៤ប្រភេទ៖ក.ការគ្រប់គ្រងបន្ទប់ពិសោធន៍

ខ.ក្របខណ្ឌសមត្ថភាពបច្ចេកទេស គ.កិច្ចគាំទ្រការបង្រៀននិងរៀន ឃ.កិច្ចសហប្រតិបត្តិការ និងវិភាគលទ្ធផលនៃកម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ របស់អគារធនធាន ដូចខាងក្រោម៖

***តារាង៤.៤ ផ្នែកទាំង៤នៃកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍***

| ល.រ | **ក.ការគ្រប់គ្រងបន្ទប់ពិសោធន៍** | M | SD | Level |
|---|---|---|---|---|
| ១. | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | 3.75 | 1.37 | ល្អ |
| ២ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលគ្រូ ទាក់ទងការងារបន្ទប់ពិសោធន៍ | 2.90 | 0.96 | មធ្យម |
| ៣ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 3.70 | 0.92 | ល្អ |
| ៤ | ធ្វើឱ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់ | 3.40 | 0.82 | មធ្យម |
| ៥ | ស្វែងរកប្រាក់ចំណូល-ថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | 2.75 | 1.07 | មធ្យម |
| ៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | 3.40 | 1.14 | មធ្យម |
| ៧ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | 4.30 | 0.73 | ល្អណ |
| | សរុប | 3.45 | 0.76 | ល្អ |
| ល.រ | **ខ.ក្របខណ្ឌសមត្ថភាពបច្ចេកទេស** | M | SD | Level |
| ៨. | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 3.40 | 1.19 | មធ្យម |
| ៩ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 4.15 | 0.81 | ល្អ |
| ១០ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ | 4.10 | 1.17 | ល្អ |
| ១១ | ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 3.80 | 0.90 | ល្អ |
| ១២ | មានកាលវិភាគថ្នាក់-គ្រូនៅមុខបន្ទប់ពិសោធន៍ | 3.95 | 1.10 | ល្អ |
| | សរុប | 3.88 | 0.81 | ល្អ |
| ល.រ | **គ.កិច្ចគាំទ្រការបង្រៀន និងរៀន** | M | SD | Level |
| ១៣. | មានការគាំទ្រនិងលើកទឹកចិត្តគ្រូ-សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | 3.90 | 0.91 | ល្អ |
| ១៤ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធ | 3.85 | 1.09 | ល្អ |
| ១៥ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | 2.50 | 0.76 | មធ្យម |
| ១៦ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ-អ្នកគ្រូ | 3.15 | 1.30 | មធ្យម |
| ១៧ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | 2.65 | 1.18 | មធ្យម |
| | សរុប | 3.21 | 0.83 | មធ្យម |
| ល.រ | **ឃ.កិច្ចសហប្រតិបត្តិការ** | M | SD | Level |
| ១៨. | សាលាមធ្យមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 3.80 | 1.06 | ល្អ |
| ១៩ | បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 3.85 | 1.04 | ល្អ |
| ២០ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | 4.15 | 0.81 | ល្អ |
| ២១ | ចែករំលែក ធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | 4.00 | 0.79 | ល្អ |
| ២២ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 3.80 | 1.20 | ល្អ |
| | សរុប | 3.92 | 0.84 | ល្អ |

តាមតារាងទិន្នន័យ៤.៤ បានបង្ហាញពីមធ្យមភាគសរុបផ្នែក ក"ការគ្រប់គ្រងបន្ទប់ពិសោធន៍" របស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ក្នុងអគារធនធាននៃសាលាមធ្យមសិក្សាធនធាន ស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង បានទទួលលទ្ធផលក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤៥) គឺនៅលើកម្រិត "មធ្យម"តែបន្តិចទេ។ សូចនាករ "បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍តាមតួនាទី និងភារកិច្ច" ទទួលបានការយល់ស្របច្រើនជាងគេទៅលើ ការគ្រប់គ្រងបន្ទប់ពិសោធន៍ ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣០) និងសូចនាករ "ស្វែងរកប្រាក់ចំណូល-ថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=២.៧៥)។

ផ្នែក ខ "ក្របខណ្ឌសមត្ថភាពបច្ចេកទេស" របស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ ក្នុងអគារធនធាននៃសាលាមធ្យមសិក្សធនធាន ស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង បានទទួលលទ្ធផលក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៨៨)។ សូចនាករ "មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង" ទទួលបានការយល់ស្របច្រើនជាងគេទៅលើក្របខណ្ឌសមត្ថភាពបច្ចេកទេស ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.១៥) និងសូចនាករ "ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្រ្ត ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.៤០)។

ផ្នែក គ "កិច្ចគាំទ្រការបង្រៀន និងរៀន" របស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ ក្នុងអគារធនធាននៃសាលាមធ្យមសិក្សធនធាន ស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង បានទទួលលទ្ធផលក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.២១)។ សូចនាករ "មានការគាំទ្រនិងលើកទឹកចិត្តគ្រូ-សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍" ទទួលបានការយល់ស្របច្រើនជាងគេទៅលើកិច្ចគាំទ្រការបង្រៀន និងរៀន ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩០) និងសូចនាករ "បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=២.៥០)។

ផ្នែក ឃ "កិច្ចសហប្រតិបត្តិការ" របស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ ក្នុងអគារធនធាននៃសាលាមធ្យមសិក្សធនធាន ស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង បានទទួលលទ្ធផលក្នុងកម្រិត "ល្អ" (មធ្យមភាគ

ពិន្ទុ=៣.៩២)។ សូចនាករ "បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្ដាញ" ទទួលបានការយល់ស្របច្រើនជាងគេទៅលើកិច្ចគាំទ្រការបង្រៀន និងរៀន ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.១៥) និងសូចនាករ "សាលាមធ្យមសិក្សាបណ្ដាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.៨០)។

ជារួមយោងតាមតារាងខាងលើបង្ហាញថា ផ្នែកទាំងបួននៃកម្រិតសមត្ថភាពរបស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធន មានតម្លៃមធ្យមខុសៗគ្នា។ លំដាប់ពិន្ទុលើផ្នែកទី៤"កិច្ចសហប្រតិបត្តិការ" ស្ថិតក្នុងកម្រិតខ្ពស់លំដាប់លេខ១គឺ M=3.92, SD=0.84 ផ្នែកទី២"ក្របខណ្ឌសមត្ថភាពបច្ចេកទេស" ស្ថិតក្នុងកម្រិតខ្ពស់លំដាប់លេខ២ M=3.88, SD=0.81 ផ្នែកទី១"ការគ្រប់គ្រងបន្ទប់ពិសោធន៍" ស្ថិតក្នុងកម្រិតខ្ពស់លំដាប់លេខ៣ M=3.45, SD=0.76 និងផ្នែកទី៣"កិច្ចគាំទ្រការបង្រៀននិងរៀន" ស្ថិតក្នុងកម្រិតមធ្យមលំដាប់លេខ៤ M=3.21, SD=0.83 ។ ជារួមឃើញថា កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន មានតម្លៃមធ្យមកម្រិតខ្ពស់គឺ(M=3.61, SD=0.76)។

***តារាង៤.៥ ផ្នែកទាំង៤នៃកម្រិតសមត្ថភាពរបស់លោក លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍***

| ល.រ | កម្រិតសមត្ថភាពរបស់លោក លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ | M | SD | Level |
|---|---|---|---|---|
| ១ | **ការគ្រប់គ្រងបន្ទប់ពិសោធន៍** | 3.45 | 0.76 | ល្អ |
| ២ | **ក្របខណ្ឌសមត្ថភាពបច្ចេកទេស** | 3.88 | 0.81 | ល្អ |
| ៣ | **កិច្ចគាំទ្រការបង្រៀន និងរៀន** | 3.21 | 0.83 | មធ្យម |
| ៤ | **កិច្ចសហប្រតិបត្តិការ** | 3.92 | 0.84 | ល្អ |
| | សរុប | 3.61 | 0.76 | ល្អ |

យោងតាមលទ្ធផលនៃតារាង៤.៥ខាងលើ "កិច្ចសហប្រតិបត្តិការ" ស្ថិតក្នុងចំណាត់ទី១ ដែលមាន M=3.92, SD=0.84។ ចំណុចនេះ ដោយសារតែទាំងគណៈគ្រប់គ្រងនិងបរិវច្ឆការីយល់ថា "សាលាមធ្យមសិក្សាបណ្ដាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍" (តារាងទី២សំណួរទី១៨) ក្នុងចំណោមគណៈគ្រប់គ្រងចំនួន២០នាក់ បានជ្រើសរើសយកកម្រិតទី៤ គឺអនុវត្តបានច្រើនចំនួន៩នាក់ និងជ្រើសរើសយកកម្រិតទី៥ គឺអនុវត្តបានច្រើនបំផុត ចំនួន៧នាក់។ម្យ៉ាងទៀតសំណួរទី១៩"បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធអាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន" ក្នុងចំណោមគណៈគ្រប់គ្រងដដែល បានជ្រើសរើសយកកម្រិតទី៤គឺអនុវត្តបានច្រើនចំនួន៥នាក់ និងជ្រើសរើសយកកម្រិតទី៥ គឺអនុវត្តបានច្រើនបំផុត ចំនួន៧នាក់។

ចំណែកសំណួរទី២០ ″បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍របស់សាលាបណ្ដាញ″ ក្នុងចំណោមគណៈគ្រប់គ្រង២០នាក់ បានជ្រើសរើសយកកម្រិតទី៤គឺអនុវត្តបានច្រើនចំនួន៧នាក់ និងជ្រើសរើសយកកម្រិតទី៥ គឺអនុវត្តបានច្រើនបំផុត ចំនួន៨នាក់ ជារួមទាំងពីរកម្រិតស្មើនឹង៧៥%។

អ្នកស្រាវជ្រាវរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អមួយចំនួនតាមរយៈតារាងខាងលើនេះ។ លទ្ធផលនេះបង្ហាញថា កម្រិតសមត្ថភាពរបស់លោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ឱ្យតម្លៃខ្ពស់លើកិច្ចសហប្រតិបត្តិការ និងក្របខណ្ឌសមត្ថភាពបច្ចេកទេស ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន។ជារួមកម្រិតសមត្ថភាពរបស់លោកនាយក/នាយករងបច្ចេកទេសនិងបរិវច្ឆការីបន្ទប់ពិសោធន៍ មិនទាន់មានមោទនភាពខ្លាំងក្លានោះទេ ពីព្រោះថាយើងឃើញ M=3.61, SD=0.76 គឺនៅលើមធ្យមតែបន្តិចប៉ុណ្ណោះ។ ចំណែកឯកិច្ចគាំទ្រការបង្រៀននិងរៀន យើងសង្កេតឃើញថា នៅមានកម្រិតនៅឡើយ មានន័យថាកម្រិតសមត្ថភាពរបស់លោកនាយក/នាយករងបច្ចេកទេសនិងបរិវច្ឆការីបន្ទប់ពិសោធន៍ ពុំទាន់យកអស់លទ្ធភាពនៅឡើយទេ។

ស្ថានភាព នៃការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន នៅមានកម្រិតនៅឡើយ គឺប្រើប្រាស់បន្ទប់ពិសោធន៍មិនទាន់មានប្រសិទ្ធភាពពេញលេញទេ។ គណៈគ្រប់គ្រងអគារធនធានដែលរួមមានលោកនាយក នាយករងទទួលបន្ទុកបច្ចេកទេស និងក្រុមប្រឹក្សាបច្ចេកទេស ពុំទាន់អនុវត្តនូវភារកិច្ចរបស់ខ្លួនឱ្យអស់លទ្ធភាពនៅឡើយទេ ជាពិសេសភារកិច្ចដូចជា ″សហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការទ្រទ្រង់សាលារៀន គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្ដាញ ក្នុងការស្វែងរក និងចាត់ចែងប្រើប្រាស់មូលនិធិ ប្រាក់ចំណូលសម្រាប់ធានានិរន្តរភាពដំណើរការអគារធនធាន″។ មានភារកិច្ចពីរទៀតដែលគណៈគ្រប់គ្រងអគារធនធានពុំទាន់បានបំពេញឱ្យបានស៊ីជម្រៅ ទីមួយគឺ ″ធានាការប្រើប្រាស់ឱ្យអស់លទ្ធភាព ប្រកប ដោយសុវត្ថិភាព និងថែរក្សាទុកដាក់បរិក្ខារ/ឧបករណ៍″ និងទីពីរគឺ ″ធ្វើឱ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់″។ ដូចនេះដើម្បីឱ្យការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធានមានប្រសិទ្ធភាព គណៈគ្រប់គ្រងអគារធនធាន ត្រូវមានយន្តការឬក៏សេចក្ដីណែនាំផ្សេងៗផ្ដល់ជូនចំពោះអ្នកអនុវត្តន៍ឱ្យបានត្រឹមត្រូវហើយត្រូវតាមដាននិងសង្កេតជាប្រចាំ។ ជាក់ស្ដែងតាមរយៈលោកម៉ឹង វាសនា និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១(២០១២-២០១៤) បានរកឃើញថា ដំណើរការរបស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន នៅមានកម្រិតនៅឡើយ។ ការគ្រប់គ្រង

របស់លោកនាយកនៅមានកម្រិត ហើយការចូលមកប្រើប្រាស់អគារធនធានរបស់សាលាបណ្ដាញ រិតតែមានកម្រិតទៀត។ ចំណែកឯសម្ភារៈពិសោធន៍មានការខ្វះខាត ជាពិសេសសារធាតុគីមីមានតម្លៃថ្លៃ ហើយពិបាករកទិញទៀត។ មួយវិញទៀតតាមរយៈរបាយការណ៍សង្ខេបស្ដីពីការចុះពិនិត្យមើលដំណើរការប្រតិបត្តិអគារធនធាន នៅវិទ្យាល័យសម្ដេចតេជោហ៊ុនសែនសួង របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ចុះថ្ងៃ អង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃ ១៨ ខែ កុម្ភៈ ឆ្នាំ២០២០ បានរកឃើញអំពីការងារបន្ទប់ពិសោធន៍ដូចតទៅ(១)មុខវិជ្ជាគីមីវិទ្យាៈគ្រូមួយចំនួនធំមិនបានមកធ្វើការពិសោធន៍តាមកាលវិភាគដែលបានកំណត់ (២)មុខវិជ្ជាជីវវិទ្យាៈគ្រូមួយចំនួនមិនបានមកធ្វើការពិសោធន៍តាមកាលវិភាគដែលបានកំណត់ ភាគច្រើនថ្នាក់ទី ៧ ទី៨ ទី៩(ខ្វះសម្ភារៈពិសោធ) (៣)មុខវិជ្ជារូបវិទ្យាៈគ្រូមិនបានមកពិសោធន៍តាមកាលវិភាគ គ្រូខ្លះមកពិសោធហើយតែមិនបានដាក់ឈ្មោះគ្រូដឹកនាំ (៤)មុខវិជ្ជាផែនដីវិទ្យាៈភាគច្រើនគ្រូដឹកនាំសិស្សចូលបន្ទប់ពិសោធន៍ តែនៅមិនទាន់អនុវត្តតាមកាលវិភាគនៅឡើយ។

អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបគុណវិស័យ ចំនួនពីរគឺទី(១)តើលោក/លោកស្រីជួបបញ្ហាលំបាកអ្វីខ្លះ ក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន? និងទី(២)"តើលោក/លោកស្រីមានសំណូមពរ ឬអនុសាសន៍យ៉ាងណាខ្លះ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?" អ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យតាមបែបផ្ដុំគំនិតរកអ្នកមានគំនិត ឬយោបល់ដូចគ្នាចាត់ជាក្រុម ងាយស្រួលក្នុងការគិតជាភាគរយ។

ក.បញ្ហាលំបាកក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍

ចំពោះបញ្ហាលំបាកក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន អ្នកស្រាវជ្រាវបានសុំសម្ភាសន៍ផ្ទាល់ជាមួយលោកនាយក ឬលោកនាយករងបច្ចេកទេសទទួលបន្ទុកអគារធនធាន ហើយក្នុងចំណោមនាយកសាលាមធ្យមសិក្សាធនធានទាំង៤ ភាគច្រើនលើសលប់លោកបានលើកឡើងថា "ពិបាកជ្រើសរើសគ្រូចូលកាន់បន្ទប់ពិសោធន៍" នេះជាបញ្ហាប្រឈមទី១។ បញ្ហាប្រឈមទី២ គឺខ្វះគ្រូឯកទេស ជាពិសេសគ្រូឯកទេសកាន់បន្ទប់ពិសោធន៍តែម្ដង គឺលោកគ្រូ-អ្នកគ្រូមិនចង់ធ្វើ(កាន់បន្ទប់ពិសោធន៍) ដោយសារតែបន្ទប់ពិសោធន៍គ្មានលាភការសម្រាប់ពួកគាត់។ ជាក់ស្ដែងនៅសាលាមធ្យមសិក្សាធនធានមួយ មានគ្រូសរុបចំនួន២១៤នាក់ ស្រី១០៨នាក់ ក្នុងចំណោមបរិវច្ឆការី៤នាក់ លោកនាយកជ្រើសរើសបានគ្រូកម្រិតមូលដ្ឋានពនាក់ ស្រីពនាក់ ហើយជាគ្រូដែលធ្លាប់បង្រៀនថ្នាក់ទី៧ និងមិនដែលបានបណ្ដុះបណ្ដាលទៀត ក្នុងគ្រាដែលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រចាប់ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២ មានចំនួន

៥៥នាក់ ស្រី២០នាក់។ ចំណែកឯសាលាមធ្យមសិក្សាធនធានមួយទៀត បរិវច្ឆការីបន្ទប់ពិសោធន៍ ត្រូវមាន៤នាក់ ប៉ុន្តែលោកនាយកជ្រើសរើសបរិវច្ឆការីបានតែ២នាក់ គឺមួយនាក់កាន់២មុខវិជ្ជា ហើយក្នុងចំណោម២នាក់ មានមួយនាក់ខុសមុខវិជ្ជាឯកទេស គឺគាត់ជាបុគ្គលិកទីចាត់ការ និងមានមុខវិជ្ជាឯកទេស"អក្សរសាស្ត្រ អង់គ្លេស"។ អ្នកទទួលបន្ទុកតាមបន្ទប់ពិសោធន៍នីមួយៗ មកប្រចាំការមិនសូវទៀងទាត់ មានការអសកម្មក្នុងការងារ។

ចំពោះបញ្ហាប្រឈមដែលបានមកពីកម្រងសំណួរវិញ បានចង្អុលបង្ហាញថា ក្នុងចំណោមលោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ចំនួន២០នាក់ សាមសិបភាគរយបាននិយាយថាមិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍ ជាពិសេសឧបករណ៍មើលផ្កាយប្រើមិនកើត ហើយសម្ភារៈពិសោធន៍មួយចំនួនមិនស្គាល់ និងមួយចំនួនទៀតមិនសូវចេះប្រើប្រាស់ ។ លោកគ្រូ អ្នកគ្រូមួយចំនួនមិនស្គាល់ឧបករណ៍ពិសោធន៍ ហើយសម្ភារៈឬឧបករណ៍ដែលខូចពិបាករកកន្លែងជួសជុល ឬចង់ទិញថ្មីមិនដឹងជារកកន្លែងទិញនៅឯណា ពោលពិបាកក្នុងការរកទិញសម្ភារៈពិសោធន៍ ជាពិសេសសារធាតុគីមីតែម្តង ។ ម្ភៃភាគរយទៀតបាននិយាយថា គ្មានគ្រូជំនាញឬអ្នកបច្ចេកទេសផ្នែកបន្ទប់ពិសោធន៍ បរិវច្ឆការីមួយចំនួនមិនមែនជាគ្រូឯកទេស និងមិនបានបានបណ្តុះបណ្តាលទៀត។ ជារួមបរិវច្ឆការីបន្ទប់ពិសោធន៍ ភាគច្រើនគ្មានជំនាញ ឬបច្ចេកទេសផ្នែកបន្ទប់ពិសោធន៍ ពីព្រោះអ្នកកាន់បន្ទប់ពិសោធន៍ មានការផ្លាស់ប្តូរគ្នាកាន់ជាញឹកញាប់ និងមិនបានបណ្តុះបណ្តាលទៀត។ ម្យ៉ាងទៀតម៉ោងសម្រាប់ធ្វើពិសោធន៍មិនគ្រប់គ្រាន់ទេ ដោយសារសាលាមធ្យមសិក្សាធនធាននីមួយៗ មានថ្នាក់រៀនច្រើន បូករួមទាំងសាលាបណ្តាញទៀត ដូចនេះកាលវិភាគសម្រាប់ពិសោធន៍តាមថ្នាក់នីមួយៗមិនគ្រប់គ្រាន់ទេ។ ម្ភៃភាគរយទៀតបាននិយាយថា ខ្វះការចូលរួមពីគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ មានន័យថាលោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រគាត់មានជំនាញផ្នែកពិសោធន៍ ប៉ុន្តែគាត់មិនសហការជាមួយបរិវច្ឆការីទេ នៅពេលដែលបរិវច្ឆការីមិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍នោះ។ ដប់ប្រាំភាគរយទៀតបានឆ្លើយថា សម្ភារៈពិសោធន៍មិនស្របតាមខ្លឹមសារមេរៀន ពោលគឺសម្ភារៈពិសោធន៍ មិនត្រូវនឹងប្រធានបទរបស់មេរៀនតាមកម្រិតថ្នាក់នីមួយៗ។ ចំណែកដប់ភាគរយទៀត បានឆ្លើយថាបន្ទប់ពិសោធន៍តូចចង្អៀត បើប្រៀបធៀបទៅនឹងចំនួនសិស្សក្នុងមួយថ្នាក់ មានចន្លោះពីសែសិបនាក់ទៅហាសិបនាក់។ បន្ទប់ពិសោធន៍មិនគ្រប់តាមមុខវិជ្ជា ពោលគឺក្នុងអគារធនធាននីមួយៗមានបន្ទប់ពិសោធន៍តែពីរទេ ប៉ុន្តែមុខវិជ្ជាវិទ្យាសាស្ត្រមានបួន គឺមុខវិជ្ជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដូច្នេះបន្ទប់ពិសោធន៍មួយ

ត្រូវដាក់ពីរមុខវិជ្ជា។ ក្នុងចំណោមលោកនាយក/នាយករងបច្ចេកទេស និងបរិវច្ឆការីបន្ទប់ពិសោធន៍ចំនួន២០នាក់ មានមួយនាក់គ្មានយោបល់។

ខ.សំណូមពរ ឬអនុសាសន៍ក្នុងការដោះស្រាយបញ្ហាប្រឈម

ចំណែកឯកម្រងសំណួរទី(២)"តើលោក/លោកស្រីមានសំណូមពរ ឬអនុសាសន៍យ៉ាងណាខ្លះ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?" ហុកសិបភាគរយបាននិយាយថា សូមឱ្យក្រសួងអប់រំ យុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាលបរិវច្ឆការីបន្ទប់ពិសោធន៍ និងគ្រូមុខវិជ្ជាវិទ្យាសាស្ត្រជាមួយនឹងប្រធានបទថ្មីៗ ហើយមាន រយៈពេលពី២ទៅ៤សប្តាហ៍។ សូមក្រសួងអប់រំកុំបណ្តុះបណ្តាលតែប្រធានបច្ចេកទេស ពីព្រោះកន្លងមកអ្នកដែលបានទៅសិក្ខាសាលាឬបណ្តុះបណ្តាលវគ្គខ្លីៗ ពេលត្រលប់មកវិញមិនដែលបានផ្សព្វផ្សាយនូវចំណេះដឹងទាំងនោះ ដល់លោកគ្រូអ្នកគ្រូដទៃទៀតទេ ដូចនេះអ្នកដែលមិនបានចូលរួមនៅតែមិនចេះ ជាពិសេសបរិវច្ឆការី។ សូមក្រសួងអប់រំជួយផ្តល់អ្នកជំនាញជួយបន្ទប់ពិសោធន៍ និងជួយជួសជុលឧបករណ៍ពិសោធន៍ដែលខូច ឬបន្ថែមឧបករណ៍ពិសោធន៍ថែមទៀត។ សូមក្រសួងជួយផ្តល់ឧបករណ៍ពិសោធន៍ថ្មីៗនិងសម្ភារៈសម្រាប់ពិសោធន៍បន្ថែម ជាពិសេសត្រូវការធាតុគីមីឱ្យបានគ្រប់គ្រាន់ ពីព្រោះសារធាតុនេះពិបាករកវាណាស់។ ដប់ភាគរយទៀត ចង់បានបន្ទប់ពិសោធន៍ធំទូលាយ ដែលអាចដាក់សិស្សបានចំនួនពី៤០ទៅ៥០នាក់ ហើយបន្ទប់ពិសោធន៍ត្រូវមានគ្រប់តាមមុខវិជ្ជាវិទ្យាសាស្ត្រទាំងបួន គឺមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។ ចំណែកដប់ភាគទៀតសំណូមពរឱ្យក្រសួងជួយផ្តល់សារធាតុគីមីឱ្យបានគ្រប់គ្រាន់ និងស្របតាមខ្លឹមសារមេរៀន។ ចំពោះលោកគ្រូ-អ្នកគ្រូដែលសំណូមពរទៅក្រសួងអប់រំ យុវជន និងកីឡា ចង់ឱ្យក្រសួងផ្តល់សេវាពិសោធន៍តាមមេរៀននីមួយៗឱ្យបានច្បាស់លាស់ ជាមួយនឹងពេលវេលាសមស្រប ពីព្រោះពេលវេលាពិសោធន៍សព្វថ្ងៃនេះមិនគ្រប់គ្រាន់ទេ គឺមានចំនួនដប់ភាគរយ។ ប្រាំភាគរយចង់បានឱ្យក្រសួងអប់រំ យុវជន និងកីឡា មានកម្មវិធីផ្តល់រង្វាន់លើកទឹកចិត្តដល់លោកគ្រូ-អ្នកគ្រូដែលរកឃើញនូវរបៀបពិសោធន៍ថ្មីៗ និងប្រាំភាគរយទៀតគ្មានយោបល់។

## ៤.២.ការវិភាគទិន្នន័យលើកម្រងសំណួរទី២

### ៤.២.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

តារាង៤.៦៖ សង្ខេបព័ត៌មានទូទៅរបស់អ្នកចូលរួម

| ល.រ | បរិយាយ | ត្បូងឃ្មុំ | កំពង់ចាម | ព្រៃវែង | ព្រៃវែង | សរុប |
|---|---|---|---|---|---|---|

| | | | វិ.សគបាស ស៊ុង | វិទ្យាល័យ ព្រះសីហនុ | វិទ្យាល័យ ព្រះអង្គឌួង | វិទ្យាល័យកំពង់ ពពិល | ចំនួន | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ១ | ភេទ | ប្រុស | 9 | 11 | 9 | 6 | 35 | 72.90% |
| | | ស្រី | 3 | 5 | 3 | 2 | 13 | 27.10% |
| | | សរុប | 12 | 16 | 12 | 8 | 48 | 100.0% |
| ២ | អាយុ | 20-30 ឆ្នាំ | 0 | 1 | 2 | 3 | 6 | 12.50% |
| | | 31-40 ឆ្នាំ | 7 | 9 | 7 | 4 | 27 | 56.25% |
| | | 41-50 ឆ្នាំ | 5 | 4 | 2 | 1 | 12 | 25.00% |
| | | លើស50 ឆ្នាំ | 0 | 2 | 1 | 0 | 3 | 6.25% |
| | | សរុប | 12 | 16 | 12 | 8 | 48 | 100.0% |
| ៣ | កម្រិតវប្បធម៌ | ម.ទ.ភ | 2 | 2 | 4 | 0 | 8 | 16.70% |
| | | បរិញ្ញាបត្រ | 9 | 8 | 6 | 7 | 30 | 62.50% |
| | | បរិ.ជាន់ខ្ពស់ | 1 | 6 | 2 | 1 | 10 | 20.80% |
| | | សរុប | 12 | 16 | 12 | 8 | 48 | 100.0% |
| ៤ | ក្របខណ្ឌគ្រូបង្រៀន | កម្រិតមូលដ្ឋាន | 2 | 2 | 4 | 0 | 8 | 16.67% |
| | | កម្រិតឧត្តម | 10 | 14 | 8 | 8 | 40 | 83.33% |
| | | សរុប | 12 | 16 | 12 | 8 | 48 | 100.0% |
| ៥ | បទពិសោធន៍ក្នុងការងារពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ | 1-3 ឆ្នាំ | 0 | 3 | 3 | 3 | 9 | 18.75% |
| | | 4-6 ឆ្នាំ | 5 | 0 | 2 | 2 | 9 | 18.75% |
| | | 7-9 ឆ្នាំ | 1 | 3 | 2 | 1 | 7 | 14.58% |
| | | 10 ឆ្នាំឡើង | 6 | 10 | 5 | 2 | 23 | 47.92% |
| | | សរុប | 12 | 16 | 12 | 8 | 48 | 100.0% |

តាមរយៈលទ្ធផលនៅតារាង៤.៦ បានបង្ហាញថាភាគរយភេទប្រុស របស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកមធ្យមសិក្សាទុតិយភូមិ នៅតាមសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មានចំនួនច្រើនជាងភេទស្រីរហូតដល់ជិតមួយភាគបួន គឺភេទប្រុសចំនួន ៧២.៩០% នៃសមាមាត្រសរុប ១០០%។ តាមរយៈលទ្ធផលក្នុងតារាងនេះ ក៏បានបង្ហាញថា ភាគរយអាយុរបស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកមធ្យមសិក្សាទុតិយភូមិ នៅតាមសាលាមធ្យមសិក្សធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត

កំពង់ចាម និងខេត្តព្រៃវែង អាយុនៅចន្លោះពី៣១-៤០ឆ្នាំមានចំនួនច្រើនជាងគេគឺរហូតដល់ ៥៦.៣០% និងអាយុចាប់ពី៥០ឆ្នាំឡើងមានចំនួនតិចជាងគេគឺ៦.៣០% នៃសមាមាត្រសរុប ១០០%។ ជាមួយគ្នានេះដែរ លទ្ធផលក្នុងតារាងក៏បានបង្ហាញថា ភាគរយកម្រិតវប្បធម៌ របស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកមធ្យមសិក្សាទុតិយភូមិ នៅតាមសាលាមធ្យមសិក្សាធនធានក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង សញ្ញាបត្របរិញ្ញាបត្រ មានចំនួនច្រើនជាងគេគឺ ៦២.៥០% និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានចំនួនតិចជាងគេគឺ ១៦.៧០% នៃសមាមាត្រសរុប ១០០%។ ម្យ៉ាងទៀតលទ្ធផលក្នុងតារាងក៏បានបង្ហាញអំពី ភាគរយគ្រូកម្រិតមូលដ្ឋាន និងគ្រូកម្រិតឧត្តម របស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកមធ្យមសិក្សាទុតិយភូមិ នៅតាមសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មានគ្រូកម្រិតឧត្តមចំនួនច្រើនជាងគេគឺ៨៣.៣% នៃសមាមាត្រសរុប ១០០%។ ចំនែកឯបទពិសោធន៍ក្នុងការងារពិសោធន៍ នៃមុខវិជ្ជាវិទ្យាសាស្ត្ររបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ នៅតាមសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មានបទពិសោធន៍ចាប់ពី១០ឆ្នាំឡើងមានចំនួនច្រើនជាងគេគឺ៤៧.៩២% រីឯគ្រូដែលមានបទពិសោធន៍ចាប់ពី៧-៩ឆ្នាំមានចំនួនតិចជាងគេគឺ១៤.៥៨%។

៤.២.២ កម្រិតសមត្ថភាពរបស់លោក/លោកស្រីការប្រើប្រាស់អគារធនធាន

*តារាង៤.៧.ចំនួនអ្នកឆ្លើយតបសំណួរតាមកម្រិតនៃការប្រើប្រាស់*

| ល.រ | សំណួរស្តីពីកម្រិតសមត្ថភាពរបស់លោក/លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | |
|---|---|---|---|---|---|---|
| | | តិចបំផុត | តិច | មធ្យម | ច្រើន | ច្រើនបំផុត |
| ១. | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | 3 | 12 | 20 | 9 | 4 |
| ២ | បានធ្វើដំណើរការពិសោធន៍តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ | 6 | 3 | 12 | 22 | 5 |
| ៣ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | 4 | 3 | 8 | 23 | 10 |
| ៤ | បន្ទប់ពិសោធន៍ មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | 5 | 10 | 13 | 12 | 8 |
| ៥ | បន្ទប់ពិសោធន៍ មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | 2 | 3 | 7 | 19 | 17 |
| ៦ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | 3 | 8 | 15 | 13 | 9 |
| ៧ | មានវិធីសាស្រ្តបង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | 6 | 7 | 14 | 15 | 6 |
| ៨ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 7 | 4 | 13 | 15 | 9 |
| ៩ | គោរពតាមនីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | 1 | 5 | 8 | 16 | 18 |
| ១០ | សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធ | 0 | 4 | 7 | 15 | 22 |
| ១១ | មានកិច្ចប្រជុំបច្ចេកទេស អំពីការរៀបចំធ្វើកិច្ចតែងការបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត | 1 | 5 | 10 | 17 | 15 |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្រ្ត ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 8 | 7 | 9 | 13 | 11 |
| ១៣ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជា មួយគណៈគ្រប់គ្រង | 5 | 4 | 15 | 14 | 10 |
| ១៤ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ | 9 | 5 | 19 | 9 | 6 |
| ១៥ | ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 2 | 2 | 8 | 23 | 13 |
| ១៦ | មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធ | 1 | 3 | 3 | 11 | 30 |
| ១៧ | មានការគាំទ្រឲ្យអនុវត្តមេរៀនវិទ្យាសាស្រ្តក្នុងបន្ទប់ពិសោធន៍ | 1 | 3 | 3 | 20 | 21 |
| ១៨ | មានការលើកទឹកចិត្តឲ្យធ្វើការពិសោធន៍នៅអគារធនធាន | 4 | 3 | 5 | 18 | 18 |
| ១៩ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់អនុវត្តតាមមុខវិជ្ជាច្បាស់លាស់ | 3 | 4 | 8 | 14 | 19 |
| ២០ | មានបុគ្គលិកបច្ចេកទេស សម្រាប់ជំនួយពេលប្រើបន្ទប់ពិសោធន៍ | 8 | 8 | 2 | 14 | 16 |
| ២១ | ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | 18 | 13 | 6 | 4 | 7 |
| ២២ | ធ្លាប់បានឲ្យចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ | 12 | 7 | 9 | 11 | 9 |
| ២៣ | បានរៀបចំសម្ភារៈពិសោធន៍ឲ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 2 | 10 | 2 | 13 | 21 |
| | ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ | 10.05 % | 12.05 % | 19.56 % | 30.80 % | 27.54 % |

តាមរយៈតារាង៧.៥បង្ហាញថា ក្នុងចំណោមលោកលោកគ្រូ-អ្នកគ្រូ បង្រៀនមុខវិជ្ជាវិទ្យាសាស្រ្តចំនួន៥៨នាក់ បានឆ្លើយសណ្ចួរទាំង២៣ ដោយជ្រើសរើសយកកម្រិតទី៤"អនុវត្តបានច្រើន" មានភាគរយច្រើនជាងគេគឺ៣០.៨០% បន្ទាប់មកជ្រើសរើសយកកម្រិតទី៥"អនុវត្តបានច្រើនបំផុត" មានភាគរយច្រើនលំដាប់ទី២គឺ៣០.៨០%។ ចំណែកឯលំដាប់ថ្នាក់ទី៣បានទៅលើកម្រិតទី៣"អនុវត្តបានមធ្យម" មានភាគរយ១៩.៥៦% និងលំដាប់ថ្នាក់ទី៤បានទៅលើកម្រិតទី២"អនុវត្តបានតិច" មានភាគរយត្រឹមតែ១២.០៥% ចំណែកឯលំដាប់ចុងក្រោយគេ គឺលោកគ្រូ អ្នកគ្រូជ្រើសរើសយកកម្រិតទី១ "អនុវត្តបានតិចបំផុត"មានភាគរយតិចជាងគេ គឺ១០.០៥%។

អ្នកសិក្សាបានខិតខំស្រាវជ្រាវ និងស្វែងយល់នូវចម្ងល់ចំនួនពីរដងដែល ដែលកាលពីលើកទី១ អ្នកសិក្សាស្រាវជ្រាវ សិក្សាទៅលើអ្នកគ្រប់គ្រងបន្ទប់ពិសោធន៍ ហើយលើកនេះ អ្នកស្រាវជ្រាវសិក្សាទៅលើលោកលោកគ្រូ-អ្នកគ្រូ ដែលបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត ហើយចម្ងល់លើកនេះក៏ដូចលើកទី១ដែរគឺ ៖(១)តើលោកគ្រូ-អ្នកគ្រូជួបឧបសគ្គអ្វីខ្លះ ក្នុងការប្រើប្រាស់បន្ទប់

ពិសោធន៍នៅសាលាធនធាន? និង(២)តើលោកគ្រូ-អ្នកគ្រូមានសំណូមពរ ឬអនុសាសន៍ យ៉ាងដូចម្ដេចខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ?

ដើម្បីស្រាយចម្ងល់ទាំងពីរខាងលើនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ ដោយប្រើកម្មវិធី SPSS Version 25. ដូចលើកទី១ដែរ ដើម្បីធ្វើការវិភាគទិន្នន័យតាមបែបពណ៌នាស្ថិតិ (Descriptive Statistics) រកតម្លៃមធ្យម (M) រកតម្លៃគម្លាតស្តង់ដារ (SD) និងកម្រិត (Level) ដើម្បីស្វែងយល់ចំពោះចម្ងល់ទី១លើកទី២នេះ។

កម្រិតនៃចម្លើយជ្រើសរើសមាន៥កម្រិត ក្នុង១សំណួរ គឺកម្រិតទី១ កម្រិតទី២ កម្រិតទី៣ កម្រិតទី៤ និងកម្រិតទី៥ ហើយអ្នកឆ្លើយជ្រើសរើសយកតែមួយគត់ ក្នុងចំណោមជម្រើសទាំង៥។ តាមទ្រឹស្តី Likert $\frac{Hihgestlevel - Lowestlevel}{TotalLevel} = \frac{5-1}{5} = \frac{4}{5} = 0.80$ ។ មធ្យមភាគនៅចន្លោះពី១ទៅ១.៨០ អនុវត្តបានតិចបំផុត, មធ្យមភាគនៅចន្លោះពី១.៨១ទៅ២.៦០ អនុវត្តបានតិច, មធ្យមភាគនៅចន្លោះពី២.៦១ទៅ៣.៤០ អនុវត្តបានមធ្យម, មធ្យមភាគនៅចន្លោះពី៣.៤១ទៅ៤.២០ អនុវត្តបានច្រើន ,មធ្យមភាគនៅចន្លោះពី៤.២១ទៅ៥.០០ អនុវត្តបានច្រើនបំផុត។

លទ្ធផលនៃសំណួរស្រាវជ្រាវទី១លើកទី២"តើលោកគ្រូ-អ្នកគ្រូជួបឧបសគ្គអ្វីខ្លះ ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាធនធាន?

***តារាង៤.៨ ស្តីពីតម្លៃមធ្យម(M)តម្លៃគម្លាតស្តង់ដារ(S D)និងកម្រិតនៃការប្រើប្រាស់***

| ល.រ | កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន | M | S D | Level |
|---|---|---|---|---|
| ១. | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | 2.98 | 1.02 | មធ្យម |
| ២ | បានធ្វើដំណើរការពិសោធន៍តាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ | 3.35 | 1.16 | មអ្យម |
| ៣ | បន្ទប់ពិសោធន៍មានសេចក្ដីណែនាំ ស្ដីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | 3.67 | 1.14 | ល្អ |
| ៤ | បន្ទប់ពិសោធន៍ មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | 3.17 | 1.24 | មធ្យម |
| ៥ | បន្ទប់ពិសោធន៍ មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | 3.96 | 1.07 | ល្អ |
| ៦ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | 3.35 | 1.16 | មធ្យម |
| ៧ | មានវិធីសាស្រ្តបង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | 3.17 | 1.20 | មធ្យម |
| ៨ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 3.31 | 1.29 | មធ្យម |
| ៩ | គោរពតាមនីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | 3.94 | 1.08 | ល្អ |
| ១០ | សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធន៍ | 4.15 | 0.97 | ល្អ |
| ១១ | មានកិច្ចប្រជុំបច្ចេកទេស អំពីការរៀបចំធ្វើកិច្ចតែងការបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត | 3.83 | 1.06 | ល្អ |
| ១២ | ផ្ដល់ឱកាសឱ្យគ្រូមុខវិទ្យាសាស្រ្ត ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 3.25 | 1.41 | មធ្យម |
| ១៣ | មានរៀបចំការប្រជុំ ស្ដីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 3.42 | 1.22 | ល្អ |
| ១៤ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្ដាញទាំងអស់ | 2.96 | 1.25 | មធ្យម |
| ១៥ | ធានាបាននូវយន្តការស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 3.90 | 0.99 | ល្អ |

| | | | | |
|---|---|---|---|---|
| ១៦ | មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធនៅក្នុងបន្ទប់ពិសោធន៍ | 4.37 | 1.00 | ល្អ |
| ១៧ | មានការគាំទ្រឲ្យអនុវត្តមេរៀនវិទ្យាសាស្ត្រក្នុងបន្ទប់ពិសោធន៍ | 4.18 | 0.96 | ល្អ |
| ១៨ | មានការលើកទឹកចិត្តឲ្យធ្វើការពិសោធន៍នៅអគារធនធាន | 3.89 | 1.22 | ល្អ |
| ១៩ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់អនុវត្តតាមមុខវិជ្ជាច្បាស់លាស់ | 3.87 | 1.21 | ល្អ |
| ២០ | មានបុគ្គលិកបច្ចេកទេស សម្រាប់ជំនួយពេលប្រើបន្ទប់ពិសោធន៍ | 3.46 | 1.51 | ល្អ |
| ២១ | ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | 2.35 | 1.43 | មធ្យម |
| ២២ | ធ្លាប់បានឲ្យចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ | 2.96 | 1.47 | មធ្យម |
| ២៣ | បានរៀបចំសម្ភារៈពិសោធន៍ឲ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 3.85 | 1.30 | ល្អ |
| | សរុប | 3.51 | 0.97 | ល្អ |

តាមតារាង៤.៨ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដារ និងកម្រិតនៃសំណួរបែបបរិមាណវិស័យទាំង២៣សំណួរ ទៅលើកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន។ បើយោងតាមលទ្ធផលនៃតារាងខាងលើ បង្ហាញថាសំណួរចំនួន១៣មានតម្លៃមធ្យមកម្រិតខ្ពស់ គឺមានន័យថាអនុវត្តបានច្រើន (គឺសំណួរទី៣,៥,៩,១០,១១,១៣,១៥ ,១៦,១៧,១៨,១៩,២០និង២៣) រីឯកម្រិតមធ្យមមានចំនួន១០ គឺមានន័យថាអនុវត្តបានមធ្យម (គឺសំណួរទី១,២,៤,៦,៧,៨,១២,១៤,២១និង២២)។ សំណួរដែលឈរនៅលំដាប់ទី១ គឺសំណួរទី១៦ ដែលលើកឡើងថា″ មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធក្នុងបន្ទប់ពិសោធន៍″ (M=4.37, SD=1.00) គឺមានតម្លៃមធ្យមខ្ពស់ជាងគេបំផុត។ ចំណាត់ថ្នាក់ទី២ បានទៅសំណួរទី១៧″មានការគាំទ្រ ឱ្យអនុវត្តមេរៀនវិទ្យាសាស្ត្រក្នុងបន្ទប់ពិសោធន៍″ ។ បន្ទាប់មកមានចំណាត់ជាបន្តបន្ទាប់រហូតដល់សំណួរដែលមានតម្លៃមធ្យមទាបជាងគេបំផុត គឺសំណួរទី២១ ដែលបានលើកឡើងថា″ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ″ (M=2.35, SD=1.44) ។ ជារួម កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន មានតម្លៃមធ្យមកម្រិតខ្ពស់គឺ(M=3.51, SD=0.97)គឺមានន័យថាពួកគាត់អនុវត្តបានច្រើន ប៉ុន្តែបើយោងទៅតាមតម្លៃមធ្យម អ្នកស្រាវជ្រាវរកឃើញថា អនុវត្តបានច្រើនកម្រិតទាបនៅឡើយ។

អ្នកស្រាវជ្រាវបានបែងចែកនៃកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាននោះទៅជា៣ប្រភេទ៖ ក.ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ ខ.ចំណេះដឹងសមត្ថភាព គ.ការលើកទឹកចិត្ត និងវិភាគលទ្ធផលនៃកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន ដូចខាងក្រោម៖

***តារាង៤.៩ ផ្នែកទាំង៣នៃកម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍***

| ល.រ | ក.ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ | M | S D | Level |
|---|---|---|---|---|
| ១. | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | 2.98 | 1.02 | មធ្យម |
| ២ | បានធ្វើដំណើរការពិសោធន៍តាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ | 3.35 | 1.16 | មធ្យម |
| ៣ | បន្ទប់ពិសោធន៍មានសេចក្ដីណែនាំ ស្ដីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | 3.67 | 1.14 | ល្អ |
| ៤ | បន្ទប់ពិសោធន៍ មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | 3.17 | 1.24 | មធ្យម |
| ៥ | បន្ទប់ពិសោធន៍ មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | 3.96 | 1.07 | ល្អ |
| ៦ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | 3.35 | 1.16 | មធ្យម |
| ៧ | មានវិធីសាស្រ្តបង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | 3.17 | 1.20 | មធ្យម |
| ៨ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 3.31 | 1.29 | មធ្យម |
| ៩ | គោរពតាមនីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | 3.94 | 1.08 | ល្អ |
| ១០ | សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធន៍ | 4.15 | 0.97 | ល្អ |
| | សរុប | 3.50 | 0.78 | ល្អ |
| ល.រ | ខ.ចំណេះដឹងសមត្ថភាព | M | S D | Level |
| ១១ | មានកិច្ចប្រជុំបច្ចេកទេស អំពីការរៀបចំធ្វើកិច្ចតែងការបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត | 3.83 | 1.06 | ល្អ |
| ១២ | ផ្ដល់ឱកាសឱ្យគ្រូមុខវិទ្យាសាស្រ្ត ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 3.25 | 1.41 | មធ្យម |
| ១៣ | មានរៀបចំការប្រជុំ ស្ដីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 3.42 | 1.22 | ល្អ |
| ១៤ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្ដាញទាំងអស់ | 2.96 | 1.25 | មធ្យម |
| ១៥ | ធានាបាននូវយន្តការស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | 3.90 | 0.99 | ល្អ |
| ១៦ | មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍ | 4.37 | 1.00 | ល្អ |
| | សរុប | 3.62 | 0.80 | ល្អ |
| ល.រ | គ.ការលើកទឹកចិត្ត | M | S D | Level |
| ១៧ | មានការគាំទ្រឲ្យអនុវត្តមេរៀនវិទ្យាសាស្រ្តក្នុងបន្ទប់ពិសោធន៍ | 4.18 | 0.96 | ល្អ |
| ១៨ | មានការលើកទឹកចិត្តឲ្យធ្វើការពិសោធន៍នៅអគារធនធាន | 3.89 | 1.22 | ល្អ |
| ១៩ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់អនុវត្តតាមមុខវិជ្ជាច្បាស់លាស់ | 3.87 | 1.21 | ល្អ |
| ២០ | មានបុគ្គលិកបច្ចេកទេស សម្រាប់ជំនួយពេលប្រើបន្ទប់ពិសោធន៍ | 3.46 | 1.51 | ល្អ |
| ២១ | ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | 2.35 | 1.43 | មធ្យម |
| ២២ | ធ្លាប់បានឲ្យចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ | 2.96 | 1.47 | មធ្យម |
| ២៣ | បានរៀបចំសម្ភារៈពិសោធន៍ឲ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 3.85 | 1.30 | ល្អ |
| | សរុប | 3.51 | 0.97 | ល្អ |

តាមតារាង៤.៩ បង្ហាញថាពីមធ្យមភាគសរុបផ្នែក (ក) "ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍" របស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត នៃសាលាមធ្យមសិក្សាធនធាន ក្នុងខេត្តត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មធ្យមភាគសរុប គឺយល់ស្របក្នុងកម្រិតល្អ (M=3.50, SD=0.78)។ សូចនាករ ទី១០ "សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធន៍"

ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ក្នុងកម្រិត"ល្អ" (M=4.15, SD=0.97) និងសូចនាករ "បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ "បានទទួលការយល់ស្របទាបជាងគេក្នុងកម្រិត"មធ្យម" (M=2.98, SD=1.02)។

ផ្នែក (ខ) "ចំណេះដឹងសមត្ថភាព" របស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ នៃសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មធ្យមភាគសរុប គឺយល់ស្របក្នុងកម្រិតល្អ (M=3.62, SD=0.80)។ សូចនាករទី១៦ "មានសៀវភៅកត់ត្រាការចូលធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើចំណេះដឹងសមត្ថភាព"ល្អ" (M=4.37, SD=1.00) និងសូចនាករ "បានរៀបចំកម្មវិធីប្រជុំជំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់" បានទទួលការយល់ស្របទាបជាងគេក្នុងកម្រិត"មធ្យម" (M=2.96, SD=1.25)។

ផ្នែក (គ) "ការលើកទឹកចិត្ត" របស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ នៃសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិតល្អ (M=3.51, SD=0.97)។ សូចនាករ ទី១៧ "មានការគាំទ្រឲ្យអនុវត្តមេរៀនវិទ្យាសាស្ត្រក្នុងបន្ទប់ពិសោធន៍" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការលើកទឹកចិត្តក្នុងកម្រិត"ល្អ" (M=4.18, SD=0.96) និងសូចនាករ"ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ"បានទទួលការយល់ស្របទាបជាងគេក្នុងកម្រិត"មធ្យម" (M=2.35, SD=1.43)។

ផ្នែកទាំងបីនៃកម្រិតសមត្ថភាពរបស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធន មានតម្លៃមធ្យមខុសគ្នាៗ។ លំដាប់ពិន្ទុលើផ្នែកទី២" ចំណេះដឹងសមត្ថភាព" ស្ថិតក្នុងកម្រិតខ្ពស់ លំដាប់លេខ១គឺ M=3.62, SD=0.80 ផ្នែកទី៣"ការលើកទឹកចិត្ត" ស្ថិតក្នុងកម្រិតខ្ពស់លំដាប់លេខ២ M=3.51, SD=0.97 និងផ្នែកទី១"ការបង្រៀន និងរៀននៅបន្ទប់ពាិសោធន៍" ស្ថិតក្នុងកម្រិតមធ្យមលំដាប់លេខ៣ M=3.50, SD=0.78 ។ ជារួមឃើញថា កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាន មានតម្លៃមធ្យមកម្រិតខ្ពស់គឺ(M=3.54, SD=0.74)។ លទ្ធផលនេះបង្ហាញថា កម្រិតសមត្ថភាពរបស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន ឱ្យតម្លៃខ្ពស់លើចំណេះដឹងសមត្ថភាព ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន។

***តារាង៤.១០ ផ្នែកទាំង៣នៃកម្រិតសមត្ថភាពរបស់លោក លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍***

| ល.រ | កម្រិតសមត្ថភាពរបស់លោក លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ | M | SD | Level |
|---|---|---|---|---|
| ក | **ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍** | 3.50 | 0.78 | ល្អ |
| ខ | **ចំណេះដឹងសមត្ថភាព** | 3.62 | 0.80 | ល្អ |
| គ | **ការលើកទឹកចិត្ត** | 3.51 | 0.97 | ល្អ |
| | សរុប | 3.54 | 0.75 | ល្អ |

យោងតាមលទ្ធផលនៃតារាង៤.១០ ខាងលើបានបង្ហាញពីមធ្យមភាគសរុបនៃកម្រិតសមត្ថភាពពរបស់លោក លោកស្រីក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ របស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ នៃសាលាមធ្យមសិក្សាធនធាន ក្នុងខេត្ត ត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែងយល់ស្របក្នុងកម្រិត"ល្អ"(មធ្យមភាគ=៣.៥៤)។ ក្នុងផ្នែក(ខ) "ចំណេះដឹងសមត្ថភាព" ស្ថិតក្នុងចំណាត់ទី១ ដែលមាន M=3.62, SD=0.80។ ចំណុចនេះ ដោយសារតែកម្រិតសមត្ថភាពរបស់លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រយល់ថា "មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធន៍នៅ ក្នុងបន្ទប់ពិសោធន៍" (តារាង៤.៨សំណួរទី១៦) ក្នុងចំណោមលោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ចំនួន៤៨នាក់ បានជ្រើសរើសយកកម្រិតទី៤ គឺអនុវត្តបានច្រើនចំនួន១១នាក់ និងជ្រើសរើសយកកម្រិតទី៥ គឺអនុវត្តបានច្រើនបំផុត ចំនួន៣០នាក់ ជារួមទាំងពីរកម្រិតស្មើនឹង៨៥.៤២%។ ម្យ៉ាងទៀតសំណួរទី១៥"ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព" ក្នុងចំណោមលោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រដដែល បានជ្រើសរើសយកកម្រិតទី៤គឺអនុវត្តបានច្រើនចំនួន២៣នាក់ និងជ្រើសរើសយកកម្រិតទី៥ គឺអនុវត្តបានច្រើនបំផុត ចំនួន១៣នាក់ ជារួមទាំងពីរកម្រិតស្មើនឹង៧៥%។

អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបគុណវិស័យ ចំនួនពីរ គឺទី(១)តើលោកគ្រូ-អ្នកគ្រូជួបឧបសគ្គអ្វីខ្លះ ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន? និងទី(២)"តើលោកគ្រូ-អ្នកគ្រូមានសំណូមពរ ឬអនុសាសន៍យ៉ាងដូចម្តេចខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ?" អ្នកស្រាវជ្រាវធ្វើការវិភាគទិន្នន័យតាមបែបផ្តុំគំនិត រកអ្នកមានគំនិតឬយោបល់ដូចគ្នាចាត់ជាក្រុម ងាយស្រួលក្នុងការគិតជាភាគរយ។

ក.ឧបសគ្គក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាធនធាន

ចំពោះបញ្ហាប្រឈមដែលបានមកពីកម្រងសំណួរផ្នែកទី១ បានចង្អុលបង្ហាញថា ក្នុងចំណោមលោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រចំនួន៤៨នាក់ ភាគច្រើនបានលើកឡើងថា មិនចេះប្រើសម្ភារៈនិងឧបករណ៍ពិសោធន៍មួយចំនួនដូចជា មិនស្គាល់ឈ្មោះឧបករណ៍ពិសោធន៍ មិនដឹងពីរបៀបពិសោធន៍ មិនចេះប្រើសម្ភារៈពិសោធន៍ គឺលោកគ្រូ-អ្នកគ្រូខ្វះបទ

ពិសោធន៍ ហើយបើសិនសម្ភារៈពិសោធន៍ខូចគឺមិនអាចដោះស្រាយបានទេ។ លោកគ្រូ-អ្នកគ្រូវិទ្យាសាស្ត្រមួយចំនួនធំខ្វះចំណេះដឹងលើការពិសោធន៍គឺសមត្ថភាពនៅមានកម្រិត នេះមកពីលោកគ្រូ អ្នកទាំងនោះមិនបានបណ្តុះបណ្តាលបន្ថែម។ ចំនែកឯបរិវច្ឆការីវិញក៏មិនចេះប្រើឧបករណ៍ពិសោធន៍ មិនចេះប្រើប្រាស់មីក្រូទស្សន៍ និយាយរួមគឺខ្វះអ្នកឯកទេសបន្ទប់ពិសោធន៍ ហើយគ្មានការចែករំលែក ក្នុងការធ្វើពិសោធពីគ្រូដែលមានបទពិសោធន៍ ជាពិសេស ខ្វះអ្នកបច្ចេកទេសសម្រាប់ជំនួយពេលពិសោធន៍តែម្តង។

ផ្នែកសម្ភារៈនិងឧបករណ៍វិញមានការខ្វះខាតច្រើនដូចជាខ្វះសៀវភៅណែនាំអំពីរបៀបពិសោធន៍ សម្ភារៈមិនគ្រប់គ្រាន់សម្រាប់ធ្វើពិសោធ ខ្វះឯកសារដើម្បីធ្វើពិសោធ ហើយសម្ភារៈពិសោធន៍ភាគច្រើនមិនដំណើរការ និងសម្ភារៈពិសោធន៍មួយចំនួនទៀតមិនអាចប្រើប្រាស់បាន។ លោកគ្រូ-អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនទៀត បានលើកឡើងថាខ្វះឧបករណ៍ពិសោធន៍ និងសម្ភារៈឧបទ្វេសមួយចំនួន សម្រាប់រៀន និងបង្រៀន។ និយាយរួមសម្ភារៈ និងឧបករណ៍ពិសោធន៍ភាគច្រើនមានការខ្វះខាត ជាពិសេសខ្វះសារធាតុគីមីតែម្តងដែលជាសារធាតុចាំបាច់ ហើយគ្រូមិនមានសមត្ថភាពក្នុងការដោះស្រាយបាន។ លោកគ្រូ-អ្នកគ្រូក៏បានលើកឡើងទៀតថាសម្ភារៈពិសោធន៍មួយចំនួន មិនត្រូវតាមមេរៀន ដូចនេះគ្រូត្រូវតែស្វែងរកសម្ភារៈពិសោធន៍ទាំងនោះ ប៉ុន្តែសម្ភារៈពិសោធន៍មួយចំនួនពិបាកក្នុងការរកទិញ។ បើនិយាយរឿងទិញ គឺថវិកាមានកំណត់ អគារធនធានមានកញ្ចប់ថវិកាសម្រាប់ពិសោធន៍ហើយ ប៉ុន្តែថវិកាទាំងនោះមិនបម្រើឱ្យការពិសោធន៍ដោយរលូនទេ។

ផ្នែកបន្ទប់ពិសោធន៍៖លោកគ្រូ-អ្នកគ្រូមួយចំនួនទៀតបាននិយាយថា បន្ទប់ពិសោធន៍តូច ប្រៀបធៀបនឹងចំនួនសិស្សក្នុងមួយថ្នាក់ៗមានចំនួនចាប់ពី៤០ទៅ៥០នាក់សិស្សមិនអាចអង្គុយអស់គ្នា ហើយបន្ទប់ពិសោធន៍មានមិនគ្រប់តាមមុខវិជ្ជាវិទ្យាសាស្ត្រ។ នៅក្នុងអគារធនធាននីមួយៗ មានបន្ទប់ពិសោធន៍ពីរ ប៉ុន្តែមុខវិជ្ជាវិទ្យាសាស្ត្រមានបួនគឺរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដូចនេះបន្ទប់ពិសោធន៍តូចហើយក្នុងមួយបន្ទប់ដាក់ពីរមុខវិជ្ជាទៀត។ ម្យ៉ាងទៀតម៉ោងបង្រៀនតិច ហើយបន្ទប់ពិសោធន៍មិនសូវទំនេរដោយសារសាលាធនធានមានថ្នាក់រៀនច្រើន រួមទាំងសាលាបណ្តាញចូលមកពិសោធន៍ដែរ ដូចនេះសេវាសម្រាប់ពិសោធន៍មានមិនគ្រប់គ្រាន់ទេ។

លោកគ្រូ អ្នកគ្រូមួយចំនួនទៀតបានឆ្លើយថា សម្ភារៈពិសោធន៍មិនស្របតាមខ្លឹមសារមេរៀន ហើយបន្ទប់ពិសោធន៍មានមិនគ្រប់តាមមុខវិជ្ជា(បន្ទប់ពិសោធន៍មួយដាក់ពីរមុខវិជ្ជា)។ លោកគ្រូ អ្នកគ្រូភាគច្រើន បានលើកឡើងថាបន្ទប់ពិសោធន៍តូចចង្អៀត បើប្រៀបធៀបទៅនឹង

ចំនួនសិស្សក្នុងមួយថ្នាក់ សិស្សមានការពិបាកក្នុងការចូលមកសង្កេតមេរៀនពិសោធន៍ និងសម្ភារៈពិសោធន៍ភាគច្រើនមិនអាចដំណើរការ។ លោកគ្រូម្នាក់ បង្រៀនគីមីវិទ្យាថ្នាក់ទី១១និង១២ បានលើកឡើងថា គ្មានអ្នកគ្រប់គ្រងបន្ទប់ពិសោធន៍ច្បាស់លាស់។ លោកគ្រូ អ្នកគ្រូមួយចំនួនទៀត បានលើកឡើងថា មិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍ ហើយគ្រូវិទ្យាសាស្ត្រមួយចំនួនធំ មិនបានបណ្តុះបណ្តាល។ អ្នកគ្រូម្នាក់បង្រៀនជីវវិទ្យាថ្នាក់ទី១១និង១២បានលើកឡើងថា ខ្វះការលើកទឹកចិត្តគ្រូ ខ្វះឯកសារពិសោធន៍ និងខ្វះសម្ភារៈពិសោធន៍មួយចំនួន ។ លោកគ្រូ អ្នកគ្រូមួយចំនួនទៀតបានលើកឡើងថា សម្ភារៈមួយចំនួនមិនដំណើរការ ពីព្រោះវាចាស់ៗពេក និងសម្ភារៈពិសោធន៍មួយផ្នែកទៀតពិបាករកទិញ មិនដឹងទៅរកទិញនៅឯណា ។ លោកគ្រូ អ្នកគ្រូភាគច្រើនមិនចេះប្រើមីក្រូទស្សន៍ គ្មានអ្នកឯកទេសជួយបង្ហាត់បង្រៀន ជាពិសេសឧបករណ៍មើលផ្កាយ។ លោកគ្រូម្នាក់បង្រៀនជីវវិទ្យាថ្នាក់ទី១១ បានលើកឡើងថា ខ្វះចំណេះដឹងលើការពិសោធន៍ និងថវិកាមិនគ្រប់គ្រាន់សម្រាប់ទិញសម្ភារៈពិសោធន៍ និងចំណុចខ្វះខាតផ្សេងទៀតដូចដែលបានរៀបរាប់ខាងលើ។

បញ្ហាប្រឈមនានា នៃការប្រើប្រាស់បន្ទប់ពិសោធន៍ របស់អគារធនធាន បានជួបឧបសគ្គជាច្រើនដូចជាខ្វះអ្នកបច្ចេកទេស ឬគ្រូជំនាញផ្នែកបន្ទប់ពិសោន៍ ពោលគឺបរិវច្ឆការីមិនមែនជាគ្រូឯកទេសនិងមិនបានបណ្តុះបណ្តាល។ តាមការសង្កេតក្នុងចំណោមវិទ្យាល័យធនធានទាំងបួន មានវិទ្យាល័យធនធានចំនួនបីដែលមានបរិវច្ឆការីចំនួនបីភាគបួន ជាគ្រូបង្រៀនកម្រិតមូលដ្ឋានហើយបង្រៀននៅថ្នាក់ទី៧ទៀត ជាពិសេសជាងនេះទៅទៀតនោះនៅវិទ្យាល័យ ធនធានមួយនៅក្នុងខេត្តព្រៃវែង មានបរិវច្ឆការីតែពីរនាក់ទេ កាន់បន្ទប់ពិសោធន៍មានបួនមុខវិជ្ជា គឺម្នាក់កាន់ពីរមុខវិជ្ជា ហើយក្នុងចំណោមបរិវច្ឆការីពីរនាក់នេះ មានម្នាក់កាន់ខុសឯកទេសទៀត គឺលោកនាយកយកគ្រូទីចាត់ការដែលមានឯកទេសអក្សរសាស្ត្រអង់គ្លេសឱ្យមកកាន់បន្ទប់ពិសោធន៍ និយាយជារួមគឺខ្វះការចូលរួមពីលោកគ្រូ-អ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្រតែម្តង ។ មួយវិញទៀតគ្រូវិទ្យាសាស្ត្រមួយចំនួនធំដែលកំពុងបង្រៀន មិនធ្លាប់ទទួលការបណ្តុះបណ្តាលពីរបៀបធ្វើពិសោធ ធ្វើឱ្យលោកគ្រូ-អ្នកគ្រូមិនស្គាល់ និងមិនចេះប្រើប្រាស់សម្ភារៈពិសោធន៍ មានន័យថាចំណេះដឹងលើការពិសោធន៍របស់លោកគ្រូ-អ្នកគ្រូនៅមានកម្រិត។ មួយវិញទៀតលោកនាយកនៃអគារធនធាន លោកពិបាកជ្រើសរើសគ្រូ មកកាន់បន្ទប់ពិសោធន៍ណាស់ ដោយសារលោកគ្រូ-អ្នកគ្រូទាំងនោះ គាត់បានបដិសេធក្នុងការចូលកាន់បន្ទប់ពិសោធន៍ ពីព្រោះបន្ទប់ពិសោធន៍មិនបានផ្តល់លាភសក្ការៈដល់ពួកគាត់។ បញ្ហាប្រឈមមួយទៀតគឺ ខ្វះខាតសម្ភារៈសម្រាប់ប្រើប្រាស់ធ្វើពិសោធតែម្តង ពោលគឺក្នុងបន្ទប់ពិសោធន៍នៃ

អគារធនធាន មិនមានសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើពិសោធ ជាពិសេសខ្វះសារធាតុគីមី និងពិបាករកទិញវាខ្លាំងណាស់។ ម្យ៉ាងទៀតសម្ភារៈមួយចំនួនមិនមានតាមតម្រូវការមេរៀនរបស់គ្រូបង្រៀន ហើយសម្ភារៈពិសោធន៍ខ្លះចាស់ឬក៏ខូចប្រើមិនបាន និងពិបាករកកន្លែងជួសជុលដែលធ្វើឱ្យដំណើរការពិសោធន៍គ្មានសកម្មភាព។ មួយវិញទៀតគឺខ្វះឯកសារពិសោធន៍ ឬសៀវភៅណែនាំសម្រាប់ធ្វើពិសោធ ដែលជាលេសធ្វើឱ្យលោកគ្រូ អ្នកគ្រូមានហេតុផលថាគាត់មិនចង់ដឹកនាំសិស្សចូលបន្ទប់ពិសោធន៍។ បញ្ហាមួយទៀតដែលជាបញ្ហាស្នូលដែរនោះ គឺខ្វះខាតថវិកាសម្រាប់ទិញសម្ភារៈសម្រាប់ធ្វើពិសោធតែម្តង ពោលអគារធនធានគឺមានថវិកាមួយផ្នែកសម្រាប់ធ្វើពិសោធហើយ ប៉ុន្តែថវិកាទាំងនោះវាមិនបម្រើឱ្យការធ្វើពិសោធប្រព្រឹត្តទៅដោយរលូនទេ។ បញ្ហាប្រឈមមួយទៀតគឺខ្វះបន្ទប់ពិសោធ មានន័យថាបន្ទប់ពិសោធន៍មិនបម្រើតាមតម្រូវការរបស់សិស្សទេ ពោលគឺបន្ទប់ពិសោធន៍តូច បើប្រៀបធៀបនឹងសិស្សក្នុង១ថ្នាក់ៗ ដែលថ្នាក់ខ្លះមានរហូតដល់ជាងហាសិបនាក់ ហើយបន្ទប់ពិសោធន៍មិនគ្រប់តាមមុខវិជ្ជាទៀត គឺក្នុងវិទ្យាល័យធនធាននីមួយៗមានបន្ទប់ពិសោធន៍ចំនួនពីរ ចំណែកឯមុខវិជ្ជាវិទ្យាសាស្ត្រមានរហូតដល់បួនមុខវិជ្ជាឯណោះ។ មួយវិញទៀតពេលវេលាសម្រាប់សិស្សចូលបន្ទប់ពិសោធន៍មិនគ្រប់គ្រាន់ ពោលគឺម៉ោងពិសោធន៍សម្រាប់ថ្នាក់នីមួយៗបានតិចម៉ោងក្នុងមួយសប្តាហ៍ ដោយសារតែនៅវិទ្យាល័យធនធាននីមួយៗ មានបន្ទប់ពិសោធន៍ចំនួនពីរ ហើយថ្នាក់រៀនមានច្រើនថ្នាក់ និងបូករួមទាំងថ្នាក់រៀនរបស់សាលាបណ្តាញថែមទៀត។ កត្តាទាំងអស់នេះហើយដែលធ្វើឱ្យមន្ទីរពិសោធន៍របស់អគារធនធានជួបនូវបញ្ហាប្រឈម ដែលទាមទារឱ្យគណៈគ្រប់គ្រងអគារធនធានមានសំណូមពរយ៉ាងណាទៅក្រសួងអប់រំ យុវជន និងកីឡា ឬក៏មានវិធីសាស្ត្រយ៉ាងដូចម្តេច ដើម្បីដោះស្រាយបញ្ហាប្រឈមនៅចំពោះមុខបានដោយរលូន។ ជាក់ស្តែងដូចក្រុមស្រាវជ្រាវមួយរបស់កញ្ញា ថ្លាង សូរិយា ដែលមានគ្នា៥នាក់ គឺ(១)កញ្ញា ថ្លាង សូរិយា ប្រធាន (២)លោកស្រី អ៊ុំ សុចិន្តា សមាជិក (៣)លោក ទី ប៉ូលីរស្មី សមាជិក(៤)លោក ឃី មឿយ សមាជិក (៥)លោក ទៀង សោភទ្រា សមាជិក បានរកឃើញថាការប្រើប្រាស់ទីពិសោធន៍វិទ្យាសាស្ត្រក្នុងអគារធនធានគឺ"នៅមានកម្រិតនៅឡើយ"។ ក្រុមនេះបានរកឃើញអំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់ទីពិសោធន៍វិទ្យាសាស្ត្រនៅវិទ្យាល័យធនធាន រួមមាន សម្ភារៈប្រើប្រាស់សម្រាប់ធ្វើពិសោធក្នុងអគារធនធាន"មិនទាន់គ្រប់គ្រាន់" ហើយសម្ភារៈខ្លះ"មិនមានតាមតម្រូវការ"របស់គ្រូបង្រៀន។ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួន"មិនធ្លាប់ទទួលការបណ្តុះបណ្តាល" ពីរបៀបធ្វើពិសោធ មួយចំនួនទៀតចេះធ្វើពិសោធងាយៗបានតិចតួច។

ជាចុងក្រោយមានលោកគ្រូ អ្នកគ្រូចំនួន៥នាក់ ស្មើនឹង១០.៤២% មិនបានបញ្ចេញយោបល់អ្វីបន្តិចសោះ។

ខ.សំណូមពរ ឬអនុសាសន៍ ក្នុងការដោះស្រាយបញ្ហាប្រឈម

ចំណែកឯកម្រងសំណួរទី(២)"តើលោកគ្រូ-អ្នកគ្រូមានសំណូមពរ ឬអនុសាសន៍យ៉ាងម្តេចខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ?" លោកគ្រូ អ្នកគ្រូភាគច្រើន បាននិយាយថា សូមឱ្យក្រសួងអប់រំ យុវជន និងកីឡាសូមក្រសួងអប់រំបំប៉នគ្រូវិទ្យាសាស្ត្រ និងបរិវច្ឆការី កុំយកតែប្រធានក្រុមបច្ចេកទេស ជាពិសេសសូមក្រសួងបើកវគ្គបង្រៀនការពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤ នៅថ្នាក់ទី១០ ១១ ១២ ដើម្បីឱ្យគ្រូមានជំនាញក្នុងការធ្វើពិសោធន៍។ លោកគ្រូ-អ្នកគ្រូមួយចំនួនទៀត សូមក្រសួងអប់រំបើកសិក្ខាសាលា ឬបើកវគ្គបំប៉នគ្រូវិទ្យាសាស្ត្រ និងបរិវច្ឆការីស្តីពីរបៀបប្រើប្រាស់ឧបករណ៍ពិសោធន៍ ហើយផ្តល់ឯកសារពិសោធន៍គ្រប់មេរៀន រួមទាំងសារធាតុគីមីស្របទៅនឹងមេរៀនគ្រប់កម្រិតថ្នាក់ ហើយបណ្តុះបណ្តាលគ្រូជាមួយប្រធានបទថ្មីៗ និងផ្តល់ជំនាញមកបង្ហាត់បង្ហាញមើលមីក្រូទស្សន៍។ លោកគ្រូ-អ្នកគ្រូខ្លះទៀត សូមឱ្យក្រសួងអប់រំបណ្តុះបណ្តាលនិស្សិតលើមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤ ធ្វើជាបរិវច្ឆការីតែម្តង គឺបណ្តុះបណ្តាលលើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា សម្រាប់កាន់បន្ទប់ពិសោធន៍។ លោកគ្រូ-អ្នកគ្រូមួយផ្នែកទៀត សូមក្រសួងអប់រំ យុវជន និងកីឡា មេត្តាផ្តល់ឯកសារឧបករណ៍និងសម្ភារៈពិសោធន៍ឱ្យបានគ្រប់គ្រាន់ ហើយស្របនឹងមេរៀនតាមកម្រិតថ្នាក់នីមួយៗ និយាយជារួមឯកសារពិសោធន៍ឱ្យគ្រប់មេរៀនដូចសៀវភៅសិក្សាគោល។ម្យ៉ាងទៀតលោកគ្រូ អ្នកគ្រូមួយចំនួនសុំឱ្យក្រសួងអប់រំជួយផ្តល់សម្ភារៈពិសោធន៍ថ្មីៗឡើងវិញឱ្យបានច្រើន ពីព្រោះសម្ភារៈពិសោធន៍ដែលនៅសព្វថ្ងៃ ភាគច្រើនចាស់ៗ និងខូចខាតអស់ហើយ។ លោកគ្រូ-អ្នកគ្រូមួយក្រុមទៀត សូមក្រសួងអប់រំផ្តល់បន្ទប់ពិសោធន៍តាមមុខវិជ្ជាវិទ្យាសាស្ត្រនីមួយៗ គឺរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដើម្បីមានភាពងាយស្រួលក្នុងដំណើរការពិសោធន៍ផង និងមួយទៀតងាយស្រួលក្នុងការទុកដាក់ឧបករណ៍ឬសម្ភារៈពិសោធន៍ផងដែរ ជាពិសេសទៅទៀតនោះគឺជួយម៉ោងពិសោធន៍ឱ្យបានច្រើន ។ ម្យ៉ាងទៀតលោកគ្រូ អ្នកគ្រូមួយចំនួនសូមឱ្យក្រសួងអប់រំបន្ថែមម៉ោងពិសោធន៍ឱ្យបានម៉ោងច្រើន ដើម្បីយកម៉ោងនោះមកធ្វើពិសោធន៍ និងសូមឱ្យក្រសួងអប់រំ ជួយពង្រឹងដំណើរការពិសោធន៍ឱ្យមានភាពសស្រាក់សស្រាំឡើង។ លោកគ្រូ-អ្នកគ្រូមួយក្រុមទៀត សូមឱ្យក្រសួងអប់រំ យុវជន និងកីឡា មេត្តាជួយបន្ថែមថវិការបស់អគារធនធានសម្រាប់ពិសោធន៍ឱ្យបានប្រសើរជាងសព្វថ្ងៃបន្តិច ពីព្រោះថវិកាសព្វថ្ងៃនេះមិនបម្រើឱ្យដំណើរការពិសោធន៍ប្រព្រឹត្តទៅដោយរលូនទេ។

ជារួមអ្នកស្រាវជ្រាវសង្កេតឃើញថា  លោកគ្រូ-អ្នកគ្រូភាគច្រើនសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ជួយបណ្តុះបណ្តាលគ្រូវិទ្យាសាស្ត្រនិងបរិវច្ឆការីលើផ្នែកពិសោធន៍ និងជួយបន្ថែមឧបករណ៍-សម្ភារៈពិសោធន៍ ផ្តល់បន្ទប់ពិសោធន៍ឱ្យបានគ្រប់មុខវិជ្ជា ព្រមទាំងជួយបន្ថែមថវិកាដល់អគារធនធានក្នុងផ្នែកពិសោធន៍។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូកទី ៥
# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវដែលបានផ្ដោតទៅលើ ការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្ររបស់អគារធនធាន នៃសាលាមធ្យមសិក្សាធនធាន **នៅមានកម្រិតនៅឡើយ**។ ការចូលធ្វើពិសោធ ដែលជាសកម្មភាពមួយ បានជួយគាំទ្រដល់មេរៀនក្នុងថ្នាក់បានមួយកម្រិតទៀតនោះ ជាពិសេសធ្វើឱ្យសិស្សយល់កាន់តែច្បាស់ពីទ្រឹស្ដី និងបញ្ញត្តិផ្សេងៗក្នុងផ្នែកវិទ្យាសាស្ត្ររបស់លោកគ្រូ-អ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្រនៃអគារធនធានរបស់សាលាមធ្យមសិក្សាធនធាន មិនអស់លទ្ធភាពនៅឡើយទេ។

បញ្ហាប្រឈមក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន រួមមានៈ

- សម្ភារៈប្រើប្រាស់សម្រាប់ធ្វើពិសោធក្នុងអគារធនធានមិនទាន់គ្រប់គ្រាន់
- សម្ភារៈមួយចំនួនមិនមានតាមតម្រូវការរបស់គ្រូបង្រៀន
- គ្រូវិទ្យាសាស្ត្រមួយចំនួនធំមិនធ្លាប់ទទួលការបណ្ដុះបណ្ដាលពីរបៀបធ្វើពិសោធ
- បរិវច្ឆការីមិនមែនជាគ្រូឯកទេសនិងមិនបានបណ្ដុះបណ្ដាល
- លោកគ្រូ-អ្នកគ្រូមួយចំនួនមិនស្គាល់ និងមិនចេះប្រើប្រាស់សម្ភារៈពិសោធន៍
- ចំណេះដឹងលើការពិសោធរបស់លោកគ្រូ-អ្នកគ្រូខ្លះនៅមានកម្រិត
- ខ្វះការចូលរួមពីលោកគ្រូ-អ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ
- ខ្វះសារធាតុគីមី និងពិបាករកទិញវាសម្រាប់ពិសោធន៍
- ខ្វះអ្នកបច្ចេកទេស ឬគ្រូជំនាញផ្នែកបន្ទប់ពិសោន៍
- ខ្វះឯកសារពិសោធន៍ ឬសៀវភៅណែនាំសម្រាប់ធ្វើពិសោធ
- ខ្វះថវិកាសម្រាប់ទិញសម្ភារៈសម្រាប់ធ្វើពិសោធ
- សម្ភារៈពិសោធន៍ខូចប្រើមិនបាន ហើយពិបាករកកន្លែងជួសជុល
- ពេលវេលា(ម៉ោង)មិនគ្រប់គ្រាន់សម្រាប់ពិសោធន៍
- បន្ទប់ពិសោធន៍តូច បើប្រៀបធៀបនឹងសិស្សក្នុង១ថ្នាក់ៗ
- បន្ទប់ពិសោធន៍មិនគ្រប់តាមមុខវិជ្ជាវិទ្យាសាស្ត្រទាំង៤

- ពិបាកជ្រើសរើសគ្រូ មកកាន់បន្ទប់ពិសោធន៍

## ៥.២ សំណូមពរ

ដើម្បីរួមចំណែកក្នុងការលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់បន្ទប់ពិសោធរបស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន ក៏ដូចជាការចូលរួមមួយផ្នែកក្នុងការលើកកម្ពស់ប្រសិទ្ធភាព ពិសោធន៍វិទ្យាសាស្ត្រនៃអគារធនធានទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលអ្នកសិក្សាបានរកឃើញ ហើយតាមរយៈនេះ អ្នកសិក្សាសូមលើកនូវសំណូមពរមួយចំនួនជូនដល់សាលា ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអ្នកពាក់ព័ន្ធនានា ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដើម្បីពិនិត្យ កែលម្អ និងដោះស្រាយទៅតាមស្ថានភាព និងលទ្ធភាពជាក់ស្តែងដូចតទៅៈ

### ១. សម្រាប់សាលា

- ត្រូវមានសៀវភៅណែនាំ កិច្ចតែងការធ្វើពិសោធ និងរបៀបធ្វើរបាយការណ៍ពិសោធន៍ ព្រមទាំងសៀវភៅកត់ត្រាការចូលធ្វើពិសោធ
- ជំរុញគ្រូមិនដែលធ្លាប់បានរៀនពិសោធ បានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានានាលើផ្នែកធ្វើពិសោធ
- គណៈគ្រប់គ្រងសាលា ត្រូវពង្រឹងយន្តការអនុវត្តក្នុងការប្រើប្រាស់បន្ទប់ពិសោធវិទ្យាសាស្ត្ររបស់គ្រូនិងសិស្សឱ្យអស់លទ្ធភាព

### ២. សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

- ជួយបើកវគ្គបណ្តុះបណ្តាលផ្នែកពិសោធន៍ទាំងបួនមុខវិជ្ជាឱ្យបានច្រើន
- កាលវិភាគពិសោធន៍ គួរកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា
- គួរមានបន្ទប់ពិសោធដាច់ពីគ្នាតាមមុខវិជ្ជានីមួយៗ
- ត្រូវមានឧបករណ៍ និងសារធាតុគីមីគ្រប់គ្រាន់សម្រាប់ពិសោធន៍
- ផ្តល់សម្ភារៈ និងធាតុគីមីបន្ថែមមួយចំនួន
- រៀបចំឱ្យមានម៉ោងពិសោធន៍ ផ្សេងពីម៉ោងបង្រៀន
- សូមឱ្យមាន LCD តាមបន្ទប់ពិសោធន៍
- ត្រូវការសម្លៀកបំពាក់ និងសៀវភៅសម្រាប់ធ្វើពិសោធ
- ផ្តល់ឧបករណ៍ជំនួយសំឡេងដល់គ្រូបង្រៀន
- សម្ភារៈប្រើប្រាស់ បង្កើនថវិកាសម្រាប់ធ្វើពិសោធ

- ផ្តល់គ្រូដែលមានឯកទេសពិសោធន៍ សម្រាប់កាន់បន្ទប់ពិសោធន៍
- សុំឱ្យមានបន្ទប់ពិសោធន៍សម្រាប់មុខវិជ្ជានីមួយៗ
- បង្រៀនពីរបៀបប្រើប្រាស់ឧបករណ៍ពិសោធន៍ឱ្យបានច្បាស់លាស់
- មានឧបករណ៍ពិសោធន៍ឱ្យចំមេរៀនដែលត្រូវធ្វើពិសោធ
- ផ្តល់ឯកសារពិសោធន៍ឱ្យបានគ្រប់គ្រាន់ និងផ្តល់រូបភាពពណ៌ដែលទាក់ទងនឹងការធ្វើពិសោធ
- រៀបចំកម្មវិធី និងមេរៀនដែលត្រូវពិសោធ តាមកម្រិតថ្នាក់
- ចំពោះគ្រូដែលមានជំនាញខាងពិសោធន៍ សូមឧស្សាហ៍ចុះជួយពង្រឹងតាមបន្ទប់ពិសោធន៍របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធាន

## ៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ដោយសារតែការសិក្សាស្រាវជ្រាវនេះផ្តោតតែទៅលើការប្រើប្រាស់បន្ទប់ពិសោធរបស់អគារធនធាន ដែលជាទូទៅនៅក្នុងអគារធនធានមានផ្នែកជាច្រើនទៀតដែលត្រូវសិក្សាស្រាវជ្រាវ និងមួយផ្នែកទៀតអ្នកសិក្សា បានជ្រើសរើសយកអគារធនធាននៅក្នុងខេត្តបីប៉ុណ្ណោះគឺ ខេត្តត្បូងឃ្មុំ ខេត្ត កំពង់ចាម និងខេត្តព្រៃវែង ដែលមានអគារធនធានសរុបចំនួនបួន។ មកដល់បច្ចុប្បន្ននេះ អគារធនធានដែលកំពុងដំណើរការទូទាំង២៥ខេត្ត/ក្រុង នៅក្នុងប្រទេសកម្ពុជាមានចំនួន៣៦ និងកំពុងបន្តការសាងសង់អគារធនធានចំនួន១៤ទៀត ដែលនឹងសង់រួចក្នុងត្រីមាសទី១នៃឆ្នាំ២០២០នេះ។ សម្រាប់ការសិក្សាបន្ត អ្នកស្រាវជ្រាវដទៃទៀតអាចធ្វើការពិចារណាទៅលើ៖

- ស្ថានភាពនៃការប្រើប្រាស់បន្ទប់កុំព្យូទ័រ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធានស្ថិតនៅខេត្តផ្សេងពីនេះ ហើយអ្នកស្រាវជ្រាវអាចជ្រើសរើសសំណាកធំជាងនេះ និងប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការធ្វើការសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយសំណួរ
- ស្ថានភាពនៃការប្រើប្រាស់បណ្ណាល័យ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធានស្ថិតនៅខេត្តផ្សេងពីនេះ ហើយអ្នកស្រាវជ្រាវអាចជ្រើសរើសសំណាកធំជាងនេះ និងប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការធ្វើការសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយសំណួរ

- ស្ថានភាពនៃការប្រើប្រាស់បន្ទប់ប្រជុំ របស់អគារធនធាននៃសាលាមធ្យមសិក្សាធនធានស្ថិតនៅខេត្តផ្សេងពីនេះ ហើយអ្នកស្រាវជ្រាវអាចជ្រើសរើសសំណាកធំជាងនេះ និងប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការធ្វើការសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយសំណួរ
- ស្ថានភាពនៃការប្រើប្រាស់មូលនិធិ និងប្រាក់ចំណូលរបស់អគារធនធាននៃសាលាមធ្យមសិក្សាធនធានស្ថិតនៅខេត្តផ្សេងពីនេះ ហើយអ្នកស្រាវជ្រាវអាចជ្រើសរើសសំណាកធំជាងនេះ និងប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការធ្វើការសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយសំណួរ
- ស្ថានភាពនៃការប្រើប្រាស់អគារធនធាន នៅកម្ពុជារបស់សាលាបណ្តាញ។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៩) ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៨) ឯកសារស្តង់ដាសាលាមធ្យមសិក្សាធនធាន

ក្រសួងអប់រំ យុវជន និងកីឡា, (២០០៨) គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា, (២០១១) សៀវភៅណែនាំណែនាំប្រតិបត្តិសាលាមធ្យមសិក្សាធនធាន របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០០៨

សេចក្តីណែនាំលេខ០៦អយក.សណន ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ស្តីពីតួនាទី និងភារកិច្ចវិទ្យាល័យធនធាន និងបណ្តាញ

សេចក្តីណែនាំលេខ០៧អយក.សណន ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ស្តីពីការគ្រប់គ្រង និងដំណើរអគារធនធាន នៃវិទ្យាល័យធនធាន

សេចក្តីណែនាំលេខ២៦អយក.សណន ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់លក្ខណៈសម្បត្តិ និងប្រើប្រាស់ថវិកាសម្រាប់ដំណើរការរបស់ នៃវិទ្យាល័យធនធាន

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៦) គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៨) សមិទ្ធិផលការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម)

ក្រសួងអប់រំ យុវជន និងកីឡា,(2018-2019) ស្ថិតិ និងសូចនាករអប់រំសាធារណៈ របស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖២៤ សីហា ២០១៥ ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០១៥

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖២២ សីហា ២០១៦ ចុះថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ២០១៦

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖២១ សីហា ២០១៧ ចុះថ្ងៃទី១០ ខែ កញ្ញាឆ្នាំ២០១៧

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖២០ សីហា ២០១៨ ចុះថ្ងៃទី១៣ ខែកញ្ញាឆ្នាំ២០១៨

ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖១៩ សីហា ២០១៩ ចុះថ្ងៃទី៩ ខែ កញ្ញា ឆ្នាំ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ(២០១១), បញ្ជីរាយនាមសាលាមធ្យមសិក្សាធនធាន និងបណ្តាញ ក្រោមគម្រោងEEQP

ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ(២០១៩), បញ្ជីរាយនាមសាលាមធ្យមសិក្សាធនធាន៥០ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2)

ក្រសួងអប់រំ យុវជន និងកីឡា, ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ៣២៧៧ អយក.ប្រក ចុះថ្ងៃទី៤ ខែ ធ្នូ ឆ្នាំ២០១០

ក្រសួងអប់រំ យុវជន និងកីឡា, ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ២៥៩០ អយក.ប្រក ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១១

ក្រសួងអប់រំ យុវជន និងកីឡា, ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ៦០៣ អយក.ប្រក ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០១៣

ក្រសួងអប់រំ យុវជន និងកីឡា, ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ១០១០ អយក.ប្រក ចុះថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០១៤

ឯកសារស្រាវជ្រាវរបស់ក្រុមអ្នកគ្រូ ថ្លាង សូរិយា, ស្តីពីលទ្ធភាពរបស់គ្រូក្នុងការប្រើប្រាស់ទីពិសោធន៍វិទ្យាសាស្ត្រ នៅវិទ្យាល័យធនធានក្នុងប្រទេសកម្ពុជា

របាយការណ៍សង្ខេបស្តីពីការចុះពិនិត្យមើលដំណើរការប្រតិបត្តិអគារធនធានវិទ្យាល័យសម្តេចតេជោហ៊ុនសែន.សួង, របស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត ត្បូងឃ្មុំ, ចុះថ្ងៃអង្គារ ១០រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០

McComas, W.F.(1998). The nature of science in science education: Rationales and strategies. Dordrecht, The Nethelands: Kluwer Academic Publishers.

Reinders Duit & Maikie Tesch.(2010). On the role of the experiment in science teaching and learning visions and the reality of instructional pratice. Institue for science and mathematic.

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរស្រាវជ្រាវ

## សម្រាប់លោកនាយក/នាយករង និងបរិវច្ឆការី

ខ្ញុំបាទឈ្មោះ **រៀម ធា** ជានិស្សិតវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរ និក្ខេបបទបញ្ចប់ការសិក្សា លើប្រធានបទស្តីពី "ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា"។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យពីសាលាមធ្យមសិក្សាធនធាន ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង ។ ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយទៅលើ ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ នៃសាលាមធ្យមសិក្សាធនធាន នៅតាមបណ្តាខេត្តដែលបានជម្រាបជូនខាងលើ។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយករង និងបរិវច្ឆការី មេត្តាចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។ ការចូលរួមផ្តល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់ សម្រាប់ ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគ សម្រាប់តែការសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្ញុំបាទតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោក/លោកស្រី។

## I. ព័ត៌មានទូទៅ

១. ឈ្មោះសាលាមធ្យមសិក្សាធនធាន៖..............................................................

ស្រុក៖..................................ខេត្ត៖.............................................

២. ភេទ: ☐ ប្រុស ☐ ស្រី

៣អាយុ៖. ☐ ពី២០-៣០ ☐ ពី ៣១-៤០ ឆ្នាំ ☐ ពី ៤១-៥០ ឆ្នាំ ☐លើស៥០ ឆ្នាំ

៤.កម្រិតវប្បធម៌៖ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ បណ្ឌិត ☐ ផ្សេងៗ....

៥. ក្របខណ្ឌ៖ ☐គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐គ្រូបង្រៀនកម្រិតឧត្តម

៦.មុខវិជ្ជាឯកទេស៖..............................................................

៧.មុខវិជ្ជាធ្លាប់បង្រៀន៖.......................................................ថ្នាក់ទី៖.............................

៨.បទពិសោធន៍ជាគណៈគ្រប់គ្រងនៅក្នុងសាលាមធ្យមសិក្សាធនធាន(SRC)

☐ ១-៣ ឆ្នាំ ☐ ៤-៦ ឆ្នាំ ☐ ៧-៩ ឆ្នាំ ☐ ចាប់ពី ១០ឆ្នាំឡើង

៩.តើលោក/លោកស្រីធ្លាប់ចូលរួមការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលាមធ្យមសិក្សាធនធានដែរឬទេ? ១.ធ្លាប់☐ ២.មិនធ្លាប់☐

## II.កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់អគារធនធាន

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងកម្រិតតែមួយប៉ុណ្ណោះ ដែលត្រូវនឹងការអនុវត្តជាក់ស្តែងពិតប្រាកដរបស់លោក/លោកស្រីក្នុងតារាងខាងក្រោម។

កម្រិតចង្អុលបង្ហាញ៖

១ = ១% - ២០% គឺអនុវត្តបានតិចបំផុត

២ = ២១% - ៤០% គឺអនុវត្តបានតិច

៣ = ៤១% - ៦០% គឺអនុវត្តបានមធ្យម

៤ = ៦១% -៨០% គឺអនុវត្តបានច្រើន

៥ = ៨១% - ១០០% គឺអនុវត្តបានច្រើនបំផុត

| ល.រ | បរិយាយ | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ការគ្រប់គ្រងបន្ទប់ពិសោធន៍ | | | | | | |
| ១ | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | | | | | |
| ២ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលគ្រូ ទាក់ទងការងារបន្ទប់ពិសោធន៍ | | | | | |
| ៣ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | | | | | |
| ៤ | ធ្វើឱ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញឯកទេសច្បាស់លាស់ | | | | | |
| ៥ | ស្វែងរកប្រាក់ចំណូល-ថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | | | | | |
| ៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | | | | | |
| ៧ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | | | | | |
| ក្របខណ្ឌសមត្ថភាពបច្ចេកទេស | | | | | | |
| ៨ | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | | | | | |
| ៩ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | | | | | |
| ១០ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្តាញទាំងអស់ | | | | | |
| ១១ | ធានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | | | | | |
| ១២ | មានកាលវិភាគថ្នាក់-គ្រូនៅមុខបន្ទប់ពិសោធន៍ | | | | | |
| កិច្ចគាំទ្រការបង្រៀន និងរៀន | | | | | | |
| ១៣ | មានការគាំទ្រនិងលើកទឹកចិត្តគ្រូ-សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | | | | | |
| ១៤ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | | | | | |
| ១៥ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | | | | | |
| ១៦ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ-អ្នកគ្រូ | | | | | |
| ១៧ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | | | | | |
| កិច្ចសហប្រតិបត្តិការ | | | | | | |
| ១៨ | សាលាមធ្យមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | | | | | |
| ១៩ | បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | | | | | |
| ២០ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | | | | | |
| ២១ | ចែករំលែក ធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | | | | | |
| ២២ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | | | | | |

## III.យោបល់បន្ថែម

១.តើលោក/លោកស្រីជួបបញ្ហាលំបាកអ្វីខ្លះ ក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍ នៅសាលាមធ្យមសិក្សាធនធាន?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

២.តើលោក/លោកស្រីមានសំណូមពរ ឬអនុសាសន៍យ៉ាងណាខ្លះ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរស្រាវជ្រាវ
## សម្រាប់លោកគ្រូ-អ្នកគ្រូ បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងពិសោធន៍

ខ្ញុំបាទឈ្មោះ ញ៉ែម ធា ជានិស្សិតវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរ និក្ខេបបទបញ្ចប់ការសិក្សា លើប្រធានបទស្តីពី "ស្ថានភាពនៃការប្រើប្រាស់អគារធនធាននៅកម្ពុជា"។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យពីសាលាមធ្យមសិក្សាធនធាន ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្ត ត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្ត ព្រៃវែង ។ ការសិក្សាស្រាវជ្រាវនេះមានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយទៅលើ ស្ថានភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ នៃសាលាមធ្យមសិក្សាធនធាន នៅតាមបណ្តាខេត្តដែលបានជម្រាបជូនខាងលើ។

អាស្រ័យហេតុនេះ សូមលោកគ្រូ-អ្នកគ្រូ មេត្តាចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។ ការចូលរួមផ្តល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគ សម្រាប់តែការសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្ញុំបាទតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោកគ្រូ-អ្នកគ្រូ។

## I. ព័ត៌មានទូទៅ

១. ឈ្មោះសាលាមធ្យមសិក្សាធនធាន៖..................................................................

ស្រុក៖..................................ខេត្ត៖.............................................

២. ភេទ៖ ☐ ប្រុស ☐ ស្រី

៣. អាយុ៖ ☐ ២០-៣០ ឆ្នាំ ☐ ៣១-៤០ ឆ្នាំ ☐ ៤១-៥០ ឆ្នាំ ☐ លើស៥០ ឆ្នាំ៤.កម្រិតវប្បធម៌៖ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ បណ្ឌិត ☐ ផ្សេងៗ..............

៥. ក្របខណ្ឌ៖ ☐គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐គ្រូបង្រៀនកម្រិតឧត្តម

៦. មុខវិជ្ជាឯកទេស៖...........................................

៧.មុខវិជ្ជាធ្លាប់បង្រៀន៖.............................................ថ្នាក់ទី៖.......................................

៨. បទពិសោធន៍ក្នុងការងាពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ៖

☐ ១-៣ ឆ្នាំ ☐ ៤-៦ ឆ្នាំ ☐ ៧-៩ ឆ្នាំ ☐ ចាប់ពី ១០ឆ្នាំឡើង

៩.តើលោគ្រូ-អ្នកគ្រូ ធ្លាប់ចូលរួមការបណ្តុះបណ្តាល ស្តីពីការធ្វើពិសោធ នៃសាលាមធ្យមសិក្សាធនធានដែរឬទេ? ☐ ធ្លាប់ ☐ មិនធ្លាប់

## II.កម្រិតសមត្ថភាពរបស់លោក/លោកស្រី ក្នុងការប្រើប្រាស់អគារធនធាន

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងកម្រិតតែមួយប៉ុណ្ណោះ ដែលត្រូវនឹងការអនុវត្តជាក់ស្តែងពិតប្រាកដរបស់លោក លោកស្រី ក្នុងតារាងខាងក្រោម។/

កម្រិតចង្អុលបង្ហាញ៖

១ = ១% - ២០% គឺអនុវត្តបានតិចបំផុត

២ = ២១% - ៤០% គឺអនុវត្តបានតិច

៣ = ៤១% - ៦០% គឺអនុវត្តបានមធ្យម

៤ = ៦១% -៨០% គឺអនុវត្តបានច្រើន

៥= ៨១% - ១០០% គឺអនុវត្តបានច្រើនបំផុត

| លរ. | បរិយាយ | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ | | | | | | |
| ១ | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | | | | | |
| ២ | បានធ្វើដំណើរការពិសោធន៍តាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ | | | | | |
| ៣ | បន្ទប់ពិសោធន៍មានសេចក្ដីណែនាំ ស្ដីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធន៍ | | | | | |
| ៤ | បន្ទប់ពិសោធន៍ មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | | | | | |
| ៥ | បន្ទប់ពិសោធន៍ មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | | | | | |
| ៦ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | | | | | |
| ៧ | មានវិធីសាស្ត្របង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | | | | | |
| ៨ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | | | | | |
| ៩ | គោរពតាមនីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | | | | | |
| ១០ | សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធ | | | | | |
| ចំណេះដឹងសមត្ថភាព | | | | | | |
| ១១ | មានកិច្ចប្រជុំបច្ចេកទេស អំពីការរៀបចំធ្វើកិច្ចតែងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ | | | | | |
| ១២ | ផ្ដល់ឱកាសឱ្យគ្រូមុខវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | | | | | |
| ១៣ | មានរៀបចំការប្រជុំ ស្ដីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | | | | | |
| ១៤ | បានរៀបចំកម្មវិធីប្រជុំជំបូងមួយ ជាមួយនាយកសាលាមធ្យមសិក្សាបណ្ដាញទាំងអស់ | | | | | |
| ១៥ | ធានាបាននូវយន្តការស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថិភាព | | | | | |
| ១៦ | មានសៀវភៅកត់ត្រា ការចូលធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធ | | | | | |
| ការលើកទឹកចិត្ត | | | | | | |
| ១៧ | មានការគាំទ្រឲ្យអនុវត្តមេរៀនវិទ្យាសាស្ត្រក្នុងបន្ទប់ពិសោធន៍ | | | | | |
| ១៨ | មានការលើកទឹកចិត្តឲ្យធ្វើការពិសោធន៍នៅអាគារធនធាន | | | | | |
| ១៩ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់អនុវត្តតាមមុខវិជ្ជាច្បាស់លាស់ | | | | | |
| ២០ | មានបុគ្គលិកបច្ចេកទេស សម្រាប់ជំនួយពេលប្រើបន្ទប់ពិសោធន៍ | | | | | |
| ២១ | ទទួលបានរង្វាន់លើកទឹក ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | | | | | |
| ២២ | ធ្លាប់បានឲ្យចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ | | | | | |
| ២៣ | បានរៀបចំសម្ភារៈពិសោធន៍ឲ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | | | | | |

### III.យោបល់បន្ថែម

១. តើលោកគ្រូ-អ្នកគ្រូ ជួបឧបសគ្គ អ្វីខ្លះក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាធនធាន?

................................................................................................................................................

................................................................................................................................................

...............................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

២. តើលោកគ្រូ-អ្នកគ្រូ មានសំណូមពរ ឬអនុសាសន៍ យ៉ាងដូចម្តេចខ្លះដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ?

................................................................................................................................................

................................................................................................................................................

...............................................................................................................................................

................................................................................................................................................

................................................................................................................................................

...............................................................................................................................................

................................................................................................................................................

................................................................................................................................................

...............................................................................................................................................

................................................................................................................................................

................................................................................................................................................

...............................................................................................................................................

................................................................................................................................................

................................................................................................................................................

សូមអរគុណ!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:**៦៥២០ **អយក.**វដអ

*ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩*

**ជម្រាបមក**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវរបស់និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមសាកលវិទ្យាល័យ និងរាជធានី ខេត្ត។
**យោង ៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកប្រធានថា៖ និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន១៣នាក់ ដូចមានក្នុងលិខិតឧទ្ទេសនាមជូនភ្ជាប់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរ និក្ខេបបទស្រាវជ្រាវតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកប្រធានទទួលនូវការរាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ - ឯកសារ វដអ

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៩៦៣៣ អយក.ប្រក

## លិខិតឧទ្ទេសនាម

**យោងៈ** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវ តាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ តាមបំណែងចែកដូចខាងក្រោមៈ

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កូវ ប៊ុន្ថា | ប្រុស | តាកែវ |
| ២ | កែម សុកែវ | ប្រុស | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣ | ជិន ភិរម្យ | ប្រុស | ព្រៃវែង |
| ៤ | ញ៉ែម ធា ✓ | ប្រុស | ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង |
| ៥ | ឌឿន សុគុណ | ប្រុស | ព្រៃវែង |
| ៦ | ផន ឡេង | ប្រុស | ភ្នំពេញ |
| ៧ | ភោគ ស៊ីថន | ប្រុស | សៀមរាប |
| ៨ | ម៉េត ចាន់ណេត | ប្រុស | កណ្តាល |
| ៩ | យ៉ុន សុខេន | ប្រុស | ភ្នំពេញ |
| ១០ | វ៉ាន់ លីឆេង | ប្រុស | បាត់ដំបង |
| ១១ | ស្រី រស្មី | ប្រុស | ភ្នំពេញ |
| ១២ | ហុក វិចិត្រ | ប្រុស | ព្រះវិហារ |
| ១៣ | ឡុង ចំណាន | ប្រុស | កំពង់ចាម |

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួលៈ**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអ.យ.ក រាជធានី-ខេត្តដែលពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វេជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

**វគ្គបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២**
**ប្រធានបទនិក្ខេបបទ និងគ្រូដឹកនាំ**

| ល.រ | គោត្តនាម-នាម | ភេទ | ប្រធានបទនិក្ខេបបទ | គ្រូដឹកនាំ |
|---|---|---|---|---|
| ១ | កូវ ប៊ុន្ថា | ប | ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ | បណ្ឌិត ឈាង សង្វាត |
| ២ | កែម សុកែវ | ប | ទស្សនៈយល់ឃើញរបស់សិក្ខាកាមដែលចូលរៀនវគ្គTUPនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ឯ.ឧ បណ្ឌិត សៀង សុវណ្ណា |
| ៣ | ជិន ភារម្យ | ប | ទស្សនៈយល់ឃើញរបស់នាយកសាលានិងគ្រូវិទ្យាល័យលើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី | ឯ.ឧ បណ្ឌិត សៀង សុវណ្ណា |
| ៤ | ញ៉ែម ធា | ប | ស្ថានភាពនៃការប្រើប្រាស់អាគារធនធាននៅកម្ពុជា | បណ្ឌិត ឈាង សង្វាត |
| ៥ | ខឿន សុគុណ | ប | យុទ្ធសាស្ត្រក្នុងការគៀរគរថវិការបស់វិទ្យាល័យនានាដែលបានអនុវត្តគម្រោងSEIP | បណ្ឌិត នូវ វីរ៉ា |
| ៦ | ផន ឡេង | ប | យុទ្ធសាស្ត្រក្នុងការជំរុញអនុវត្តការពិសោធនិងបច្ចេកវិទ្យានៅសាលាជំនាន់ថ្មី | បណ្ឌិត នី រដ្ឋា |
| ៧ | ភោគ ស៊ីថន | ប | ការគ្រប់គ្រងសាលារៀននៅសាលាបឋមសិក្សាវត្តបូព៌ | បណ្ឌិត នី រដ្ឋា |
| ៨ | ម៉េត ចាន់ណេត | ប | ស្ថានភាពនៃការរៀននិងបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកណ្តាល | បណ្ឌិត នូវ វីរ៉ា |
| ៩ | យ៉ុន សុខេន | ប | កត្តាជោគជ័យរបស់សិស្សទទួលបាននិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា | ឯ.ឧ បណ្ឌិត សៀង សុវណ្ណា |
| ១០ | ភ៉ាន់ លីឆេង | ប | បទពិសោធក្នុងការគ្រប់គ្រងសាលារៀននៅវិទ្យាល័យពេជ្រចិន្តា | បណ្ឌិត នូវ វីរ៉ា |
| ១១ | ស្រី រស្មី | ប | ការអនុវត្តការគ្រប់គ្រងសាលារៀននៅសាលាជំនាន់ថ្មី | បណ្ឌិត ឈាង សង្វាត |
| ១២ | ហុក វិចិត្រ | ប | ទស្សនៈយល់ឃើញរបស់សិក្ខាកាមដែលចូលរៀនវគ្គពន្លឿននៅវិទ្យាស្ថានជាតិអប់រំ | បណ្ឌិត នូវ វីរ៉ា |
| ១៣ | ឡុង ចំណាន | ប | ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់វិទ្យាល័យនានានៅកំពង់ចាម | បណ្ឌិត នី រដ្ឋា |

ថ្ងៃ សុក្រ ១២ កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៩
នាយកវិទ្យាស្ថានជាតិអប់រំ

បណ្ឌិត.សៀង សុវណ្ណា